**OMI0003**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## *សម្ភាសជាមួយឈ្មោះ ម៉ក់ ដេត អាយុ៥៣ឆ្នាំ ក្រោប្រវត្តិរូប មុខងារសព្វថ្ងៃៈ ប្រធានការិយាល័យកសិកម្មស្រុកអន្លង់វែង រស់នៅភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨*

## *សម្ភាសដោយៈ ឡុង ដានី*

### *កាសែតទី១*

*ដានី ៖ ខ្ញុំណែនាំខ្លួនប្រាប់ពូម៉ាសារទៀតថា ពួកខ្ញុំនឹងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ៗធ្វើការទាក់ទងនឹងការប្រមែប្រមូលឯកសារក្នុងជំនាន់៣ឆ្នាំ ។ ហើយការប្រមែប្រមូលនឹង យើងមានការអនុញ្ញាតិពីរាជរដ្ឋាភិបាលដែរ ។ ហើយប្រហែលជាពូដឹងខ្លះហើយ ថាការប្រមែប្រមូលនឹង យើងចង់ក្រងជាឯកសារពីរបបកម្ពុជាប្រជាធិបតេយ្យជំនាន់៣ឆ្នាំនឹង ។ ហើយរាល់ការប្រមែប្រមូលនឹង យើងគ្រាន់ទុកសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយ ឬសម្រាប់អ្នកស្រាវជ្រាវ ឬមានតុលាការគេចង់ប្រើការអី គឺយើងអាចឲ្យពត៌មាននឹងទៅគេប្រើប្រាស់ដែរ ។ ហើយមកនឹងជាដំបូងខ្ញុំចង់ឲ្យពូរៀបរាប់ពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពូខ្លះៗជាសង្ខេបនៅក្នុងសម័យ៣ឆ្នាំហើយ ម្យ៉ាងទៀតនឹង ខ្ញុំចង់បានជាសំខាន់ចង់បានពត៌មានដែលពូធ្លាប់មានទំនាក់ទំនងល្អជាមួយប្រជាជន ទាំងប្រជាជនចាស់ ប្រជាជនថ្មីនឹង ហើយក៏ពូធ្លាប់បានជួយអ្នកណាខ្លះដែលពូអាចនៅចាំដែលជួយក្នុងសម័យនឹង ដែលជាអ្នកនៅក្នុងអង្គភាពរបស់ពូ ដូចថាគាត់ជាប្រជាជនថ្មី ឬប្រជាជនណាដែលពូធ្លាប់បានជួយគាត់កាលពីសម័យនឹង ។ បើសិនជាពូមានរឿងរ៉ាវនឹង ពូអាចជួយជម្រាបប្រាប់ខ្ញុំ ។ ដំបូងខ្ញុំចង់ឲ្យពូរៀបរាប់ប្រវត្តិជាសង្ខេប ពីប្រវត្តិពូកាលពីសម័យ៣ឆ្នាំ?*

*ដេត ៖ បើនិយាយពីប្រវត្តិខ្ញុំ ពីសម័យ៣ឆ្នាំមកនឹង បើយើងនិយាយពីត្រឹមកាលខ្ញុំចេញពីផ្ទះ គិតថាចេញពីផ្ទះនៅឆ្នាំ៧០ ចុង៧០ជិតចូល៧១ហើយ ខ្ញុំរត់ចេញពីផ្ទះមក ។ អញ្ចឹងយើងបានចូលកងទ័ពរបស់កមជាប្រជាធិបតេយ្យនោះ បម្រើការងារនោះគឺនៅក្នុងស្រុកបារាយណ៍ដែរតាំងគោក ខ្ញុំធ្វើការនៅតាំងគោក ខ្ញុំវិលុកនៅម៉ាយើងត្រាំងសំរោង និងម៉ាផ្លូវស្រះ...តាមថ្នល់ជាតិលេខ៦ ។ រួមមកយើងចេះតែដំណើរការក្នុងកងទ័ពនឹងរហូតមកទល់បច្ចុប្បន្ន នៅពេលដែលសមាហរណ៍កម្ម យើងរស់នៅក្នុងដំណាក់កាលដែលក្នុងដូចថាក្នុងសម័យវិជ្ជាជាតិៗ*

ក្នុងសង្គ្រាមរវាងខ្មែរក្រហមនិងលន់នល់នឹង វាមានលក្ខណៈពិបាកដែរខ្ញុំ ព្រោះកាលនោះខ្ញុំជានារសាគេទេ ។ ប៉ុនដល់ពេលយើងធ្វើការទៅ វាមានដំណាក់កាលៗ បើខ្ញុំនិយាយរៀបរាប់ច្រើន វែងណាស់ ។ ប៉ុនខ្ញុំចង់ជម្រាបប្រាប់ថានៅឆ្នាំ៧៣ ដែលខ្លួនខ្ញុំមានបញ្ហាដែរ នៅយើងវគ្គភ្នំស្រីភ្នំប្រុស កាលនោះខ្ញុំមានរឿងរ៉ាវគេចោទប្រកាន់ខ្ញុំនឹងថាជាភ្នាក់ងារសេអ៊ីអាម៉ាសារ ហើយដល់កាលនោះគេយកមេខ្ញុំឈ្មោះឡឿន មេវរៈសេនាតូច៣០៧ យកទៅវៃចោល ។ ហើយខ្ញុំដល់ពេលគេយកមេទៅវៃចោលហើយ ខ្ញុំក៏ជាប់ក្នុងការស៊ើបអង្កេតរបស់គេ អញ្ចឹងគេហៅខ្ញុំទៅសួរ លោកឡៅ បូរាណ គេហៅខ្ញុំទៅសួរពីរឿងបញ្ហាពាក់ព័ន្ធរឿងតេអូ ព្រោះតេអូខ្ញុំអ្នកគ្រប់គ្រង ។ អញ្ចឹងតេអូនឹង ទាក់ទងទៅណាខ្លះ ខ្ញុំថាមិនដែលឃើញទាក់ទងទៅណាផង ផ្លាស់មកពីសៀមរាបមកវៃនៅកំពង់ចាមនឹង ក្នុងឆ្នាំ៧៣នឹងវាវរៈសេនាតូចគាត់មានជម្ងឺ អញ្ចឹងតេអូនៅ មេឈឺតេអូក៏ឈឺដែរ មានបានបញ្ហាទៅណា ការងារចាត់ចែងនៅលើអនុនៅលើនេះទេ តាមផ្នែករបស់ គេចោទប្រកាន់ថា“ខ្ញុំលាក់សកម្មភាពរបស់គេ” ហើយកាលនោះ ឡឿននឹងគេហៅទៅរៀន គេយកទៅវៃចោលបាត់ទៅ អញ្ចុងខ្ញុំលក្ខណៈយើងនៅក្មេង អញ្ចឹងគេអត់គេមិនទាន់ប្រកាន់អីយ៉ាងណាទេ អញ្ចឹងសភាពការណ៍ចេះតែផ្តោតទៅលើយើង ។ ដល់ពេលថ្ងៃមួយទៅ ការងារនឹងក៏គេដកខ្ញុំចេញពីអងភាពនឹង មកនៅអង្គភាពមួយទៀតជាមួយតាបេង ៣១៥ កងចល័តភូមិភាគ ។ ៣១៥ មកនៅជាមួយគាត់នឹង នៅៗទៅក៏ខ្ញុំនៅគាត់ឈប់ឲ្យនៅជាមួយ បានប៉ុន្មានខែបានគេរៀបចំកម្លាំង រៀបចំកងពលសារថ្មី មួយចំនួនមកវៃនៅព្រែកក្តាមនឹងទៅ មួយចំនួនត្រូវដកវៃនៅកំពង់ធំ-សៀមរាបមក ខ្ញុំក៏ចូលកន្លែង ៣០៩ ក្នុងកងតាបេងនឹង មានលេខរបស់គេ លេខចល័តយើងកំពង់ធំ ។ ដល់ពេលមកវៃនឹងចង់និយាយថា អានឹងដែលយើងខ្ញុំមានការចោទប្រកាន់ច្រើន អញ្ចឹងវាចេះតែរករឿង វាអត់ស្រួលដែរ វាមានបញ្ហាអី។ គេចោទតែយើងជាខ្មាំង ព្រោះយើងនៅជាមួយមេមុនទៅហើយ វាមានរឿងទៅហើយ ។ ដល់បន្ទាប់មកទៀត ខ្ញុំបានចេញពីមេឈ្មោះឡឿនមួយមក បានមកនៅជាមួយតាបេង កាលនោះគេចាត់ទុកគាត់ម៉ាប្រធានយោធានៅតំបន់នៅកំពង់ធំ ។ ដល់ពេលមកនៅនឹង កាលនោះខ្ញុំមានរឿងមួយទៀត មានរឿងជាន់មួយទៀត កាលនោះគណៈតំបន់ឈ្មោះសេងៗនឹង កាលនោះយើងអត់ដឹងត្រកូលនាម អ្នកណាឈ្មោះអី ត្រកូលអីអត់សូវដឹង ដល់ពេលគណៈតំបន់នឹងគេឲ្យខ្ញុំជូនទៅធ្វើការនៅយើងទៅស្ទឹ-ស្រែវាលនៅទល់ឥឡូវ កាលនោះខ្ញុំជូនគេមកដាក់នឹង ខ្ញុំទៅធ្វើម៉ូតូនៅស្រែវាល នៅស្ទឹនៅផ្សារស្ទឹ ។ ដល់ពេលធ្វើម៉ូតូរួច ឡប់មកវិញក៏គេឲ្យខ្ញុំនៅចាំគេនឹង នៅចាំកន្លែងស្នាក់ការគេនឹង ស្នាក់ការនារសាណាទៅអត់មានក្មេងៗដូចគ្នាថា“ចុយ!ដេតអត់ហូបបាយ” “មេប្រជុំរួចចប់តិច” “ហូបបាយនៅ”

ថា“នៅ មិនទាន់ហូបផង” “ទៅហូបនឹងគេទៅ” ខ្ញុំថា“ទៅម៉េច តាមផ្លូវៗទៅគេប្រជុំនឹងយើងទៅមិនរំខានគេ” “អឺ!យើងការងារយើងអញ្ចឹង មានទៅស្អីទេ”ក៏ដើរទៅៗមានលក្ខណៈមួយភ្ញាក់ផ្អើល បានខ្ញុំដើរទៅភ្ញាក់ផ្អើល ហើយខ្ញុំទៅទាន់ពួកគេនិយាយដែរតើ ពួកគេនិយាយថាកាលនោះសុទ្ធតែគណៈតំបន់ ហើយនឹងចៅហ្វាយស្រុក និងពួកចំការកៅស៊ូ ការងារចំការកៅស៊ូជនាន់នឹង ទៅដល់គេថា“អ្នកទាំងអស់គ្នាធ្វើការងារប្រុងប្រយ័ត្ន បើបែកការណ៍អ្នកណាមួយ ធ្វើឲ្យមានបញ្ហា សុទ្ធតែទទួលខុសត្រូវដោយខ្លួនឯង” ខ្ញុំដើរឆ្ងរីក ខ្ញុំបុកពោះពួកអាពាក្យនឹង គេមកប្រជុំម៉េចដាក់ងារងារសម្រាប់ធ្វើការងារ សម្រាប់នេះអីការងារដូចការងារស្រួលខ្ញុំគិតខ្លួនខ្ញុំ ចេញខ្មោកដើរបាន១០ម៉ែត្រគេផ្អើល “អ្នកណាដើរៗ” គេបើកមកបានតាសេងនឹងគាត់ថា“អឺ!អាក្មេងនឹងនៅជាមួយខ្ញុំអត់អីទេ”ក្មេងនៅជាមួយអញ្ចឹងយើងគិតថាវាអារម្មណ៍ណាស់ខ្លាចមានបញ្ហាៗ ដល់ពេលយើងហូបបាយរួច ដល់ពេល ដល់រងចាំដល់គេចេញពីអង្គប្រជុំបានខ្ញុំដើរមកវិញៗ ដល់ពេលដើរមកវិញ ជូនគាត់នឹងទៅលេងម្ដាយគាត់នៅម្រិញ-មាន់ហើរៗ ដល់ម្រិញ-មាន់ហើរ ដេកនៅផ្ទះម្ដាយគាត់នឹង ហ្នឹងមកតាមស្ទឹងត្រង់ មកតាមម្រិញ-មាន់ហើរមក យប់នឹងគាត់សួរពីរឿងប្រវត្តិមានបងប្អូនប៉ុន្មាននាក់ធ្វើការៗ ខ្ញុំនេះក៏ថាខ្ញុំប្រាប់ត្រង់ ខ្ញុំរៀនថ្នាក់ទីប៉ុន្មាន មានបងប្អូនប៉ុន្មាន ប្រាប់ថាបងប្អូនខ្ញុំសុទ្ធតែProfesser សុទ្ធតែគយ សុទ្ធតែទាហាន ហើយបងប្អូនខាងម្ដាយសុទ្ធតែសក្តិ៣ សក្តិ៤ សក្តិ៥ អត់មានអ្នកណាមួយអត់មានការងារធ្វើទេ ហើយសម្រាប់ខ្ញុំក៏លក្ខណៈគ្រប់គ្រាន់ហើយ គ្រួសារខ្ញុំអត់មានអីរហេមរហាមទេៗ ហើយក៏ខ្ញុំរៀនថ្នាក់ទី៧ ហើយប្រាប់គាត់ថាមានបងប្អូនប៉ុន្មានថា“៨នាក់” ប្រាប់ហេតុផលគាត់ ហើយបងទី១គ្រួសារគាត់ធ្វើទាហានដែរ ប្រាប់គាត់អស់ហើយគាត់សរថា“នៅរៀន ដែលពួកលោកគ្រូណាគេនិយាយប្រាប់ ហើយនិយាយពីរឿងខ្មែរក្រហមដែរ រឿងប្រវត្តិខ្មែរក្រហម” ខ្ញុំថា“អត់ដឹង” ព្រោះអត់ដឹងមែន អត់ម៉េចផង ប្រវត្តិខ្មែរក្រហមហើយអត់មាត់ទេ ខ្ញុំក៏អត់ដឹង គាត់ក៏អត់ប្រាប់យើងទៀតដែរ ថាគេអត់ប្រាប់យើងៗ ក៏ចេះមកដេកព្រឹកឡើងមកគិតមកដល់យើងមកធ្វើការនៅតាប៉ង យ៉េងលើកំពង់ធំតាមដងស្ទឹងសែននឹងៗ មកដល់នឹង ក៏ឲ្យខ្ញុំដាំបាយ ខ្ញុំបោចមាន់ គាត់អ្នកដាំបាយ ហើយគ្នាគេមានអ្នកដាំបាយ ប៉ុន្តែគាត់អត់ឲ្យអ្នកណាដាំទេ ដាំតែពីរនាក់ខ្ញុំនឹងៗ ដាំបាយស៊ីរួច គាត់ចេះតែសួររឿងប្រវត្តិខ្មែរក្រហម ដឹងរឿងអត់ អញ្ចឹងអារម្មណ៍ខ្ញុំគេបំពាក់ខ្ញុំហើយ គេចង់បំពាក់ ហើយចាំមើលគេចង់ដឹងថាតេយើងស្មេងយកយ៉ាងម៉េច ប៉ុន្តែខ្ញុំគិតក្នុងចិត្តរបស់ខ្ញុំគេមានគោលបំណងអីមួយហើយៗ ដល់ពេលទៅបានគេនិយាយពីប្រវត្តិខ្មែរក្រហម ដល់ហើយចង់ធ្វើមនុស្សវាបុកអង្ករបុកអីទៅ អាឡែងដាំបាយយូរទៅ ក្រោយមកទៀតទៅមើលឃើញ និយាយកាត់ហើយ

ឃើញធ្វើក្របីៗវត្តដំបូកធ្លាយ ឆ្កែនឹងចង់ធ្វើក្របី ដល់ពេលកើតជាក្របីទៅដល់ព្រាត់ទាញមិនដាច់ អញ្ចឹងមនុស្សលោកចង់តែព្រាត់មួយដាប់ ធំតែមាឌ ប៉ុនព្រាត់មួយទាញមិនបានៗ ប៉ុនឆ្កែមកឃ្វានៗនឹងព្រាត់នឹង ឃ្វានដាច់ អញ្ចឹងធ្វើឆ្កែវិញៗ អញ្ចឹងខ្ញុំនឹកគិតថា ទិសដៅរបស់ពួកនឹងធ្វើកុម្មុយនីស ហេតុអីបានមកនិយាយរឿងនឹងវិញ អញ្ចឹងខ្ញុំថាពួកនឹងនេះម៉ង សេរីម៉ងៗ អញ្ចឹងអាពាក់ព័ន្ធនឹងការងារនឹង តាំងពីនឹងមកខ្ញុំមានបញ្ហារហូត គេចេះតែរកគន្លឹះ មានបញ្ហាទៀតគេចេះតែចោទថា“ខ្ញុំមិនថាខ្លាំងៗទេណា” ប៉ុនខ្ញុំចេះតែនៅ បើយើងមិនដឹងទៅណា ក្នុងសភាពការណ៍សង្គមអញ្ចឹងទៅហើយ ។ ដល់ពេលក្រោយមកទៀតមក ខ្ញុំដិះក្រោយប៉ុន្មានថ្ងៃមកបានខ្ញុំទៅជូនៗ អញ្ចឹងទាំងប្រធានយោធា ប្រធានតំបន់នឹង ខ្ញុំជូនទៅមកអស់ ខ្ញុំនារសាគេ ដល់ពេលជូនមកទៀត ក្រោយមកទៀតបាត់គំរបអាគុយសេអ៊ិល កាលនោះជិនាន់នោះជិះសេអ៊ិល បាត់គំរបអាគុយ គេចោទខ្ញុំថាខ្លាំងម៉ង អានេះកាត់បានតែមេវ៉ា បំផ្លាញអីមិនបាន ធ្វើអីមិនបាន អាដែលយកគំរបធុងអាគុយគ្រវាត់ចោល គិតទៅមានអាគុយប្រអប់វ៉ាម្នាងៗ រករឿងរក ខ្ញុំទ្រាំមិនបានខ្ញុំរត់ៗចេញៗ គេតាមបាញ់ខ្ញុំចោលរហូត ហើយគេឲ្យកម្លាំងពីរនាក់ ខ្ញុំរត់រហូតមកតាំងពីកំពង់ធំមកដើរកាត់មកលើ ពីតាំងក្រសាំងអីមក មកនៅកំពង់ថ្មៗ រួចទៅបានខ្ញុំទៅចូលដែលគេនៅយើងនៅវត្តបឹងពែង ឆ្លងព្រែកក្តាមៗខ្មែរក្រហមវៃបានហើយណា វៃបានលន់លល់ហើយ ។ អញ្ចឹងវៃគេម៉ាជួរយើងព្រែកព្នៅនឹង ហើយម៉ាជួរកប់ស្រូវ ...ម៉ាជួរនឹង សមរភូមិកណ្តាលវៃក្នុងទឹកមែន នៅធ្វើការគេនឹងទៅៗ ដល់ពេលទៅធ្វើការឲ្យគេនឹង ក៏គេឲ្យខ្ញុំឡើងជាអនុសេនាតូច ។

ដានី : អនុសេនាតូច ឆ្នាំណា?

ដេត : ឆ្នាំ៧៤ហើយ ចុង៧៤ ជិតចូល៧៥ហើយឆ្នាំ៧៤ កាលខ្ញុំទៅជិតចូល៧៤ ខែ១២ ខ្ញុំរត់នឹងក្នុងខែ១១ ខែ១២ ដល់ពេលធ្វើការងារបានប៉ុន្មានខែដែរ បានដល់ចូលឆ្នាំ៧៥ អា១៧មេសានឹងៗ

ដានី : ចុះកាលនៅជាមួយឈ្មោះសេង គាត់គណៈតំបន់?

ដេត : គណៈតំបន់ នៅកំពង់ធំៗ

ដានី : គាត់លេខាតំបន់?

ដេត : បាទ! លេខាតំបន់ៗ

ដានី : តំបន់ប៉ុន្មានកាលនឹង?

ដេត : កាលនោះតំបន់៤២ ។

ដានី : តំបន់៤២?

ដេត ៖ បាទ! ទីតាំងគាត់នៅក្នុងខាងដែលចំប៉ាក្រហមក នៅតាប័ង ។

ដានី ៖ គេចាប់គាត់ដែរ កាលនោះ?

ដេត ៖ កាលនោះ អត់ទាន់ចាប់ទេ គេចាប់គាត់នៅពេលគាត់ឡើងមកដល់ពេលឈ្នះលន់នល់ ដាច់ភ្នំពេញហើយនឹង គាត់ឡើងមកកសិកម្មក្រសួងកសិកម្ម ក្រោយមកបានគេចាប់ ។ អញ្ចឹងបានថាជំនាន់នឹងវាមានការប្រទូសប្រទាស់គ្នាផ្នែកនយោបាយផ្ទៃក្នុង អញ្ចឹងមិនដឹងអ្នកណាអ្នកណែដែលនឹង ។ ខ្ញុំដឹង បើតាមសន្ទាក់ខ្ញុំមើល អញ្ចឹងពួកនឹងតាមសម្លាប់ខ្ញុំហើយ ព្រោះអាថ្ងៃដាច់ភ្នំពេញនឹង តាសៀនមួយតាសៀនអនុតាសុតៗនៅសៀមរាប ។ តាសៀននឹង គាត់ទៅចន្ទុះមុខខ្ញុំនៅក្បាលស្ពានជ្រោយចង្វារ កាលនោះយើងដាច់ភ្នំពេញហើយនឹង ចន្ទុះថា“ឯងខូច” “យី!ខូចម៉េច បើខ្ញុំខូចខ្ញុំរត់ អត់មាននៅរ៉ៃខ្ទាំងទេ ខ្ញុំរត់ទៅណាទៅណែបាត់ហើយ ខ្ញុំមករ៉ៃខ្ទាំងទេ ខ្ញុំខូចម៉េច” ខ្ញុំថាអញ្ចឹងឯង ។ ហើយដល់ពេលទៅគេតាមព្យាបាទខ្ញុំរហូត អញ្ចឹងអារឿងដែលក្រោយមក ខ្ញុំទៅនៅកំពង់សោម ដូចខ្ញុំបានប្រាប់អញ្ចឹង ។ ហើយនៅកំពង់សោមនឹងការពិត ខ្ញុំនៅកម្មករគេនឹង នៅអង្គភាពប្រធានកម្មករនៅឃ្លាំងលើ ។

ដានី ៖ ពូចូលបែកភ្នំពេញឆាំ៧៥ភ្លាម គេបញ្ជូនពូទៅកំពង់សោមភ្លាម?

ដេត ៖ បាទ! បានកន្លះខែ នៅភ្នំពេញបានកន្លះខែ ខ្ញុំទៅនៅកំពង់សោម ។ នៅកំពង់សោម ខ្ញុំទៅនៅឃ្លាំងលើ ហើយមកធ្វើការនៅកំពង់ផែនៅភ្នំផែរទេះភ្លើង សារចុះសារឡើង លើកសម្ភារៈដឹកអង្ករចូលពីចិនមក ។ លីតែអង្ករទេខ្ញុំ លីតែអង្ករ លីតែក្រណាត់ លីដាក់ឃ្លាំងលើនឹង ត្រូវបពានមកតាមខេត្ត បញ្ជូនមកភ្នំពេញតាមឡាន តាមទូរទេះភ្លើង ប៉ុនខ្ញុំអត់ចាំខែហើយឆ្នាំណា គេថា“អូ!មិនបាច់យកអង្ករទៀតទេ ដែលយើងធ្វើស្រែបានច្រើនហើយ” ។ ហើយយើងស្មានតែប្រទេសជាតិវារីកចំរើនតាមនឹងដែរ ដល់ពេលចូលឆ្នាំចុង ដូចពាក់កណ្តាល៧៦ហើយ ចូលខែ៦ខែ៥ បានខ្ញុំត្រូវដកចេញពីនឹងមកភ្នំពេញ មកនៅវត្តខណ្ណលោម ។ ដល់ពេលមកនៅវត្តខណ្ណលោម គេឲ្យនៅកម្មករសម្រាប់លីចុះ លីឡើងអញ្ចឹង ហើយចេញពីកប៉ាល់តូចៗនឹង លីគរ លីកប្បាស លីគ្រាប់ឈូក លីអញ្ចឹងទៅៗ លទ្ធផលនាំចេញលក់លី ។ ដល់ពេលអត់មានការងារលីសែង ទៅបកគរនៅក្បាលថ្នល់ ហើយក្រោយមកបានគេឈប់នៅវត្តនឹងហើយ ។ ដែលរឿងរៀប ប៉ុនខ្ញុំអាពេលដែលខ្ញុំចេញពីវត្តខណ្ណលោមទៅគេឲ្យខ្ញុំចេញទៅប៉ោយប៉ែត ។

ដានី ៖ រយៈពេលប៉ុន្មាន បានគេឲ្យទៅប៉ោយប៉ែត?

ដេត ៖ មកនៅនឹងយូរដែរ ប្រហែលខ្ទង់៥-៦ខែ ។

ដានី ៖ ឆ្នាំណា?

ដេត ៈ ក្នុងឆ្នាំ៧៦ដែរ ចុង ចំមើលខ្ញុំនៅកំពង់សោមម៉ាឆ្នាំម៉ាខែម៉ាអាទិត្យឲ្យតែការងារចាំ ម៉ាឆ្នាំម៉ាខែម៉ាអាទិត្យបានមកនៅភ្នំពេញៗបានប៉ុន្មានខែ បានគេឲ្យខ្ញុំទៅនៅច្រកប៉ោយប៉ែត ។ ច្រកប៉ោយប៉ែតខ្ញុំសម្រាប់លក់អីវ៉ាន់ចេញ ។ លក់អីវ៉ាន់ចេញនឹង លក់ទាំងត្រី ឡាន ម៉ូតូ ថាស ចំរៀង កៅស៊ូក្រែត កៅស៊ូក្រែតអត់ទាន់លក់ទេ លក់តែអាកៅស៊ូស្អុយ ។ អញ្ចឹងនៅដោះដូរ ហើយនឹងទិញសម្ភារៈចូលវិញៗ ។ ប៉ុនដល់ពេលដំណាក់កាលនឹង បានខ្ញុំទៅជួប មានកម្លាំងតាសឿននឹងទៅជួបៗខ្ញុំនៅនឹង មានបញ្ហាទៀត ។ ទៅដល់សំលឹងមុខខ្ញុំ ខ្ញុំរឿងទៀតហើយ ព្រោះខ្ញុំដឹងថាខ្សែពួកគេ ព្រោះខ្ញុំអត់មានខ្សែម៉ាសំឡុងទេ ខ្ញុំធ្វើការទៅ ខ្ញុំចេះតែលោតៗទៅ ចេះតែទៅតាមអញ្ចឹងទៅ ហើយមិនមានអី ។ ដល់ពេលនៅបានប៉ុន្មាន គេចោទថា«ខ្ញុំសេអ៊ីអាប្រុងរត់ទៅថៃ» ទៅរឿងអានឹងទៀតហើយ ខ្ញុំនឹកឃើញទៀត រឿងប្រឌិតទៀត ខ្ញុំចេះតែបុកពោះ ។ ហើយដល់ពេលក្រោយមកទៀត ថាខ្ញុំទាក់ទងជាមួយនារី ស្រឡាញ់នារីនឹង អានឹងមានការឈ្លោះគ្នាវែងឆ្ងាយណាស់ រឿងជាមួយនារីនឹង ហើយខ្ញុំអត់ៗទេ ។ បានខ្ញុំ អានឹងដដែកគ្នា តាឈឿនៗសមាជិកក្រសួងពាណិជ្ជកម្ម តាឈឿននឹងទៅនៅចេញចូលតាមដានសម្រេចឲ្យតាវ៉ាន់មួយ នៅដកពីពាយ័ព្យពាណិជ្ជកម្មពាយ័ព្យនឹងទៅនៅនឹងដែរទៅសួរខ្ញុំថា«នារីនឹងមានទាក់ទងនារីនឹងអត់» ប៉ុនការពិតគេធ្វើរកគន្លឹះសម្រាប់កំចាត់យើងចេញពីកន្លែងនឹងម៉ង ធ្វើម៉េចអ៊ុកឡុងឲ្យយើងចេញមក សម្រាប់គេស្រួលទាក់ទងគ្នាយើងម៉េច យើងអត់យល់ត្រង់នឹង ។ ហើយមានឈ្លោះគ្នាច្រើនណាស់ ហើយបានគេដកខ្ញុំបានប្រាប់មិញអញ្ចឹង បានដកខ្ញុំមកនៅក្នុងភ្នំពេញនឹងវិញ ។ ក្រោយមកបានដកខ្ញុំមកធ្វើកម្មករនៅយើង ទន្លេបិទកៅស៊ូក្រែតចុះឡើង ។

ដានី ៈ ដកពីប៉ោយប៉ែតមកនៅភ្នំពេញ?

ដេត ៈ បាទ! នៅភ្នំពេញ ។

ដានី ៈ នៅកន្លែងណា?

ដេត ៈ ខ្ញុំនៅនែក! គីឡូលេខ៦ ។

ដានី ៈ ទៅប៉ោយប៉ែតរយៈពេលប៉ុន្មាន បានគេដកមក?

ដេត ៈ យូរដែរ ជិតម៉ាឆ្នាំដាង គិតទៅម៉ាខែវស្សារហូតដល់ប្រាំង ខ្ញុំវាភ្លេចដែរទៅ ប៉ុនគ្រាន់ថាក្នុងអំឡុងចូលខ្ទង់ចូល៧៧ហើយ ដកខ្ញុំមកវិញ ជិតចូល៧៧ហើយ ។

ដានី ៈ ដកពូទៅប៉ោយប៉ែតចុងឆ្នាំ៧៦?

ដេត ៈ បាទ! ចុង៧៦ អញ្ចឹងធ្វើការជិតចូល៧៧បានមកវិញ តាមហ្នឹងហែរ ។

ដានី ៈ ៧៧?

ជេត ៖ ចូល៧៦ ជិត១៧៧ បើខ្វះតិចតួច ខ្ញុំភ្លេចអានឹង ប៉ុនអត់យូរប៉ុន្មានទេ ។

ដានី ៖ អញ្ចឹងទៅ ហ៊ើយប៉ែតអត់យូរប៉ុន្មានទេ?

ជេត ៖ បាទ!អត់យូរប៉ុន្មានទេ ហ៊ើយប៉ែតមានរឿងៗប្រហែលដកចេញពីនឹងមក សេអ៊ីអារបស់… ទៅនឹង ។

ដានី ៖ ផ្លាស់មកនៅគីឡូលេខ៦?

ជេត ៖ បាទ! ដល់ពេលមកនៅគីឡូលេខ៦ នៅនឹងចុះឡើងបានគេឲ្យទៅនៅក្បាលថ្នល់ទៀត ។

ដានី ៖ រយៈពេលប៉ុន្មានបានទៅនៅក្បាលថ្នល់?

ជេត ៖ អត់យូរទេ ម៉ាខែៗកាលនឹង ហើយបានបញ្ជូនចុះបញ្ជូនឡើង ។

ដានី ៖ នៅគីឡូលេខ៦ធ្វើអី?

ជេត ៖ កម្មករ ។

ដានី ៖ កម្មករធ្វើអីអានឹង?

ជេត ៖ កាលនឹងនៅក្នុងក្របខណ្ឌក្រសួងពាណិជ្ជកម្មដែរ កម្មករលីកៅស៊ូស្អុយ លីគ្រាប់ឈូក លីសណ្តែក ។

ដានី ៖ លីទៅណា?

ជេត ៖ លីយកមកដាក់ទន្លឃ្លាំង អត់មានយកទៅណាទេ ។

ដានី ៖ កៅស៊ូអីនឹង យកមកពីខាងណា មកដាក់នឹង?

ជេត ៖ មកពីមេមត់ មកពីតាំងសាឡង់ៗ យើងលីឡើងមកសម្រាប់ដាក់ទូកទេះភ្លើងបញ្ចេញទៅកំពង់សោម ។ ហើយដល់ពេលរួចទៅ គេអត់ឃើញមានអីអញ្ចឹងទៅ ក៏គេដកខ្ញុំនេះមកនៅទួលទំពូងម៉ារយៈទៀត បានចេញពីទួលទំពូងមក បានគេឲ្យរៀបចំកម្លាំងហើយទៅ ។

ដានី ៖ ធ្វើអីដែរនៅទួលទំពូង?

ជេត ៖ នៅទួលទំពូង ឲ្យមកបកករគេចាត់ការងារបកករ បកករមួយថ្ងៃៗអត់មាន បកករនឹងអត់មានពេលទំនេរទេ គេបែកវេនគ្នា ឧទាហរណ៍ពីព្រឹក អញ្ចឹងការងារក្នុងពាណិជ្ជកម្មការនឹងពិបាកដែរនឹង យើងធ្វើកម្មករនឹងពីម៉ោង៦ដល់ម៉ោង១២ ហូបបាយ អញ្ចឹងដល់ពេលម៉ោង៦ម៉ោង១២ទៀត ធ្វើកម្មករអាលីសែងនៅកំពង់សោមក៏អញ្ចឹងនៅនេះអញ្ចឹងទៀត អនុវត្តអញ្ចឹងឯងអត់មានពេលទំនេរទេ ទំនេរតិចណាស់ ។ ហើយដល់ពេលម៉ាវគ្គនឹងរួច បានគេឲ្យខ្ញុំមកនៅមន្ទីរក្រសួងនៅមេមត់នៅអីនឹង អស់ម៉ារយៈរដូវប្រាំងបានដកឡប់ទៅវិញ ទៅគ្រប់គ្រងនៅកន្លែងនេះនឹង ក្នុងខែ៤ខែ៥ខែ៦ នៅធ្វើការនៅរោងចក្រម៉ាស៊ីនអេស្កាដេរ នៅទន្លេបិទ ។

ដានី ៖ អញ្ចឹងទៅនៅ ផ្លាស់ពីគីឡូលេខ៦ទៅនៅទួលទំពូង នៅបាន?

ដេត ៖ នៅទួលទំពូងខ្ញុំនៅចង់២ខែដែរ ២-៣ខែដែរ ដើរចុះដើរឡើង ។

ដានី ៖ ដល់ពេលប្រហែលបាន២-៣ខែ បានគេផ្លាស់មកនៅណា?

ដេត ៖ បានគេឲ្យកម្មករនៅទន្លេបិទ ប្រហែលនៅម៉ារដូវ១ទឹកឡើង ។

ដានី ៖ ខែឆ្នាំ៧៧ដែរ?

ដេត ៖ បាទ! ចូលក្នុងឆ្នាំ៧៧ហើយ ។

ដានី ៖ ខែ១ ប្រហែលខែប៉ុន្មាន ខែវស្សា ខែប្រាំង?

ដេត ៖ ការពិតខែវស្សា ។

ដានី ៖ ចុងហើយ ចុង៧៧?

ដេត ៖ បាទ! ចុង ជិតចុងហើយ មកខ្ទង់ខែ៩ខែ១០ ដឹងយើងធ្វើការបានប៉ុន្មានទេ ចូលក្នុងដល់ខែ១ហើយបានបកទៅភ្នំពេញវិញ ។

ដានី ៖ ទៅមកទន្លេបិទធ្វើអី?

ដេត ៖ កាលនឹងលីកៅស៊ូដាក់សាឡង់ មានឡានដឹកជញ្ជូន១ដើងគោកគេ ។

ដានី ៖ កៅស៊ូមកពីខាង?

ដេត ៖ ដកពីមេមត់ និងជប់ កៅស៊ូក្រែក ទម្លាក់សាឡង់នឹង នៅធ្វើការនៅនឹងកំពង់ផែ ។

ដានី ៖ ពូនៅធ្វើការនៅកំពង់ផែ?

ដេត ៖ កំពង់ផែក៏នៅ ហើយដូរនេះ ឧទាហរណ៍ថារោងចក្រដំណើរការអសជប់១ គេឲ្យទៅមេមត់ ដល់ពេលមេមត់ចុះឡើង អស់កៅស៊ូនឹង បានអ្នកធ្វើដូរ អាពួកនេះមកនៅទន្លេបិទម្ដង យកអាពួកទន្លេបិទនឹងទៅនៅជប់ម្ដងដោះដូរគ្នា បង្វិលគ្នាដូរជាប់សម្រាប់ដាក់ឡាន ។ ដល់ពេលយើងផ្លាស់ពីនឹងទៀតមក បានយើងនៅកន្លែងនៅភ្នំពេញ ។ នៅភ្នំពេញ អត់នៅយូរទេ ម៉ានៅកន្លែងរោងម៉ាសីនអេស្កាដេរយ៉ាងច្រើន២ខែ អាឈ្មោះគ្នាដែលខ្ញុំនិយាយនឹងណា ។

ដានី ៖ នៅរោងម៉ាស៊ីនអេស្កាដេរ កាលនឹងខែប៉ុន្មានដែរ?

ដេត ៖ ខែនឹងខែប្រមូលផល ខ្ទង់ខែ១ ចុងខែមួយ ។

ដានី ៖ ខែមួយឆ្នាំ ៧៧ ៧៨?

ដេត ៖ ដូចមិនទាន់៧៨ទេ ខ្ញុំហាក់បីដូចជាច្រឡំថ្ងៃខែ ប៉ុនគ្រាន់ថាយើងអត់ចាំថ្ងៃខែច្បាស់ទេណាសម្រាប់ចាំ១ម៉ោងអញ្ចឹង ។

ដានី ៖ ប្រហែលខែ១ ៧៧ ក៏ខែប៉ុន្មាន?

ដេត ៖ ក្នុងខែ១ ៧៧ ។

ដានី ៖ ចុះពីមុនមកប្រហែល?

ដេត ៖ នែក! ខ្ញុំខែ១ ព្រោះយើងទៅដាប់ដែលខ្ញុំគេចាត់ទុកឲ្យនៅនេះដូចប្រាំងវស្សា កាលពិតវាអត់ភ្លេចរឿងប្រាំងវស្សា អាចុះបើងប៉ាយ៉ាបនឹងថ្ងៃណាក៏ថ្ងៃសើមរហូត កាលពេលធ្វើនឹងប្រាំងទេ នៅនឹង ។

ដានី ៖ នៅណានៅប្រាំង?

ដេត ៖ នៅដែលគេដកនៅប្រាំងចំរេះ វាចាត់ទុកថាយើងជាពួកនិន្នាការហើយណា ។

ដានី ៖ ដកពីដប់មកនៅកន្លែងរោងកិនម៉ាស៊ីស្រូវអេស្កាដេរ?

ដេត ៖ បាទ! នៅគីឡូលេខ៦ សម្រាប់ដឹកអង្ករ សម្រាប់លីស្រូវ កិនអង្ករកិនអីនឹងឯង ។ ហើយដល់ពេលចេញពីនឹងទៀតមក អានឹងបានគេដកហើយ ។

ដានី ៖ នៅកន្លែងអេស្កាដេរ កាលនឹងពូធ្វើប្រធាន?

ដេត ៖ ខ្ញុំប្រធានអនុសេនាតូច សម្រាប់ ។

ដានី ៖ តាំងពីរហូតប្រធានអនុសេនាតូចរហូត?

ដេត ៖ បាទ! ប្រធានអនុសេនាតូចរហូត ហើយដល់ពេលគេមកប្រជុំដកនៅមន្ទីរ៥១នឹង១របស់ពាណិជ្ជកម្មក្បែរផ្សារចាស់យើងពីដើម ។

ដានី ៖ ពេលកាលនឹង ពេលពូធ្វើការនៅកន្លែងរោងម៉ាស៊ីនកិនស្រូវអេស្កាដេរ គេឲ្យមកប្រជុំនៅមន្ទីរ?

ដេត ៖ បាទ! គេដកមកជុំគ្នានៅត្រង់នឹង ។

ដានី ៖ មកមន្ទីរ៥១?

ដេត ៖ បាទ! ហើយដកមកនឹង កាលនឹងខ្ញុំអត់ដឹងគេដកទៅណាទេ មុនស្មានគេដកទៅរៀនៗ អញ្ចឹងបានគេដកមក បានគាត់ុងនឹងមួយ គាត់ុងមុននៅបាត់ដំបង គាត់ុងប្រាប់ថា"ដេតៗឯងទៅនឹងមិនធម្មតាទេ អញ្ចឹងមានបញ្ហាហើយ អញ្ចឹងគេយកដេតឯងទៅលុតដំ អញ្ចឹងដេតឯងរកខោអាវទុកឲ្យហើយទៅ ទៅដល់នោះគ្មានអ្នកណាបើកឲ្យទេ" គាត់ប្រាប់ដែរណាគ្មានអ្នកណាបើកខោអាវឲ្យយើងទេ ។ ខ្ញុំនឹកឃើញមិនដឹងទៅរកឯណា គេដកមកហើយបានប្រាប់ អាមកនេះមានដើរទៅរកខោអាវណាបាន ហើយអញ្ចឹងក៏គ្មានបានត្រៀមខោអាវអីច្រើនទេ ខោអាវគេអត់មានបើកឲ្យផង ខោអាវយើងមានប៉ុន្មានប៉ុននឹង របូតតាំងពីនឹងទៅដល់ទៅរហូតទល់នឹងសភាពការណ៍៧៩ ។

ដានី ៖ អញ្ចឹងពេលនៅរោងចក្រអេស្កាដេរនឹង មកប្រជុំរហូត?

ដេត ៖ បាទ! មកគេមកដកបណ្ដោយ ។

ដានី ៖ ឆ្នាំណាដែលគេហៅមកប្រជុំនៅមន្ទីរ៥១នឹង កន្លែងផ្សារចាស់?

ជេត ៖ នៅមន្ទីរ៥១ អាផ្សារចាស់ ខ្ញុំវាភ្លេចខែឆ្នាំច្បាស់ ប៉ុនខ្ញុំដឹងម៉ាដំណាក់កាលៗ អញ្ចឹង ខ្ញុំកត់របស់ខ្ញុំដែរមុន ក្រោយមកវាខ្ចិលលែងរវល់ ។

ដានី ៖ ប្រហែលជា៧៧ ឬ៧៨?

ជេត ៖ អត់ទាន់ចូល ៧៨គឺខ្ញុំមកដល់ស៊ីងត្រង់ហើយ មកកន្លែងលុតដំហើយ ។

ដានី ៖ អញ្ចឹងនៅ៧៧នៅឡើយ?

ជេត ៖ បាទ! ក្នុង៧៧ ។

ដានី ៖ ខែ៧៧នឹង ខែប្រាំង ខែវស្សា?

ជេត ៖ តាមខ្ញុំមើលអត់ ចូលខ្ទង់ខែវស្សា ខ្ទង់ខែ បើមិនខែ៩ ខែ១០ ព្រោះនៅបានតិចទេ នៅក-១០នឹង បានតិចបានគេឲ្យនៅឡូនេសាទសម្រាប់នេះនៅព្រែកព្នៅនឹង ពេលដាច់ ។

ដានី ៖ អញ្ចឹងពេលមកប្រជុំនៅកន្លែងពាណិជ្ជកម្ម គេមកប្រជុំនៅកន្លែងមន្ទីរ៥១ ប្រជុំម៉េចខ្លះ ពីណាគេមកប្រជុំ?

ជេត ៖ តារិទ្ធៗនឹងកាលនោះប្រធានពាណិជ្ជកម្ម ។

**ផ្នែក«ខ»**

ដានី ៖ តារិទ្ធ ប៉ុន្តែគុយ ធួនគេចាប់តាំងពីអន្លង់?

ជេត ៖ អត់ដឹងៗពីអន្លង់ ប៉ុនខ្ញុំដឹងថាគេចាប់ហើយ គេអត់ទាន់អី ។

ដានី ៖ គុយ ធួន?

ជេត ៖ បាទ! គុយ ធួនហៅធុច ។

ដានី ៖ គុយ ធួនហៅ ធុច គេចាប់?

ជេត ៖ បាទ! គេចាប់បាត់ហើយ ។

ដានី ៖ ដល់ចាប់ហើយគេតាំងឡើង?

ជេត ៖ តារិទ្ធិៗនឹងបានគេដកពួកខ្ញុំ ។

ដានី ៖ តារិទ្ធិនឹង អ្នកមកពីណាមកដែរ?

ជេត ៖ ដូចតារិទ្ធិគាត់មុនដូចប្រធានភូមិភាគ ដែលមកក្តាប់នៅកន្លែងនឹង ។

ដានី ៖ រៀងម៉េចគាត់នឹង?

ជេត ៖ ទាប តុល ខ្មៅ ។

ដានី ៖ គាត់មកប្រជុំជាមួយពីណាខ្លះកាលនឹង?

ជេត ៖ កាលនោះ ធំនៅគាត់ ហើយតាតុងនឹង ។

ដានី ៖ តាតុងនឹងគាត់?

ដេត ៖ តាតុងនឹង គាត់ពីមុននៅទំនាក់ទំនងជាមួយខ្ញុំនៅប៉ោយប៉ែតដែរ តែក្រោយមកគេដក ។

ដានី ៖ តាតុង ហើយតាហុង?

ដេត ៖ តុងៗចិនណា ជនជាតិចិន ។

ដានី ៖ គាត់ធ្វើធំដែរ?

ដេត ៖ គាត់មិនមែនជាអ្នកធំ គាត់ជាសកម្មជនគេល្អដែរជួយកាលជំនាន់អាពត អាចជួយគិតអីឲ្យ ធ្វើសកម្មជនមក ដល់ពេលក្រោយមកគេទុក ។ បាននៅ គាត់ជាអ្នកបេះដឹងមួយនៅកន្លែងក្រឡាបញ្ជីស្នាម ។

ដានី ៖ គាត់មកប្រជុំជាមួយតារិទ្ធិ?

ដេត ៖ បាទ! មកប្រជុំតារិទ្ធិនឹង គាត់នឹងបានប្រាប់ខ្ញុំថា «គេដកដេតឯងទៅនឹង គឺមិនរឿងធម្មតាទេ គេចោទពីបញ្ហាពាក់ព័ន្ធនយោបាយហើយ» ។

ដានី ៖ កាលប្រជុំនឹង មានគ្នាប៉ុន្មាននាក់ដែលគេហៅមកប្រជុំ?

ដេត ៖ នៅប្រជុំនឹងការពិតនៅតែនឹងមានគ្នា៣៨នាក់ អាចថាថ្នាក់៣៨នាក់ ។

ដានី ៖ ថ្នាក់ៗអីគេកាលនឹង?

ដេត ៖ ថ្នាក់សុទ្ធតែប្រធានក្រុម អនុសេនាតូច អនុសេនាធំ អញ្ចឹងលាយសុទ្ធតែជនចំរើន យុវកក បក្សជន ។

ដានី ៖ ជនចំរើន យុវកក ហើយនឹងបក្សជន?

ដេត ៖ បាទ!

ដានី ៖ ហើយប្រជុំនឹង គាត់និយាយថាម៉េច តារិទ្ធិគាត់និយាយថាម៉េចខ្លះ?

ដេត ៖ គាត់ថា «អស់មិត្តទាំងអស់ ដែលហៅមកប្រជុំទាំងអស់ អស់មិត្តទាំងអស់ដែលយល់ថាបក្សមិនទុកចិត្តសមាមិត្តអីយ៉ាងណាទេ តែអង្គការសុំឲ្យសមាមិត្តទៅនៅម៉ាជុំសិន ហើយបើសិនជាអ្នកណាមួយដែលគ្នាការពាក់ព័ន្ធ ហើយនឹងមានរឿងអីនោះបក្សនឹងយកមកធ្វើការវិញ អញ្ចឹងប្រមូលទុកម្តុសម្រាប់ការស៊ើបអង្កេត» គាត់និយាយរៀងវាមិនដល់ការស៊ើបអង្កេត ថាយកទៅម្ជុំសម្រាប់យើងកសាងខ្លួន ។ អញ្ចឹងយើងបានសេចក្តីថាយើងមានកំហុសយ៉ាងណានោះវាជារឿងមួយហើយ ។ ហើយដល់ពេលអញ្ចឹង យើងមកនៅរួចមកគេបញ្ជូនមកកោះធំ ។

ដានី ៖ ប្រជុំរយៈពេលប៉ុន្មានទៅ?

ដេត ៖ អត់ដល់ម៉ោងទេ ការពតយើងរៀបរាប់ណែនាំតិចថាយើងត្រូវផ្លាស់ ។

ដានី ៖ តារិទ្ធិគាត់នៅកន្លែងមន្ទីរ៥១នឹង?

ដេត ៖ បាទ! គាត់នៅកន្លែងនឹងម៉ង នៅក្រសួងកសិកម្ម នៅតែនឹង ។

ដានី ៖ ក្រសួងកសិកម្ម ក្រសួងពាណិជ្ជកម្ម?

ដេត ៖ ពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ។

ដានី ៖ មន្ទីររបស់គាត់ធ្វើការ នៅមន្ទីរ៥១?

ដេត ៖ បាទ!

ដានី ៖ នៅផ្សារចាស់?

ដេត ៖ ផ្សារចាស់ ។

ដានី ៖ ដល់ពេលប្រជុំមកដល់ប៉ុន្មាន បានគេទាំង៣០នាក់នឹង បានគេបញ្ជូនផ្លាស់មក?

ដេត ៖ ផ្លាស់មក បានឡានមកដឹកមកទម្លាក់នៅកន្លែងក-១០ ។

ដានី ៖ ក-១០នៅណា?

ដេត ៖ ប្រាំងចំរេះ វត្តចាប កន្លែងចិញ្ចឹមជ្រូក កន្លែងចិញ្ចឹមត្រីស្រស់ ។ ឲ្យនៅនឹងល្ងាចឡើងទាល់តែមកដល់ភ្លាមម៉ោង យើងគិតថាម៉ោង៦ដល់ហើយណា សម្រាកបាននេះនឹងថ្ងៃតិចបានគេហៅប្រជុំៗសម្រាប់បានម៉ាថ្ងៃនឹង ហើយគេរៀបផែនការឲ្យយើងពលកម្មបណ្ដោយ ។ អញ្ចឹងអ្នកណាទៅកាប់ពើក អ្នកណាត្រូវស្រោចទឹកដំណាំ អ្នកណាត្រូវរកត្រី អ្នកណាត្រូវដក ត្រូវស្ទូង អីរៀបចំប្រព័ន្ធធ្វើស្រែនឹងបណ្ដោយ ចាប់ផ្ដើមបណ្ដោយ ធ្វើស្រែខ្លួនឯង ។ ពួកយោធាគេកំពុងកាប់ផ្លូវជាតិលេខ៥នឹង បង្ហូរទឹកពីបឹងប៉ាយាប់មកឲ្យគោក ។ ហើយចាប់ផ្ដើមអនុវត្តធ្វើស្រែនៅនឹងបណ្ដោយ អញ្ចឹងបានគេដល់ពេលធ្វើស្រែដល់ខ្ញុំបាននេះទេ បានគេដកខ្ញុំមកបានប៉ុន្មានខែផង ដល់រដូវត្រីចុះ ឲ្យខ្ញុំមកនៅកន្លែងឡូនេសាទនៅប្រាំងចំរេះនឹងឯង ឡូគេនៅជិតនឹង ឲ្យនៅគ្រប់គ្រងតែពួកខ្ញុំនឹងឯង ហើយគេយកដាក់ប្រធានមួយៗ ។ ក្រោយមកបានអស់ត្រីហើយ បានគេឲ្យទៅធ្វើស្រែៗ គេឲ្យដើររើ ពេលស្រូវទុំឲ្យរើកណ្ដុរ ដូចខ្ញុំថា ។ ពេលប្រជុំគេរករឿងមិនរើកណ្ដុរ រើតែគួរស្រូវ ហើយមានរឿងគេចោទប្រកាន់រហូត គេចេះតែកសាងយើង ប៉ុន្មម្នាក់ៗខំព្យាយាមឲ្យល្អ ធ្វើម៉េច ។

ដានី ៖ ហើយពូកាលនឹងដូចថា ពូដឹងខ្លួនថាគេយកទៅលុតដំនឹង ពូមានកំហុសអីបានគេយកទៅលុតដំ?

ដេត ៖ កាត់ បើយើងនិយាយពីការងាររបស់យើងថាអត់មានកំហុស ប៉ុន្តែជារឿងចោទប្រកាន់បក្សពួកម៉ង អញ្ចឹងយើងនៅក្នុងខត្តរ អញ្ចឹងមេធំក្បត់ហើយ គេរើម៉ារ៉ាប់ម៉ាខ្សែនឹងក្បត់ទាំងអស់បណ្ដោយ ។

ដានី ៖ គេថាអញ្ចឹង?

ដេត ៖ បាទ! គេថាអញ្ចឹង ព្រោះបានអីដូចខ្ញុំបានបញ្ជាក់អញ្ចឹង អាថ្ងៃមួយដែលខ្ញុំប្រាប់ថាឈ្មោះអាចេក និងរីមនឹង ចេង រីមនឹងវាជិះគ្នា កាប់ពើកនោះ ដល់ពេលល្ងាចនឹងគេចែកស្រែកសម្រាក មនុស្សច្រើន នឹងដកពីគ្រប់អង្គភាពមកនាំគ្នាធ្វើស្រែម៉ាពាន់ ពីរពាន់នាក់ ។

ដានី ៖ មិនមែន១៥នាក់ អឺ!៣០នាក់?

ដេត ៖ អឺ! មិនមែនទេ ម៉ាពាន់នាក់ដាង មកពីពាយ័ព្យ មកពីកងពលប៉ុន្មាន ពួកនៅជួរព្រំដែន ពួកនិមិត្តអីនឹង ម៉ាចំនៀរនឹង ពួកនឹងទៅនៅនឹងទាំងអស់ នាំគ្នា ទាំងប្រពន្ធកូននាំគ្នាធ្វើស្រែ មិនតិចទេ រាប់ពាន់នាក់ ហើយរកអុសដុតមិនបាន វារុះតែផ្ទះអ្នកស្រុកនៅម៉ាជួរប្រាំងចំរេះ អាផ្ទះចាម អាផ្ទះណាចាស់ល្អមៗរើផ្ទះនឹងយកទៅដុតបាយស៊ី គ្នាមានអុសឯណាកាលនឹង ផ្ទះណាចាស់ៗរុះទាំងអស់នឹងហើយ ។

ដានី ៖ បារពើកនៅកប់ស្រូវ?

ដេត ៖ បាទ! អាបឹងនឹងហើយ ក្រោយក-១០ក្រោយភូមិចាមនឹងហើយតាមបណ្តោយប្រឡាយ ។ ដល់ពេលគ្នាចាប់ផ្តើមជិះប្រឡែងគ្នាដូចកូនក្មេងណា ធម្មតាគ្នាក្មេងមានអាយុប៉ុន្មាន អាយុត្រឹម ២០ឯាយអី វានៅនេះដែរ ២១ ២២ទើបក្រោយ ចេះធ្វើការងារមិនបាច់អ្នកណាដាស់តឿនអី ។ ដល់ពេលមកប្រជុំ ល្ងាចមកប្រជុំ អាពួកនឹងលើកមតិកសាងកំចាត់ទស្សនះនាម៉ឺននិយមបុណ្យសក្តិនេះ ច្បាប់បញ្ជានិយមនឹង ហើយទៅឈរ ដែលខំទៅធ្វើការ ហើយយើងអួតទស្សនះអញ្ចឹងៗ មេបញ្ជាទៅឈរបញ្ជាឈរអញ្ចឹងអានឹងវាប៉ះគេនឹងហើយ ។ ដល់ពេលប្រជុំគេមានមតិ គេលើកមកគេចង្អុរមក«អ្នកទាំងអស់គ្នាដឹងទេ ដឹងខ្លួនស្អីទេ ស្អីចង់ទាមទារសិទ្ធិសេរីភាពអី ចង់ទាមទារដែលស្អី ខ្ពុរ៩៥ភាគរយនៅតែតាពកមួយទេ ដែលអត់ក្បត់» ។ អញ្ចឹងបានសេចក្តីថា យើងដឹងកំហុសខ្លួនយើងថា ជាខ្សែចសង្វាក់បក្សពួកបាត់ហើយ គេចោទប្រកាន់ បានសេចក្តីថា ជារឿងមួយមេក្បត់អញ្ចឹង ចង់និយាយថាម៉ាខ្សែនឹងវាត្រូវកំទេចចោលទាំងអស់ ។ បានថាគេមិនទាន់កំទេច អញ្ចឹងរឿងគេទៅជាអញ្ចឹងហើយ ។

ដានី ៖ ពីណាមកប្រជុំនិយាយអញ្ចឹង?

ដេត ៖ តាស៊ុម ដែលប្រធានមន្ទីរ ស៊ុមនឹងប្រធានមន្ទីរក-១០នៅនឹងហើយ ។

ដានី ៖ មិនមែនតារិទ្ធិទេ?

ដេត ៖ មិនមែនតារិទ្ធិទេ អានឹងដល់ពេលមកចូលកងមន្ទីរក-១០នឹង វាចូលក្នុងក្រសួង៨៧០ហើយក្នុងការគ្រប់គ្រងរបស់តាប៉ង់ តាព្រហ្ម តាកឺ ។

ដានី ៖ ម៉ាក-១០នៅក្នុងក្រសួង?

ដេត ៖ ៨៧០ ។

ដានី ៖ ៨៧០ នៅកន្លែងណា?

ដេត ៖ បាទ! ៨៧០ អានឹងជាប់ប៉ុលពតម៉ង ។

ដានី ៖ ប៉ុននៅណា?

ដេត ៖ កន្លែងគេ អត់ដឹងនៅណាទេ ខ្ញុំមិនដឹងដែរ ប៉ុនដឹងថាកន្លែងការងារក្រសួង៨៧០ គ្រប់គ្រង ដែលខាងផ្នែកក ប មន្ទីរមានមន្ទីរប មន្ទីរក មន្ទីរអីនឹងអានឹងលើពួកនឹងហើយ ។

ដានី ៖ លើពួក៨៧០ ?

ដេត ៖ បាទ!

ដានី ៖ មិនមែនពួកការបរទេសទេ?

ដេត ៖ អានឹងនៅក្រោមការគ្រប់គ្រងទាំងអស់ អានឹងនៅនែន!របស់គាប៉ុនៗនឹង ។

ដានី ៖ ស្គាល់គាប៉ុនដែរ?

ដេត ៖ ស្គាល់ ដល់ពេលក្រោយមកទៀតមក ស្ថានការណ៍រួចម៉ាសារនឹងទៅនាំគ្នាស្ងាត់ទៅ ហើយ បាននិយាយណែនាំពីអាម៉ីៗ បារាំង អញ្ចឹងម៉ែវាជាជនបារាំង ។

ដានី ៖ ឪពុក?

ដេត ៖ ឪពុកវាខ្មែរ ហើយពុកវានឹងវាហាក់ដូចជាជាប់ដែល ។

ដានី ៖ ពុកឈ្មោះអី ពុក?

ដេត ៖ ខ្ញុំភ្លេចឈ្មោះវា ឈ្មោះអីទេ ។

ដានី ៖ មិនមែនឈ្មោះសុគឿនទេ?

ដេត ៖ ហ៊ើ! ខ្ញុំភ្លេចឈ្មោះហ៎យ ខ្ញុំចាំបែបចំណាំគានឹងល្អិតដែរទេ ។

ដានី ៖ ធ្វើការនៅណា?

ដេត ៖ ធ្វើការនៅពាណិជ្ជកម្មនឹងដែរ ។

ដានី ៖ ពាណិជ្ជកម្មដែរ?

ដេត ៖ បាទ! នៅពាណិជ្ជកម្មជំនាន់នឹង គាត់នៅធ្វើនៅពាណិជ្ជកម្មនឹង ប៉ុនគាត់នៅបុយរ៉ូ ។

ដានី ៖ ម៉ីនឹង គាត់មានឈ្មោះដើមគេអី?

ដេត ៖ ខ្ញុំអត់យល់ ប៉ុនខ្ញុំហៅអាម៉ីៗនឹង អាម៉ីនឹងអញ្ចឹងវានៅស្រុកបារាំង វាទើបនឹងមកៗមិនទាន់ បានប៉ុន្មានផង ហើយដល់ពេលមានសភាពការណ៍អញ្ចឹងទៅ ឪពុកវាគេចាប់យកទៅបាត់ ហើយមិនដឹងគេដកមកនៅធ្វើកម្មករជាមួយខ្ញុំ ។ ហើយបញ្ជូនមកៗជាមួយគ្នាដែរ ហើយខ្ញុំ ចេះតែណែនាំវា វាចេះតែទាមទារថា“សុំធ្វើរបាយការណ៍ទៅបក្ស រាយការណ៍ទៅអ៊ីៗ” ថា “មិនបាច់រាយទេ សរសេរទៅក៏មិនដល់ដែរ” ។

ដានី ៖  ម៉េចអញ្ចឹង ម៉េចបានគាត់ចង់វាយការណ៍ទៅ?

ដេត ៖  គាត់ថា«មើលទៅភាពប្រក្រតីខុសគ្នារវាងការខាងលើអប់រំផ្សេង  អាអ្នកអនុវត្តឯក្រោមវាផ្សេង»។

ដានី ៖  អញ្ចឹងគាត់ធ្លាប់ បានន័យថាយ៉ាងម៉េចបានគាត់ដឹងថាការអប់រំពីលើមក?

ដេត ៖  ហើយបើខ្ញុំធម្មតាការដែលនិយាយពេលដែលរៀនៗនិយាយពីរឿងការអប់រំកុំធ្វើយ៉ាងនេះៗ អី  ប៉ុនវាអត់គិតថាខ្លួនវាដែលគេចាត់ទុកថាមនុស្សជាប់និន្នាការ  មនុស្សដែលទើបនឹងមកពីបរទេស គេវាយតម្លៃយើងម៉េច វាអត់ដឹងចំនុចនឹង។

ដានី ៖  អញ្ចឹងគាត់ចង់វាយការណ៍ទៅខាងណា?

ដេត ៖  ចង់ទៅវាយការណ៍ទៅ។

ដានី ៖  វាយការណ៍ឲ្យពីណាគេ?

ដេត ៖  វាយការណ៍ ដូចថាទៅនួន ជា លោកប៉ុល ពតនឹង ហើយធ្វើម៉េចឲ្យបានសំបុត្រឲ្យដល់ខៀវសំផន ដល់នួន ជា ដល់ប៉ុល ពត។ ខ្ញុំថា«មិនបាច់វាយទេ ជួនកាលដល់ទៅ ជួនកាលមិនដល់ ហើយយើងជួនកាលមិនដឹងយ៉ាងម៉េចផង មិនបាច់វាយ»។ វាចេះតែទទូច ប្រាប់ខ្ញុំជិតរាល់ថ្ងៃថា«ឯងជនជាតិបារាំង ហើយខ្មែរមែន ប៉ុនមកពីបារាំងទេ បើឯងសរសេរមិនស្រួលឯងត្រូវងាប់ហើយ» វាអត់ជឿ។

ដានី ៖  កាលនឹងមុីនឹងស្គាល់នួន ជា ស្គាល់?

ដេត ៖  បាទ!វាថាវាបានទៅរៀន ការវាមកពីបរទេសនឹង វានៅក្រសួងការបរទេសដែរនឹង ក្រោយមកបានគេដកមក។

ដានី ៖  គាត់មាននិយាយប្រាប់រឿងថាគាត់ធ្លាប់រៀនជាមួយអុំ?

ដេត ៖  អឺ! គេហៅជារួម ឧទាហរណ៍ថាម៉ាខែកន្លះខែអី អុំៗនឹងពួកដែលនួន ជានឹង ឯងហៅទៅរៀននៅស្តារចាស់ គេហៅបុរីកីឡាកន្លែងនេះ ឲ្យរៀននៅនឹងរៀនគ្រប់អង្គភាពទៅចេះតែរៀនទៅរៀនពន្យល់ពីរឿងនយោបាយរឹងគ្រប់គ្រងផ្នែកនយោបាយ  ចងក្រងកុំឲ្យសតិអារម្មណ៍គេឯងតែងធ្វើអញ្ចឹងឯង។

ដានី ៖  ពូធ្លាប់ទៅរៀនជាមួយនួន ជាដែរ?

ដេត ៖  ខ្ញុំទៅ ខ្ញុំរៀនបានម៉ាសារដែរ ប៉ុនលក្ខណៈទៅរៀនបុកពោះដែរនឹង ឧទាហរណ៍បុកពោះម៉េចក៏យើងទៅឃើញស្ថានភាពអត់មានអំណោយ  ដូចជាខ្ញុំនឹងឧទាហរណ៍ថា  ខ្ញុំជាប្រធានកងមួយហើយ  នឹងអ្នកនឹងឧទាហរណ៍ថាពេលដែលយើងត្រូវការធ្វើការងារ  ជួនកាលអ្នកខ្លះទំរន់មែនហើយអញ្ចឹងយើងក្នុងនាមជាប្រធានកងយើងត្រូវអប់រំគេហើយ  អ្នកឯងកុំទំរន់ពេល ថ្ងៃណា

ឈឺគេវាល់ថ្ងៃៗ បើមិនឈឺ យើងឈឺតែឯង ហើយឈឺៗនឹងចូលលក្ខណៈនេះនឹង ឈឺធាត់អាដែលអត់នេះ វាអត់ហេតុផលខ្លាំង អញ្ចឹងគួរតែពង្រឹងស្មារតីខ្លួនយើងនឹង អប់រំខ្លួនយើងនឹងធ្វើការជាមួយនឹងគេនឹងឯង កុំឲ្យខុសឃ្លានឆ្ងាយពីគេពេក ។ ហើយដល់ពេលយើងនិយាយគោលការណ៍នឹង គេថាយើងគៀបសង្កត់ទេ ។

ដានី : ចុះកាលទៅរៀននឹង នួន ជាគាត់ទៅបង្រៀនម្នាក់ឯង ឬក៏មានអ្នកផ្សេងទៅជាមួយគាត់?

ដេត : មានកងការពារម្នាក់គេឈរអែបខាងបន្ទប់គាត់ គ្មានអ្នកច្រើនទេ ។

ដានី : បង្រៀនគ្នាច្រើន?

ដេត : មួងទៅមួង៥០-១០០នាក់ ។

ដានី : ម៉ាខែមួង?

ដេត : បាទ! ម៉ាខែមួងៗ ។

ដានី : មុីនឹងក៏គាត់ធ្លាប់ទៅរៀននឹងដែរ?

ដេត : ទៅរៀននឹងដែរ ប៉ុនវាមានវគ្គខុសៗគ្នា អញ្ចឹងទទួលការអប់រំចេញពីថ្នាក់ដឹកនាំអញ្ចឹង កន្លងមកច្រើនតែអញ្ចឹងពីណាដូចពីណាដែរ ។

ដានី : ដល់មុីធ្លាប់រៀនទៅ?

ដេត : គាត់វិភាគដែលនយោបាយនៃការរៀននឹង វាខុសពីការប្រព្រឹត្តថ្នាក់ក្រោម អញ្ចឹងទទួលការអប់រំចេញពីថ្នាក់ដឹកនាំអញ្ចឹង កន្លងមកច្រើនតែអញ្ចឹង ពីណាដូចពីណាដែរ ។

ដានី : ដល់ពេលខ្មែរយើងធ្លាប់រៀនទៅ?

ដេត : គាត់វិភាគនយោការរៀន វាខុសពីការប្រព្រឹត្តខាងក្រោមនេះ អញ្ចឹងគាត់ឃើញថា«ខ្ញុំសួរឯងចាំបាច់រៀន» «អឺ!គាត់ផ្ដាំហើយ គាត់ថាទៅកន្លែងណាក៏ដោយ ករណីធ្វើមិនតាមមាគ៌ា តាមការណែនាំ ដែលបំភ្លឺមាគ៌ា បំភ្លឺពីឯកសារ និយាយពីលក្ខន្តិកៈស្ដីពីការណែនាំ ត្រូវតែរាយការណ៍» ហើយវាខុសៗហើយ ប៉ុនគ្រាន់ថាខ្ញុំថា«ទៅរាយម៉េច ចេះទៅរាយៗនាំតែនេះទេ» ប្រាប់វាអត់ស្ដាប់ ។ អញ្ចឹងដល់ក្រោយមក វាលួចសរសេរ ផ្ញើតាមគេ សរសេររួចខ្ញុំឲ្យតម្លៃថាឯង៣ថ្ងៃទៀតងាប់ហើយ ។

ដានី : ចុះពូបានមេលក្រដាសដែលគាត់?

ដេត : អត់ទេ វាអត់ឲ្យមើលផង ប៉ុនវាបាននិយាជាមួយខ្ញុំ វាថា«វាអត់និយាយអីទេ និយាយគ្រាន់ថាត្រូវកែទម្រង់នយោបាយនៃការគ្រប់គ្រង» ហើយបើធ្វើតែអញ្ចឹងយកមនុស្ស គេធ្វើតែខ្លួនវានឹង ឪវាអត់មានកំហុសមែន អញ្ចឹងយកវាមកលុតដំ មើលទៅមនុស្សរាប់ពាន់នាក់ អញ្ចឹង

វាសរសេរប្រៀបធៀប អញ្ចឹងវាប៉ះគេបាត់ហើយ ។ ហើយអញ្ចឹងធ្វើឲ្យមានបញ្ហានឹងហើយ អញ្ចឹងប្រហែលសរសេរទៅខុស អត់មានទាមទារកើតទេ ដំណាក់កាលនេះ ។

ដានី : ឆ្នាំណាដែលគាត់សរសេរ ឆ្នាំខែ ពូមានចាំទេ?

ដេត : ខែវស្សាៗ ប៉ុនខែប៉ុន្មានៗ៧៧ ចុង៧៧ ខ្ទង់ខែ៨-៩ បើ៩-១០តាមមើល ។

ដានី : ហើយគាត់សរសេរហើយ គាត់ផ្ញើតាមណា គាត់យកទៅខ្លួនគាត់ឬយ៉ាងម៉េច?

ដេត : ផ្ញើនឹងគេ គាត់ដើរលេងមកជួប ពេលថ្ងៃល្ងាចអញ្ចឹងដើរលេងមកជួបនឹងឲ្យគេទៅ ។

ដានី : ឲ្យពីណា?

ដេត : ថាឲ្យឈ្មោះតាហុងៗ មិនដឹងពីណា ខ្ញុំអត់ស្គាល់ដែរ ។

ដានី : តាហុង?

ដេត : បាទ! គាត់ថា«ខ្ញុំធ្លាប់ស្គាល់តាហុង ឲ្យតាហុងនឹងឯងយកទៅ» ។

ដានី : តាហុងគាត់ធ្វើអី?

ដេត : តាហុងនឹងអត់ដឹងដែរ ប៉ុននៅកន្លែងក្រសួងការបរទេស ប៉ុនមិនដឹងជាក្របខ័ណ្ឌគេធ្វើអី ប៉ុន នៅកន្លែង ។

ដានី : មើលទៅតាហុង គាត់កម្មាភិបាលថ្នាក់ធំដែរ?

ដេត : កម្មាភិបាលដែរនឹងជំនាន់នឹង តែខ្ញុំអត់ស្គាល់ថាតើ ។

ដានី : ប៉ុនដែលឃើញមុខតាហុងនឹងអត់?

ដេត : អត់ដែលឃើញផង ប៉ុនគាត់ប្រាប់ច្បាស់លាស់ថាធ្លាប់នៅជាមួយ ។

ដានី : ម៉ីនឹងប្រាប់ថាផ្ញើនៅតាហុង?

ដេត : បាទ! អញ្ចឹងផ្ញើទៅក៏វា តាំងពីនឹងមកបានប្រាប់ ផ្ញើរួចអត់ប្រាប់ខ្ញុំទេ ប្រាប់ថា«ម៉ីឯងខុស ហើយ អ្នកអត់ដឹងពីស្ថានការណ៍យ៉ាងម៉េចចេះតែផ្ញើ ហើយអត់ដែលមើលរឿងចារកម្មទេ អត់ដែលមើលរឿងល្បិចកល» ជួនកាលគេឲ្យយើងអនុវត្ត យើងចេះតែដាក់អញ្ចឹង ប៉ុនដល់ពេលយើងទៅ ដឹងថាអានេះមួយប្រតិកម្មហើយ មិនតាមគេ អានឹងមួយ ពីរ អានឹងសុទ្ធតែមេយើងវាល្អ មេយើងអាក្រក់គេថាយើងប្រតិកម្មអីមួយហើយអញ្ចឹងចោទ ហើយមួយទៀត ពេលដែលយកទៅនឹងវាមកដល់នឹងវាប៉ះអាខ្សែណាមួយទៀត មិនដឹងខ្សែអីខ្លះ ។ អញ្ចឹងបាន ខ្ញុំប្រាប់គ្នាវាថា«អញរត់ឆ្ងកាត់ដោយសារអាគេចោទប្រកាន់នឹង៣-៤ដងហើយ ប៉ុនក្រយៅ អញអត់ងាប់ ព្រោះអញឆ្លងកាត់ អញប៉ះគេ២-៣សារហើយ អារឿងគេនេះនឹង រឿង អញទៅប៉ោយប៉ែតម៉ាសារ អញរត់ចេញកាលនៅកំពង់ធំម៉ាសារ អញ្ចឹងពិនិត្យទៅយើង ឃើញសភាពការណ៍វាអត់ល្អទេ ហើយខ្មែរក្រហមៗដឹងអាណាខ្លះ អាខ្លះមិនមែនខ្មែរក្រហម

ជនទីនឹង ខ្ញុំថាអញ្ចឹងឯង មិនដឹងអាណាពិតប្រាកដជនទីនឹង មិនដឹងគណបក្សប៉ុន្មាននៅក្នុងនឹង ហើយគ្រប់គ្រងឲ្យបានអាមេៗលាក់មុខ" ។

ដានី : មេលាក់មុខម៉េច?

ដេត : មេកម្របញ្ចញមុខជួប អាដែល ។

ដានី : កាលជំនាន់នឹងអត់ចេញមុខទេ?

ដេត : អត់សូវចេញទេ ចេញតែអាក្រោមៗ អញ្ចឹងវាថាអានឹងហើយវាលំបាក ។

ដានី : កាលជំនាន់បលពត អត់សូវបង្ហាញមុខ បង្ហាញមាត់ទេ?

ដេត : អត់ទេ បង្ហាញតែប្រជុំមួយភ្លេត អញ្ចឹងបានខ្ញុំឃើញអាពេលប្រកាស ហើយខ្ញុំដឹងមួយទៀត គេសំឡុតខ្ញុំ ខ្ញុំនិយាយរំលងកាលខួប អឺ!បុណ្យខួបលើកទី២៨ កាលនឹងមានការបោះឆ្នោត ។

ដានី : បុណ្យខួបលើកទីប៉ុន្មាន?

ដេត : ២៨ ។

ដានី : បុណ្យខួបអីគេ?

ដេត : បុណ្យខួបបក្សលើកទី២៨ ការបោះឆ្នោតខ្ញុំនៅកំពង់សោម កាលនោះខ្ញុំមានការលើកទស្សនៈ នេះទស្សនៈការបោះឆ្នោតយ៉ាងម៉េច ខ្ញុំនិយាយទៅរៀងឆ្គង គេសំឡុតខ្ញុំវិញ ដឹងអត់ស្រួល អត់ហ៊ានមាត់ទេ ។ ខ្ញុំថា«បោះឆ្នោតឲ្យតែមនុស្សនេះទេ ប៉ុនដល់ពេលរួចទៅបានជាប់អ្នកនោះ គេតែងតាំង អញ្ចឹងបានលទ្ធិប្រជាធិបតេយ្យអ្វីៗគឺមេអ្នកសម្រេច អីៗយើងត្រឹមតែឯកភាព តាមក្រោយអញ្ចឹងយករូបភាពនឹងរកលទ្ធិប្រជាធិបតេយ្យ ។ អញ្ចឹងយើងឃើញសភាពការណ៍ អញ្ចឹង មិនបាច់មាត់អីច្រើន ដូចតែដើងមុនអញ្ចឹងធ្វើចូលកងទ័ពអ្នកក្រីក្រ កងទ័ពអស់ ប្រជាជនអស់ចូលមកសម្រាប់ឲ្យសម្ដេចឪមកវិញ ស្រាប់តែគេចូលមកទីក្រុងចប់គេបំបែរមកមាន ណារឿងវេទ្យង មានអ្នកណាហ៊ានមាត់ ។

ដានី : ចុះម៉ីនឹង ដល់ពេលគាត់ធ្វើសំបុត្រហើយ ម៉េចទៀតសកម្មភាពនឹង?

ដេត : សកម្មភាពនឹង ធ្វើសំបុត្រហើយ ក្រោយមក៣ថ្ងៃគេយកទៅបាត់ទៅ យកគ្នាទៅបាត់ទៅ ។

ដានី : ពេលយកនឹងយ៉ាងម៉េច?

ដេត : ពេលយកឡានអាហ្សីពមួយ អាហ្សីពស័រឃ្មប់ ដឹងពីណានៅភ្នំពេញដឹងថាមីង ខាំមី ។

ដានី : ឈ្មោះអីគេ?

ដេត : ឈ្មោះ ខាំមី ។

ដានី : ខាំមី ម៉េចទៅ?

ដេត : ខាំមីនឹងជនជាតិ ។

ដានី : ជនជាតិអីគេ?

ដេត : ជនជាតិអីទេ ប៉ុនមិនដឹងជនជាតិអីទេ ប៉ុនដឹងមកពីរតនគិរី មណ្ឌលគិរី ។

ដានី : គាត់នឹងធ្វើអី?

ដេត : គាត់នឹងនៅកន្លែងសម្រាប់សន្តិសុខនៅភ្នំពេញតែម៉ង ។

ដានី : សន្តិសុខអីគេនៅភ្នំពេញ?

ដេត : អត់យល់ដែរ កាលនឹងយើងមិនបាន គេមិនបានប្រកាសថាអាណាស្អី១ណាទេ ប៉ុនថាគាត់សម្រាប់ការងារនៅជុំកន្លែងប៉ុលពតនឹង ប៉ុនគ្រាន់ដឹងថាមានមេដឹកនាំដំណាក់ប៉ុន្មានទៀត យើងមិនដឹង ។

ដានី : ឈ្មោះខាំមី?

ដេត : បាទ! ខាំមី មកយកព្រោះខ្ញុំស្គាល់ ខ្ញុំជូនមីនឹងទៅដល់ឡាននឹងម៉ង ខ្ញុំស្គាល់ៗខាំមីនឹងឯងហើយ ខាំមីនឹងមិនមែនខ្ញុំទើបនឹងស្គាល់ទេ ខ្ញុំស្គាល់តាំងពីឆ្នាំ៧២ ។

ដានី : នៅរស់អត់ ខាំមីនឹង?

ដេត : អត់ដឹង មិនដឹងរឿងអីទេ អានឹងមិនរស់ ។

ដានី : ប៉ុនមី មុននឹងឡើងឡានទៅ គាត់ដឹងថាគេចាប់គាត់?

ដេត : ដឹង ។

ដានី : មាននិយាយអីខ្លះជាមួយពូ?

ដេត : ពេលដែលនែក!ទៅនឹង ថ្ងៃនឹងទៅហូបបាយ ខ្ញុំឃើញឡានមកថាឡាននឹងមកយកអ្នកណាអ្នកណែទៀតហើយ ព្រោះឡាននឹងដឹងថាមកដឹងថាយកហើយ យកខាងពីណាមិនខានទេ ឲ្យតែយកទៅដឹងថាបាត់ហើយ ថាថ្ងៃនឹងដើរទៅហូបបាយ ខ្ញុំក៏ឃើញ ខ្ញុំដើរក្រោយទៀត ឃើញឡាននឹងមកដល់ ។ មកដល់ខ្ញុំក៏អង្គុយហូបបាយជិតគ្នា ម៉ែចស៊ីបាយឆ្អែតហើយ "ចុះម៉ែចអញ្ចឹង" វានិយាយប៉ែឡាំហើយថា"ឯងសរសេរសំបុត្រថ្ងៃមុន គេមកយក ឯងមើលបើមិនជឿ" ហើយខ្ញុំក៏អត់ទាន់ដឹងថាខ្លួនឯងថានឹងវាត្រូវដែរ អត់ដឹងថាវាប្រាប់លេង អ្នកជិតស្និតជាមួយគ្នាចេះតែថា ។ ដល់ពេលដល់ហូបបាយរួច ប្រធានមន្ទីរហៅខ្ញុំទៅ "ដេតឯងទៅប្រជុំប្រាប់មីឲ្យរៀបចំអីវ៉ាន់ឡានគេចាំ" រួចប្រាប់មីឡានគេចាំទៅយកអីវ៉ាន់ហើយជួយកាន់មានអីខ្លះ ជួយកាន់ឡើងឡានទៅៗបាត់ទៅ ។ គ្រាន់ខ្ញុំមកប្រាប់ថា"នែក!រើយ កុំឆ្លើយប្រាប់គ្នាចេះចោះអីម៉ែចៗងាប់តែឯងបានហើយ គិចថាអញជួយមតិអី ជួយថាចេះចុះ គេសួរថាក្នុងអង្គភាពនឹង តើកន្លងមកមានគំនិតដូចឯងប៉ុន្មាននាក់ មានគំនិតយ៉ាងម៉េចៗអីយ៉ាងម៉េចគិចថាខ្ញុំប្រុងមានគេប្រាប់ថា គេមិនឲ្យសរសេរដែលចេះចុះ ងាប់អញហើយណា" ខ្ញុំចេះរាយ

ការណ៍វិញថា«អត់អីទេ សុខចិត្តស៊ាប់តែឯង ស៊ាប់ក៏ស៊ាប់ទៅខ្ញុំស្មោះបក្ស» ។ ទៅក៏ស្ងាត់ឈឹងទៅ ។

ដានី : ទៅជាមួយខាំមីនឹង?

ដេត : បែបគ្នាគេ២-៣នាក់ ឯកសណ្ឋានយោធា ។

ដានី : ខាំមី ២នាក់ទៀតពូស្គាល់ដែរអត់ បើឡានអា?

ដេត : ហ្វូពស័រ ឃុប គេដាក់ដំបូលក្រណាត់ រុំឃ្លុបជិត ហើយតែឃើញឡាននឹងហើយញាក់សាច់ដឹងថាចាប់ហើយ ។

ដានី : កាលនឹងពីណាគេអ្នកមកហៅៗពូទៅប្រាប់ឲ្យហៅម៉ី?

ដេត : តាស៊ីម ។

ដានី : តាស៊ីម?

ដេត : បាទ!

ដានី : ចុះកាលនឹងម៉េចបានពូដឹងថាគេមានចាប់ មានសួរចម្លើយរកខ្សែ រកអី ពូដឹងមកពីណា?

ដេត : នែក! ការពិតអាចាប់ហើយសួររកខ្សែអីនឹង ពួកយើងដឹងរៀនពីនយោបាយ រៀនទៅយើងយល់ ពួកធម្មតាកាលនោះយើងរៀន យើងទៅបែកគំនិតខ្លួនយើងអាចសន្និដ្ឋានបាន ព្រោះបានថាចុះចាប់ បើមកអញ្ចឹងគេយកទៅបាត់អញ្ចឹង ហើយយើងនឹកឃើញគិតហើយ ហើយគេប្រជុំគេនិយាយហើយនឹង បើយើងវិភាគអាគេចង្អុលអ្នកឯកចង់ទាមទារស្អី ចង់រកសិទ្ធិសេរីភាពអី ដឹងខ្លួនឯងមកម៉េចទេ មកទៅដក ខ្លួនឯងមកពីមុនដែលមានកម្លាំងប៉ុន្មានជាប់នឹងខ្លួនឥឡូវមានកម្លាំងស្អី ។ អញ្ចឹងក្នុងនាមមករាល់ថ្ងៃនេះ មកលុតដំនឹងមកឯងធ្វើអីទៀត នៅមិនដឹងខ្លួនទៀត ។ ដល់ពេលអញ្ចឹងគេចាប់ខ្សែអត់មានពិបាកអីទេ ។

ដានី : កាលនឹងដឹងថាកន្លែងគេចាប់គេនឹង គេចាប់យកទៅដាក់កន្លែងណាៗ?

ដេត : អតដឹង អត់ទាន់ដឹងទេ ហើយក្រោយមកទៀត អាយប់ចាប់គាត់នឹងបានប៉ុន្មាន ក្រោយមកអញ្ចឹងវាអស់៣ហើយណា អស់ដែលជិះក្របីចំលងភក់ អញ្ចឹងគេប្រជុំគេថា«ម៉េចប្រៀបធៀបដូចយើងជិះក្របីចំលងភក់ម៉េច» ប្រៀបធៀបទៅនយោបាយ ការពិតខ្ញុំមិនដឹងអីសោះនឹង ។

ដានី : គ្នាជិះកគ្នាលេងសោះ?

ដេត : គ្នាជិះកលេងសោះ កើតរឿង ។

ដានី : ថាយើងជិះជាន់កម្លាំង?

ដេត ៖ ថាយើងឈឺ យើងយកវាមកជិះក្របីចំលងភក់ ប្រៀបធៀបរឿងនយោបាយ វាចប់ត្រឹមនឹងឯង ។ ហើយដល់ពេលក្រោយមកទៀតមក បានខ្ញុំទៅផ្លាស់ចេញពីនឹងមក គេចោទអារឿងវ័គ្គរស្រូវ អញ្ចឹងគេរកគន្លឹះម៉េចដកពួកខ្ញុំមកទៀតមក មកនៅព្រៃ-២៨ទៀត ព្រៃ-២៨សំរោង តាទងនេះ ជិតបិទធ្នូ ភូមិ៥៨ ត្រូវបង២០ បង១៧ អានឹងពីមុនកន្លែងនឹងកន្លែងប៉ុស្តិ៍វិទ្យុចាស់កន្លែងនេះ អាព្រៃៗម្តុំកន្លែងជំនាន់កាលខ្មែរក្រហមមិនទាន់ឈ្មោះភ្នំពេញ មានប៉ុស្តិ៍វិទ្យុនៅនឹង ប៉ុលពតនៅនឹង ព្រៃ ។

ដានី ៖ នៅបិទធ្នូ នៅសំរោងទង?

ដេត ៖ អាព្រៃធំយើងមកពីគគីរតាំងរាជ មកពីនេះមកដូវនឹងឯង ។

ដានី ៖ ចុះកាលពីល្ងាចមិញ ពូជម្រាបប្រាប់ខ្ញុំថាដូចធ្លាប់ធ្វើការនៅកន្លែងណា ជួបខៀវ សំផនគាត់បើកឡាន?

ដេត ៖ អឺ! នៅកន្លែងក-១០នឹងឯង អាកន្លែងក-១០ចាប់ពួកនឹងអស់ទៅនឹង ដល់អញ្ចឹងខ្ញុំជួបលោកខៀវ សំផននឹង កាលនឹងគេឲ្យកាប់ថ្នល់ អញ្ចឹងមានម៉ាស៊ីនធំមួយសម្រាប់បង្ហូរទឹកនឹងមកធ្វើស្រែនៅក្រោយនោះ អញ្ចឹងលូមុខប៉ុន្មានតឹកចង់កន្លះម៉ែត្រដែក លើកដែកកប់ចាក់កៅស៊ូអីវិញ ចាក់ខ្លួនឯងអីខ្លួនឯងកៅស៊ូក្នុងនេះនឹងគេយកមកឲ្យចាក់ ។ ចាក់ហើយដឹកអមថ្នលនេះ មកទម្លាក់ប្រឡាយនេះ ហើយដល់ពេលនេះទៅដូចថ្ងៃល្ងាចដែរ ខៀវ សំផនមកឈប់ៗសួរខ្ញុំថា«មិត្តគេធ្វើអី?» ថា«គេឲ្យដឹកប្រឡាយសម្រាប់បូមទឹកនឹងមកសម្រាប់បង្ហូរចូលស្រះនោះ» ហើយគាត់សន្និដ្ឋានហ្នឹងៗបន្តថា«ចិត្តខ្ញុំ ខ្ញុំមិនឲ្យធ្វើអញ្ចឹងទេ យើងកាត់តែថ្នល់ចេះបានន័យថាបូមទម្លាក់អញ្ចឹងទៅ ហើយអានឹងបង្ហូរចូលទៅបានហើយ បើយើងបង្ហូរថ្នល់នេះទៀត វាកាប់កងនឹងឡានបើកធូន់ផង រាប់គោនអញ្ចឹងអង្គើលៗទៅ ទោះជាខ្ញុំចាក់ស៊ីម៉ង់យ៉ាងម៉េចក៏ដោយ វានៅតែអង្គើលដែរ បើវាលូគួរសមតិច បើយើងចាក់នេះអញ្ចឹង វាអត់ល្អទេ វានាំឲ្យរង្គើលទៅនាំប្រេះថ្នល់ខូច ។ កាលធ្វើនឹង គេមានអប់រំឲ្យគេមានប្រជុំអី និយាយអីពិគ្រោះយោបល់ទេ?» ថា«ទេ! អត់ទេ បើពិគ្រោះយោបល់ម៉េច បើខ្ញុំគេចាត់ទុកឲ្យខ្ញុំលុតដីអ៊ំ» «អឺ!គេដកមិត្តពីណាមក?» «ដកចេញពីក្រសួងពាណិជ្ជកម្ម មកធ្វើការនៅនឹង» «អញ្ចឹង?» គាត់ដូចស្រឡាំងកាំងហើយណា ហាក់បីដូចជាគាត់អត់ដឹងម៉េចទេ ហើយថា«ពីណាប្រធានអ្នកណា?» ខ្ញុំថា«តាស៊ុម ប្រធាននឹង» គាត់ក៏«អត់អីទេ ធ្វើគេឲ្យធ្វើទៅ» ក៏បានប៉ុន្មានថ្ងៃបានដកតាស៊ុមនឹងចេញ ។ ដកតាស៊ុមនឹងចេញបាត់ទៅ អត់បានដល់ម៉ាអាទិត្យផង ខ្ញុំបុកពោះដែរ លរ!ថាឯងរាយការណ៍ចេះចុះ ខ្សែគេនោះលេងឯងទៀតនោះ តែបុកពោះ ដល់ពេលនោតទៀតទៅ បានដូរតាភឿននឹងមក ។ តាភឿននឹងមកៗដល់គាត់សួរដូចពី

រឿងខ្ញុំប្រាប់មិញ សួរតាភឿនមិញខ្ញុំនិយាយតាគីមិនមែនតាគី តាភឿន ខ្ញុំនឹកឃើញហើយ តាភឿននឹងគាត់សួរពីរឿងហូបបាយហូបអី ខ្ញុំថា«ហូបបាយអត់ឆ្អែតទេ» «យើងធ្វើម៉េចឲ្យហូបបាយឆ្អែត? ដឹងធ្វើម៉េចបើអង្គការកំណត់ម៉ាកំប៉ុងៗអញ្ចឹង ម៉ាកំប៉ុងចំហ៊ុយសណ្តែក» ខ្ញុំថា«បើសិនជាហូបបាយខ្វះរួមទាំងអស់គ្នា វាល្អជាង ព្រោះកន្លែងយើងវាមានអ្នកធ្វើការធ្ងន់ អ្នកធ្វើការស្រាល អញ្ចឹងអ្នកធ្វើការធ្ងន់ អ្នកធ្វើការស្រាលវាជិតប្រហែលគ្នាដែរ អ្នកធ្វើការស្រាលនឹងវាជិតនឹងប្រហែលអាធ្ងន់ដែរនឹង បើសិនជាយើងដាំទៅ វាអាចលាយឡំបាន ព្រោះកន្លងមកខ្ញុំឃើញអា» ។

## កាសែ្សតទី២

### ផ្នែក«ក»

ដេត ៖ បើទៅជុំគ្នាល្អ ខ្ញុំថាបើយកល្អសាកមើលសិនទៅ គាត់សាកៗមើលប្រជុំថាចាំថ្ងៃអាទិត្យយើងសម្រាក ល្ងាចថ្ងៃសៅរ៍សម្រាកយើងប្រជុំ មើលឯកភាពគ្នាមើល សាកមើល បើសិនធ្វើដូចគាត់រៀងល្អដែរ មតិគាត់ ថាហើយគាត់អនុវត្តទៅ ល្អតាំងពីនឹងមកគឺបាយឆ្អែតគ្រប់គ្នាៗ ព្រោះដាតអាអ្នកនេះដឹកនឹងមកជាមួយគ្នា ហូបបាយបានទាំងអស់គ្នា ខាងនោះវាអត់ខ្វះម្ហូបដែរទេ ប៉ុនអត់មានបន្លែអីទេ សុទ្ធតែត្រកួនភាគច្រើនៗ ត្រីយើងចិញ្ចឹមបានៗ ប៉ុនមាន់អីនឹងដែលយើងចិញ្ចឹមបាន អណ្តើកចិញ្ចឹមអីអញ្ចឹងសម្រាបលក់ទៅឲ្យគេទេ ពួកយើងនឹងអត់បានហូបទេ អ្នកចិញ្ចឹមនឹងសម្រាប់យកមាន់អាពងមាន់យកអីនឹង យកទៅកន្លែងផ្សារអន្តរជាតិសម្រាប់លក់ឲ្យស្ថានទូត កន្លែងនឹងសម្រាប់លក់ឲ្យពួកនឹងទេៗ ឯបន្លែអីដែលល្អៗនេះបាន ក៏សម្រាប់យកទៅលក់ទៅកន្លែងយកទៅឲ្យលក់នៅទីផ្សារ ម្រាប់លក់ស្ថានទូតគេទិញផ្សារថ្មីនឹងឯពួកខ្ញុំអីនឹងស៊ីត្រកួនព្រលិតៗ ហើយយប់ឡើងនាំគ្នារែកណ្តុរបាន ក៏គេឆាកណ្តុរម៉ាឆ្នាំងៗ ចុះគ្នារាប់រយនាក់ កណ្តុរម៉ាធុនៗប៉ុនៗនេះៗ ច្រើនណាស់ ម្នាក់១០ ១៥ ២០ គ្រប់ៗគ្នា មនុស្សរាប់រយហើយ ដល់ពេលអ្នកបកពន្លាត់វិញចិញ្ច្រាំឡើងម៉ាធុនៗប៉ុននេះ នាំគ្នាស៊ីកណ្តុរនឹងហើយ ។ ខ្ញុំហ៊ានស៊ីជិនាន់នឹងដែរ មុនដែលហ៊ានស៊ី ។

ដានី ៖ កណ្តុរស្រែ?

ដេត ៖ អើ! កណ្តុរស្រែនឹងៗ ហើយពេលក្រោយមកទៀត ខ្ញុំបានគេដកមកបង្អត់បាយស៊ីរហូតទៅនៅវាលឌីក... ស៊ឹងត្រង់ ។

ដានី ៖ ដកទាំងអស់គ្នាមក?

ដេត ៖ បាទ!ដកពួកខ្ញុំៗ ដកតែម៉ាក្រុមពួកខ្ញុំទេ ពួកពាណិជ្ជកម្ម ។ មកៗប៉ះឃើញសុទ្ធតែពួកពេទ្យដែលកេតុមាលា ពួកនារីៗយកមកមុនខ្ញុំម៉ាឆុលទៀត មកមុនប្រហែលបាន២-៣ថ្ងៃ ។

ដានី : ពេទ្យ៦មកពីនឹង?

ដេត : ពេទ្យកេតុមាលា មិនដឹងអ្នកណាគេ ។

ដានី : ពេទ្យកេតុមាលានឹង គេប្រាប់ថាដកទៅណា?

ដេត : គេដកទៅនៅជាមួយខ្ញុំដែរ សុទ្ធតែស្រីៗ ។

ដានី : ប៉ុន្មានៗនាក់?

ដេត : អឺយ៉ាស! ច្រើនណាស់ ខ្ញុំមិនបានចាំទេ ហើយខ្លះទៀតពេទ្យនៅកំពង់សោម ខ្លះទៀត ហើយ សរុបទៅសុទ្ធតែខត្តរៗទាំងអស់ ។

ដានី : ខត្តរទាំងអស់?

ដេត : បាទ! មានកំពង់ចាម កំពង់ធំ សៀមរាបៗ មានតែ៣ខេត្តនឹងទៅជុំជើងគ្នា ។

ដានី : ពេលដែលគេដកទៅខាងកំពង់ចាម ខាងស៊ឹងត្រង់គេប្រាប់ដែលថាយើងដកទៅខាងនឹងអត់?

ដេត : គេអត់ប្រាប់ទេ គេអត់មានប្រជុំប្រាប់ គ្រាន់ផ្លាស់ មិនដឹងផ្លាស់ទៅណាទេ បុកពោះដែរនោះ មិនដឹងយកទៅណាទេ យកវ៉ែបណ្ដែតទឹកចោលណា ក៏នាំគ្នាមក ដល់ពេលគេឲ្យមកនៅនឹងគេ ឆែក ព្រឹកឡើងគេអឺវែអឺវ៉ាន់ចេញអស់រលីងទៅ គេប្រគល់ចបឲ្យកាប់ដីដាំនឹងគេទៅ កំពុងគិត ហើយយើងវ៉ៃចោលថ្ងៃណាទេ នឹកឃើញកាប់ដាំដំឡូង ។

ដានី : ដាំនៅណា?

ដេត : នៅភូមិ៥៨ នៅជិត៥៨ហៅប-២០ ហៅប-២០ត្រង់នឹង នៅភូមិ៥៨ឯខ្លួយ អឺនែក!បិទ ធ្លូ ម៉ាផ្លូវបិទធ្លូយើងនេះនឹង ទៅសួរភូមិ៥៨ជិតនឹងសួរអ្នកស្រុកដឹងកន្លែងនឹងគេស្គាល់ កន្លែង មន្ទីរប-២០ ប-១៧ ប-១៨ ។

ដានី : ពីណាគេគ្រប់គ្រងនៅនឹង?

ដេត : នែក! ឈ្មោះតាហង់ៗ ប៉ុនតាមានដឹងទៅណាកាលនឹងមិនទាន់សភាពការណ៍៧៩ គ្រាន់សភាព ការណ៍វ៉ៃគ្នាទុងទាំងគាត់រត់តែម៉ាក្រុមគ្នាគេនឹងចេញបាត់អត់មាននៅ ។ ដល់ពេលនៅតែពួក យើងនៅនោះ ។

ដានី : ចុះកាលពូទៅនឹងបានរយៈពេលប៉ុន្មានខែបានបែក៧៩?

ដេត : យូរដែរ ម៉ាឆ្នាំជាង ទៅនៅនឹង ចេញពីនឹងបានមកនៅដីថ្មីនេះ ម៉ាវស្សាជិតម៉ាប្រាំងទៀត បានបកទៅនឹងវិញ បានកើតព្រឹត្តិការណ៍៧៩ចូល ។

ដានី : ទៅនៅនឹងធ្វើអីខ្លះ ធ្វើស្រែ?

ដេត : ធ្វើតែស្រែ ប៉ុននៅកន្លែងនោះ កន្លះខែ ឬម៉ាខែគេដក៤-៥ ១០អានឹងឈ្មោះគេចេញពី ភ្នំពេញទៅ ។

ដានី ៖ ទៅពីភ្នំពេញទៅ?

ដេត ៖ បាទ! ចេញពីភ្នំពេញទៅ ។ ហើយខ្ញុំនៅពេលដែលសភាពការណ៍ដែលពួកក្រសួង៨៧០គេចេញ អានេះមួយថា«ឈប់ចោទប្រកាន់មនុស្សថ្មីចាស់» បានមួយនោះនិយាយប្រាប់ខ្ញុំឈ្មោះអាភឿន១មួយវានៅគ្រប់គ្រងពីលើខ្ញុំនឹង «អឺ!ដេត១ឯង» វាក្មេងជាងខ្ញុំ វាថា«អឺ! ដេតឯងអាយុវែងណាស់» «វែងម៉េច» «អឺ!គ្រាន់តែចេញពីភ្នំពេញ៤ដងហើយ គេយកដេតឯងទៅវៃចោល» «ប៉ុនពួកខ្ញុំនៅនឹងអ្នកធ្វើការជុំគ្នានេះ ចេះថាហ៎!នៅក្មេងអញ្ចឹង ហើយម៉ាកន្លែងនឹង ធ្វើការតែវាខ្លាំងជាងគេ ហើយធ្វើការអត់ចេះ ធ្វើការគ្មានចេះខ្ជិល មិនដែលឈឺមិនដែលអី មើលអត្តចរិត មើលបុកពាមិនសំងំក្បត់ យកទៅវៃចោល ទុក១ចេះតែទុកទៅរួចខ្លួនហើយ»

ដានី ៖ អញ្ចឹង?

ដេត ៖ បាទ!

ដានី ៖ មានគេចុចមកភ្នំពេញទៅ?

ដេត ៖ បាទ! គេចុចពីភ្នំពេញទៅ ។

ដានី ៖ មកប៉ុន្មានដង ៤ដង?

ដេត ៖ ៤ដង១ ។

ដានី ៖ ប៉ុន្តែឈ្មោះភឿននឹងអ្នកទុក ហើយព់ណាអ្នកទុក?

ដេត ៖ នែក! ពួកមន្ទីរគេនឹង មិនមែនភឿនទេ បែបភឿនគេដឹងរឿង ព្រោះខ្សែគ្នាគេនៅក្នុងមន្ទីរគេនឹង ។

ដានី ៖ មន្ទីរនឹងពីណាគេប្រធាន?

ដេត ៖ នែក! កាលនោះតាកេងពីលើ ឈ្មោះកេង ។

ដានី ៖ គាត់នៅដែរអត់?

ដេត ៖ តាកេងនឹង អត់ដឹងដែរ ដឹងនៅដឹងអត់ បាត់មិនដឹងនៅណា អញ្ចឹងគាត់នឹងកអត់ដែលប្រាប់ខ្ញុំដែរ ប៉ុនតាភឿននឹងប្រាប់ខ្ញុំនឹងណា មកប្រាប់ថា«ដេតអើយ! គេប្រុងយកដេតឯងទៅវៃចោលប៉ុន្មានសារហើយ តែគេគិតថាដេតឯងក្មេងគេពេក» អញ្ចឹងយើងមើលឃើញថាវាអត់អីហើយណា វាចេះតែរួចហើយទៅ ។ ដល់ពេល៧៩មក គេបែកបាក់គ្នាអស់ទៅ ប៉ុនវាអាភឿននឹង ក្រោយមកដែលរត់៧៩នឹង ប្រាប់ឃើញរត់ចេញពីនឹងមកក៏ស្លាប់ដែរ នែក! វៀតណាមបាញ់ផាប់បាត់ដែរ បាញ់ផាប់បាត់ទៅ នែក!រត់បានបែកគ្នាអាមកជាមួយខ្ញុំសួរវាផាប់ ។ ហើយវាប្រាប់ម៉ាចំនុចទៀត វាថា«នែក!ពួកមេ១អស់នឹងអត់ហ៊ាននៅជិតដេតឯងទេ

ដែលដល់ពេលអញ្ចឹងបានគេនាំគ្នារត់ដោយឡែកនឹង គេខ្លាចពួកដេតឯងខឹង» ថា«អឺ!ល្មមដែរនឹងធ្វើបាបគ្នា គេចោទគ្នាៗខំចង់សាប់ហើយមិនដឹងស្អីផង» ។

ដានី : ពួកមេៗនឹងអ្នកនៅខត្តរដែរ ឬក៏អ្នកមកពីណាវិញ?

ដេត : អត់ទេ សុទ្ធតែពួកជនជាតិទាំងអស់ ។

ដានី : ជនជាតិណា?

ដេត : ពួកមកពីរតនគិរី មណ្ឌលគិរី ហើយនឹងពួកព្រះវិហារ ។

ដានី : អញ្ចឹង?

ដេត : បាទ! មានប៉ុននឹង កម្លាំងមូលដ្ឋានពួកជុំវិញ ភាគច្រើនៗពួកនឹងគេយក អាណាកសិករអ្នកនេះ ចំនុចនឹងពួកនឹងធ្វើការងារអត់បេះឈប់ទេ ទាំងពលកម្ម អញ្ចឹងគេស្រឡាញ់ពលកម្មសម្រាប់ប្រើយើង ហើយគេប្រាប់ថា«ថ្ងៃមុនតាកេងនឹងមកប្រាប់វា តាកេងថាភ្ញាក់ខ្លួនដែរប៉ុលពតហៅទៅសួរ ប៉ុនកាលនោះគេមិនហៅប៉ុលពតទេ គេហៅអុំ អុំប៉ុលហៅទៅសួរថាកម្លាំងប៉ុនប៉ុន្មានពាន់ដែលទៅនៅនឹង ឥឡូវនៅសល់ប៉ុន្មាន» «អឺ!កម្លាំងគគោកទៅណាអស់» «អឺ! បញ្ជារចេញសំបុត្រនេះមកពីតាប៉ងទៅថា កំទេចចោលៗម៉ាថ្ងៃ តិចឃើញសំបុត្រទៅកំទេចឈ្មោះនេះ ឃើញសំបុត្រទៅកំទេចឈ្មោះនោះ អញ្ចឹងហាក់ដូចក្នុងបញ្ជីគេមាន» ហើយគាត់ថា បានខាងនោះឆ្គួត អត់មានមកប្រាប់គេ គេអត់មានបញ្ជាឲ្យវ៉ៃបេះតែវ៉ៃតាមគេទៅកើតរឿងបេះតែភ័យខ្លួនអញ្ចឹងទៅ ។ អញ្ចឹងតាកេងនឹងអត់សួរនៅ កាលនោះអត់សួរនៅមន្ទីរដល់ពេលដឹងសភាពការណ៍អញ្ចឹង គាត់ងាកចេញចូលភ្នំពេញៗ សភាពការណ៍បេះតែបត់ទៅកាលនោះ ផ្ទៃក្នុងបេះតែរង្គើលហើយ ។

ដានី : អញ្ចឹងអ្នកដែលទៅនៅនោះមិនមែននៅកងភូមិភាគខត្តរទេ មិនមែននៅភូមិភាគកណ្ដាលទេ?

ដេត : អត់ទេ នៅក្នុងក្រសួង៨៧០គ្រប់គ្រងដដែល ក្រសួង៨៧០ទៀតអានឹង បើក្នុងមន្ទីរអានឹងនៅក្រោមបញ្ជារបស់ក្រសួង៨៧០ម៉ង អត់មានទៅក្ដាប់ក្នុងតំបន់ ឬមួយនេះ អានឹងហៅថាមន្ទីរមជ្ឈឹមម៉ង ហើយកន្លែងនឹងកន្លែងលុតដំសព្វគ្រប់ ។

ដានី : ចុះតាបងគាត់បញ្ជារហូតដល់៧៩?

ដេត : បាទ! រហូតដល់នឹងដែរ ហើយក្រោយមកអាចបែកការណ៍ត្រឹមបាត់កម្លាំងអីចុះឡើង អានឹងអាចៗបាត់ខ្លួនទៀតទៅ មិនដឹងគេយកទៅវ៉ៃចោល អាចកំហុសអីយ៉ាងណាយើងមិនដឹងតាមដាន ។

ដានី : ចុះក្រោយពីតាប៉ង់ មានពីណាទៀត?

ដេត : ក្រោយនឹងមកអត់ដឹងទេ លែងដឹងហើយ ។

ដានី : ចុះខ្មៀន?

ដេត : ខ្មៀន ហ៉ើ!ខ្មៀនៗនឹងនៅខគួរទេ នៅអាដែលតាខ្មៀននឹងចំការកៅស៊ូ អានឹងអត់មានពាក់ព័ន្ធជាមួយពួកនឹងទេ អត់មានពួកនឹងទេ ។

ដានី : អញ្ចឹងពេលដែលយើងផ្លាស់ទៅនៅស៊ឹងត្រង់ ទៅនៅអីនឹងក៏មិនមែនភូមិភាគកណ្តាល កែ ពក គ្រប់គ្រងអត់ទេ?

ដេត : អត់ៗទេ ។

ដានី : ចុះពូដូចកាលដំបូងមិននៅកន្លែងពាណិជ្ជកម្មៗ ពេលដែលគេលុតដំគេបញ្ជូលទៅខាង?

ដេត : អានឹងចូលក្នុងក្រសួង៨៧០ហើយ ។

ដានី : ចូលមកក្រសួង៨៧០ លែងនៅក្រោម?

ដេត : លែងនៅក្រោមពាណិជ្ជកម្មទៀតហើយ អាត្រឹមលុតដំនឹង កន្លែងនឹងឈប់ហើយ ។ អញ្ចឹងដូចអានៅគុកទួលស្លែង អានៅមន្ទីរអី អានឹងសុទ្ធតែក្រសួង៨៧០ ។

ដានី : ទួលស្លែងនឹង?

ដេត : បាទ! ទួលសែងសុទ្ធតែក្រសួង៨៧០ទាំងអស់នឹង ។

ដានី : ចុះម៉េចពូដឹងថារបស់៨៧០ ?

ដេត : ហ្នឹងបើគេប្រជុំមេៗ ដឹងខ្ញុំលបគេស្តាប់និយាយព្ទ ពួកនឹងគ្រប់គ្រងអត់អស់ ។

ដានី : ពួកនឹងដឹងទាំងអស់ដឹងថានៅទួលស្លែង៨៧០ ?

ដេត : បាទ! ដឹង ។

ដានី : មេណា ពូដូចស្តាប់ព្ទពីណានិយាយថាទួលស្លែងក្រោម៨៧០ ?

ដេត : នែក! បានព្ទពួកដែល ប្រុង ខ្ញុំទៅអង្គុយប្រាជ្ញជាមួយពួកប្រធានមន្ទីរអី តាភឿនអីគាត់និយាយណា គេថា«យើងកន្លែងលុតដំយើង អាដែលដកគ្រប់អង្គភាពមកដាក់មើលទៅអត់មានកន្លែងនៅ គេរាប់ឲ្យទួលស្លែងអញ្ចឹងចេះនៅៗ ដើងឯក នៅក-១០ ហើយគេថាមន្ទីរនេះនឹង»

ដានី : មន្ទីរណា?

ដេត : មន្ទីរមកបងដេត បងដានហើយណា គ្នាខ្ញុំនៅធំៗនៅកន្លែងនឹងឯង ហើយខុសពីនឹងពួកយោធាគេច្រើនបញ្ជូនមកធ្វើអាដែងនេះ ព្រលានយន្តហោះកំពង់ឆ្នាំង ។ អញ្ចឹងយោធាគេដកមកផ្សេង កាលណាឯងពួកនៅជុំវិញក្រសួងនៅក្នុងម្តុំនឹងគេចាប់ ។ ខ្ញុំព្ទតាមគេ ព្រោះយើងដឹងថាមេគ្រប់គ្រងចេញចូលអញ្ចឹង ដូនកាលគេថានែក!យើងនៅជិតគេអញ្ចឹង “គ្នាអត់បាននែក!គេហៅទៅធ្វើការនែក!ទួលស្លែងតិច” អញ្ចឹងយើងដឹងក្នុងចង្កោមនឹងហើយ ទាល់តែគេ

និយាយមកយើងយល់ហើយ យើងមិនបាច់គេប្រាប់ក៏យើងដឹងដែរ ។ ហើយដល់ពេលនេះទៅសភាពការណ៍៧៩នឹង ខ្ញុំអត់រត់ទៅណាចេះតែនៅៗនឹងទៅ ទៅជួបជាមួយគាជុំចៅហ្វាយស្រុកនឹង ។

ដានី : ចៅហ្វាយស្រុកណា?

ដេត : ចៅហ្វាយស្រុកត្រពាំងប្រាសាទនឹងណា ទៅជួបប្រជុំចៅហ្វាយស្រុកនឹងថាមិនបាច់ទៅណាទេ ទៅគ្មានអ្នកណាគេគិតពីរឿងអញ្ចឹងទៀតទេ ក៏នៅៗចេះតែនៅជាមួយគាត់ នៅៗទៅ ។

ដានី : ពេលបែក ពេលដែលគេជ្រួលច្របល់៧៩?

ដេត : បាទ! ច្របូកច្របល់៧៩ នៅក៏នៅនឹងរហូតទាល់តែឡើងភ្នំមក ។

ដានី : អញ្ចឹងពេលបែក៧៩ ម៉េច បានពូអត់ៗត្រឡប់មកផ្ទះ?

ដេត : ខ្ញុំគិតថាត្រឡប់មកផ្ទះមិនដឹងទៅអី ខ្មាសគេ កាលនោះណា ។

ដានី : ខ្មាសគេម៉េច?

ដេត : ខ្មាសគេ ចង់និយាយថាយើងពុកម្ដាយកាលចេញមកពុកម្ដាយមិនពេញចិត្តទេ ហើយអញ្ចឹងនឹកឃើញថាទៅផ្ទះខ្មិល កុំឲ្យឪពុកម្ដាយបន្ទោសគាណាគត់គាណែងតែខ្លួនឯង ធ្វើម៉េចតាមដំណើរដែរ កុំឲ្យពេលរួចទៅរត់ទៅរកឪពុកម្ដាយវិញ គាំងចិត្តថាមិនទៅម៉ង ចិត្ត ហើយមួយទៀត កាលនោះយើងដេកគិតវិភាគម៉ង យើងមើលទៅឃួនៗចូលស្រុកនឹង ឃើញថាក៏វាមានអាទស្សនៈនឹងមួយទប់ណា ទៅចិត្តមួយនឹកទីង ឃើញថាយើងខំធ្វើការ ខំអី គេចោទថាយើងខ្មាំង ចោទយើងក្បត់ ចោទយើងសេ.អ៊ី.អា ចោទយើងខ្សែក្បត់ចេះចោះ ទស្សនៈមានទីង ប៉ុនគ្រាន់ដូចវាទស្សនៈមួយគិតឃើញថាវៀតណាមមកព្រោងប្រៀបទៅ យើងនឹកឃើញអារម្មណ៍មួយអត់ខ្មិលនៅតស៊ូ ទៅផ្ទះក៏ខ្មាស់គេដែរ អញ្ចឹងចេះតែនៅៗក៏ឡើងមកលើភ្នំនឹងមក ។

ដានី : មកនៅភ្នំណា?

ដេត : នៅភ្នំដងរែក នៅភ្នំ៣ ហើយពេលដែលមកនឹង និយាយពីម្នាក់ៗដើរអើយ!ដាច់ជើង ហើមជើង ហើមដៃអស់ហើយ១ខែ ដើរពីនឹងមក ។

ដានី : ដើរពីស្ទឹងត្រង់មក?

ដេត : បាទ! ដើរពីចំនុចនឹងមក ពីដែលប-២០នឹង ចេញពីប-២០ ។

ដានី : ទាំងអស់គ្នា ចូលទៅទាំងអស់គ្នា?

ដេត : បាទ!

ដានី : អត់មានពីណាចេញ អត់មានពីណាត្រឡប់មកផ្ទះ?

ជេត ៖ បាត់គ្នាដែរ ម៉ាពួកវ៉ូងរត់ខ្ចោចខ្ចីបែកគ្នាទៅ រួចទៅមិនដឹងទៅណាមកណា នាំគ្នាមកនៅអញ្ចឹងវិញទៅៗ អញ្ចឹងអាក្នុងឆ្នាំ៧៩នឹង ដែលរត់ទៅ មិននៅនឹងរបូតទេ មកដល់ព្រៃ មកដល់ទីតាំងរៀន មកដល់ពួកដែលពួកទៅភ្នំជីនឹង ទៅនឹងទៅអត់បាយស៊ីទៅក៏រកអង្ករអត់បាយស៊ី រកអីមិនបានៗ បង្វិលទៅកន្លែងនឹងវិញកន្លែងនឹងសំបូរដំឡូង គាស់ដំឡូង គាស់អី ស៊ីចេកទៅអត់មានអីកាលនោះស៊ីតែចេក ខ្នុរ អាខ្នុរអាផ្លែវាយកមកស្ងោរស៊ី អាគ្រាប់វាយកមកស្ងោរស៊ី អាក្លែបវាអាខ្ចីៗស្ងោរហើយពួកខ្ញុំដាក់អន្ទាក់ជ្រូកបាន បានសាច់ជ្រូកទេយោងៗ អញ្ចឹងហូបអានឹងឯង ម៉ាថ្ងៃ១ៗសាច់ជ្រូកពួកខ្ញុំហូបៗ ហើយក៏ខ្ញុំមានក្របីមានអីនឹង ធ្វើស្រែនឹងពេលដល់យួនឡើងមកអញ្ចឹងទៅនាំគ្នាចូលព្រៃ យួនដើរអញ្ចឹងទៅ យកក្របី ជ្រូកទៅអស់ធ្វើស្រែទៀតទៅៗ ហើយដល់ពេលច្រូតៗយប់ៗបោកបែនរួចយកស្រូវលាក់ទុកក្នុងព្រៃៗខ្ញុំថាតាមផ្លូវនៅអាព្រៃបន្ទាស្អិតនឹង នៅក្នុងព្រៃនឹង ដងស្ងោរដល់ដឹងថាកាលនោះមានប្រជាជនគាត់ទៅកាប់ទៅរកដំឡូងនោះ កំពុងពេញអត់ហើយណា គាត់ទៅរកដំឡូង គាត់ទៅរកចេកអីនឹង គាត់ថា«អូ!ក្មួយអើយ កូនអើយយកប្រហុកទៅ ត្រីឆ្អៀត ត្រីឆ្អើរ គាត់យកមកយកស្ករយកអីណា ហើយទៅឲ្យគាត់ទៅ យកគាត់យកអំបិលមកឲ្យទៅណា ហើយគាត់សុំចូលកាប់នេះ មានមីនមានអីដែរ ឲ្យគាត់ចូលកាប់យកចេក យកខ្នុរ យកដូចដំឡូងទៅវិញទៅហើយយើងយកប្រហុកអំបិលតិចតួចនឹងយកមក ជួនកាលពួកគាត់វេចអង្ករទៅឲ្យទៅ អញ្ចឹងវាផ្លាស់ប្តូរផលិតផលគ្នាៗ

ដានី ៖ នៅម្តុំណានឹង?

ជេត ៖ នៅម៉ាផ្លូវនឹង ម៉ាផ្លូវខ្លួយចំណាប់ ខ្វីម៉ាផ្លូវទាំងអស់ ពេលនៅនឹងអញ្ចឹងទៅ នែក!បានប៉ុន្មានត្រូវឡើងមកភ្នំនឹង ហើយម៉ាសារនឹងត្រូវអត់បាយហូបហើយ អញ្ចឹងយើងចេះតែរត់នៅនឹងទៅៗ ដល់ពេលឡើងមកនេះ បានខ្ញុំនិយាយមកដល់លើភ្នំនឹងបានបែកគា បានគេរៀបចំកងអន្តរាគមន៍៩៨០នេះបានគេដកៗ អញ្ចឹងពីនឹងមកគេចូលបង្កើតកងពលហើយ បានខ្ញុំនៅប្រែកនែក!ប៉ុន្មាន៦១២នៅម៉ាផ្លូវប៉ុលព្រិចទៅ ៦១៦ចាប់ពីត្រឹមព្រះវិហារនេះផ្លូវតាដាក់តាមបន្ទាយមកនេះៗ មកខាងនេះទៀត ដឹងកងណា ខ្ញុំអត់សូវស្គាល់ដែរទេ ដឹងថាពួកតាទីងតាហឿនណាទេ នៅ៨៨៨ ត្រឹមដាំនេះទៅ ត្រឹមនេះទៅ៦១៦ៗ

ដានី ៖ ពូនៅកងប៉ុន្មាន?

ជេត ៖ ខ្ញុំកាលនោះគេចូល៦១៦ៗ

ដានី ៖ ពីណាគេនឹង?

ដេត : កងពលតាញ៉ានៗហ្នឹងហើយ ដល់ពេលក្រោយមកបានបំបែកចេញពីនឹងមក មកបង្កើត៩៨០ ដែលដកមាស ម៉ុតៗមកពីលិចមកៗគ្រប់គ្រងអានឹងជាមួយតាថិនៗផ្នែកយោធា ទាល់តែនេះនឹងនយោបាយ តាមុតនយោបាយ ទើបឲ្យរៀបចំសម្រាប់ចុះសង្កេតសកម្មភាពយើងសៀមរាបនឹង ចុះសកម្មភាពសៀមរាបនឹង ហើយដល់ទៅបានមានវរសេនាធំប៉ុន្មាននោះ វរសេនាធំ៩១ ៩២ ៩៣ ៩៤ ក្រោយមកបានពួកទន្លេ ពួកអាដែលកំពង់ឆ្នាំងនោះមកម៉ាក្រុមទៀតមក បានបង្កើតវរសេនាធំទៀត៩៥ បានយើងបានមកនៅនឹងៗ ពេលនៅនឹង ខ្ញុំនេះហើយមកនៅនឹង ដល់ពេលតាម៉ុតមកអត់មានកម្លាំងក៏គេរុញខ្ញុំនេះឲ្យនេះ ប៉ុនការពិតខ្ញុំមកនេះអត់មានអ្នកណាចាត់តាំងទេ ខ្ញុំរត់ទេ កាលនោះខ្ញុំត្រូវឈរជើងនៅភ្នំទ្រព្យនៅប្រាសាទព្រះវិហារ កងខ្ញុំតាំងពីគេដកកម្លាំងពាក់កណ្តាលអញ្ចឹងមក នៅសល់ពាកកណ្តាល អញ្ចឹងគេដកមេឆ្លាស់ៗគ្នាណា អញ្ចឹងកន្លែងខ្លះគេត្រូវការអនុជាមួយប្រធានក្រុមឡើងថ្មីទៀត រៀបចំកម្លាំងឡើងថ្មីទៀត ដល់ពេលខ្ញុំក្រុគេនិយាយ ខ្ញុំមកប៉ះមេៗនិយាយគ្នា គេចាត់ឲ្យខ្ញុំឡើងអនុ កាលនោះខ្ញុំប្រធានក្រុមហើយ ប្រធានក្រុមខាងកាំភ្លើងធំ កាលនោះខ្ញុំនៅខាងឌូវិត គ្រាប់ឌូវិតបាញ់អាកាមភ្លើង១២ ម៉ាក្រុម១២នាក់លីអាឌូវិតនឹង បាញ់ប្រាសាទព្រះវិហារត្រង់ៗ

ដានី : បាញ់ប្រាសាទ?

ដេត : បាទ! យួនមើលទៅឃើញធ្លាប់ឃើញបាញ់ឯងម៉ាថ្ងៃ៧-៨ធំៗ

ដានី : បាញ់ទៅលើប្រាសាទ យួននៅលើប្រាសាទ?

ដេត : បាទ! ឃើញគ្រឡុកកោះនេះឯង ឆ្នុះពីនេះទៅឃើញច្បាស់បេះនឹងបេះតែបាញ់ហើយ ខ្ញុំដុំគ្រាប់វាប៉ើង ខ្មាំងមាននេះ អាជាយឃើញកន្លែងហាត់នោះឯង ហើយរួចទៅដើរបាញ់តាមពើងនោះ តាមពើងភ្នំៗ អញ្ចឹងដើរធ្វើការទៅ មើលទៅឃើញ រៀបចំបាញ់កន្លែងប្រទាញគ្នា លីតែបាញ់នឹងម៉ាថ្ងៃៗ ហើយដល់ពេលរួចទៅ អាគេដកមក គេនិយាយគ្នាថា តាឆាន់ថា "ឲ្យអាដេតទៅវាឡើងអនុសេនាតូចទៅព្រោះវាសកម្មការងារ" ផ្អើលដល់តាភាពកងពលគេថា អឺ! គាត់រងកងពលគេ មិនរងទេ មេកងពល១ប៉ុនមិនដឹងមេប៉ុន្មាន មិនទាន់ចាត់តាំងស្រួលបួល គ្រាន់ដងមេកងពលពីដើមមកគាត់នឹង គាត់ថា "ហ៎! កុំអាលឲ្យវាអីអានឹងនោះ អានឹងជាប់និន្នាការនយោបាយ វាទើបនឹងចេញពីកន្លែងគុកនឹង កុំអាលទុកចិត្តប្រគល់អីធំដុំវា ខ្ញុំនឹកឃើញអន់ចិត្តអញ្ចឹងរត់បណ្តោយណា ប្តូអញ្ចឹងអង្រឹងមួយ កៅស៊ូមួយ ខ្ចប់មី២-៣កញ្ចប់មកដើរមកអំពិល៣ដើមតែឯងដេកតាមនឹងឯង យប់ឡើងទាល់ម៉ោង១០បានខ្ញុំដេក ដើរតាំងពីម៉ោង៦ ម៉ោង១០បានខ្ញុំដេក ចេញមកពីនឹងទៀតមកដល់១០០៣នេះ ១០០៣កន្លែងតាម៉ុកនៅ ជិតកន្លែងតាម៉ុកនៅ មានប្រជាជនទ័ពគេមកផ្តុំគ្នារៀបចំកងពលថ្មីនឹង ជុំគ្នាវ៉ៃនឹងឯង

បេះដើរលេងនឹងគេ ដើរៗទៅទៅជួបអាគ្នាឯងធ្លាប់ស្គាល់ជំនាន់វ៉ៃនៅភ្នំពេញនឹង ក៏ស្គាល់គ្នា អញ្ចឹងទៅថា"ឯងនៅណា?" "អញបេះ អត់មានដេកកងណា ដឹងនៅណា អញខ្ជិល ចង់ធ្វើប្រជាជន ចង់ឈប់ធ្វើអីហើយ រស់នៅប្រជាជនគេហើយ បេះធ្វើអីហើយ ព្រោះបេះតែទាញចុះទាញឡើងនៅនេះនោះ" មិនទាន់ថានៅផង ស្រាប់ដល់ពេលរួចទៅអាឡេងនឹងវាស្គាល់គ្នា អាឡេងជាមួយខ្ញុំ ប៉ុនវាងាប់បាត់ហើយថា"ឯងមកនៅជាមួយអញៗប្រធានកងពិសេសនៅវរសេនាធំ៩៣ គេចាត់តាំងហើយ វរសេនាធំ៩៣ ហើយគេរៀបរយនេះហើយស្អែកខាងស្អែកគេប្រកាសហើយ ឯងមិនបាច់ទៅនានៅជាមួយអញ" ។ ក៏មិនទាន់ថានៅដែរ បេះតែទៅៗដល់ដេកបាន២យប់ បានតាប៉ុមនេះ តាមប៉ុមកងពល ចាត់តាំងឲ្យខ្ញុំមកនៅជាមួយតាមុតនឹងទៅ ក៏នៅជាប់ជាមួយគាត់ទៅ ។ គាត់ឲ្យបង្រៀនកេងៗ រើសក្មេងៗវ៉ៃទូរលេខ បង្រៀនចុចទូរលេខ កាលនោះប្រើតេអូអា២វ៉ាត់ ។

ដានី : បេះទូរលេខដែរ?

ដេត : ខ្ញុំបេះដែរ បេះទាំងបកក៏ខ្ញុំបេះ ។

ដានី : បេះពីអង្កាល់មក?

ដេត : បេះនៅឆ្នាំ បង្កើត៩៨០នោះ ៩៨០នោះកងពលនឹងកើតខែ៩ឆ្នាំ៨០ អញ្ចឹងគេដាក់៩៨០ទៅ ដល់ពេល៧៨៥ ខែ៧ឆ្នាំ៨៥ អញ្ចឹងគេបង្កើតនេះដាក់អញ្ចឹងហើយ អាកងពល២នឹងគេដាក់ឆ្នាំខែនឹងមក ។ ហើយពេលនឹងបង្កើត ខ្ញុំបេះតាំងពីនឹងមក ខ្ញុំរៀនបណ្តើរបង្ហាត់ ការពិតមានអាឡឿនមួយ អាឡឿនងាប់បាត់ហើយ បង្រៀនខ្ញុំនឹង ។ ហើយប្រើខ្ញុំឲ្យគ្រប់គ្រងកន្លែងនឹង បង្រៀនហើយខ្ញុំក៏គ្រប់គ្រងតទៅ បង្រៀនទៅបេះៗទៅតៗគ្នាទៅ ។ ដល់ពេលរៀនដូចខ្ញុំថាអញ្ចឹរៀនកន្លងមក ខ្វះក្រដាស ខ្វះអី អត់មានអីគ្រប់គ្រាន់សរសេរនឹងស្លឹកឈើម្តងសរសេរដៃខ្មៅ បន្ទាប់ពីសរសេរដៃខ្មៅ សរសេរប៊ិចខៀវ ឈប់សរសេរប៊ិចខៀវទៅសរសេរប៊ិចក្រហម ។ អពាំងក្រដាសមួយទម្រាំបានបោលនោះ ទាល់តែអក្សរ២-៣នោះទម្រាំមើលស្គាល់ពាដង អញ្ចឹងវាដៃខ្មៅ ដល់ពេលយើងលុបដៃខ្មៅដល់សរសេរប៊ិចខៀវវានៅមើលឃើញទៀតទេ អញ្ចឹងដាក់សរសេរប៊ិចក្រហមមួយទៀតយើងនៅមើលឃើញ យើងកត់តែលេខ ដល់ពេលចប់អានឹងមកក្រោយមកទៀត បានគេចប់អស់ហើយ ខ្ញុំនៅបង្រៀនតែ៨០ ផ្លាស់កន្លែង៨០នៅនឹង ។ ឯនឹងបានតាម៉ុកមកជដែកបង្កើតកងពល៩៥មួយទៀតកងពល៩៥ ព្រោះកាលមុនវាមាន៩១ ៩២ ៩៣ ៩៤ ៩៥ ៩៤កងដឹកជញ្ជូន ដល់៩៥នឹងកងពួកមកពូទន្លេសាបថ្មី ពួកតាប៉ុលនោះ ។ ដល់ពេលមកបង្កើតនៅនឹង៨០នឹងបានហៅខ្ញុំទៅសុំក្រដាសគាត់ៗធ្វើបាបខ្ញុំណាស់កាលនោះ គាត់អត់មានទិញក្រដាសអីឲ្យ គាត់ថា"ឯង

មិនរក» ខ្ញុំថា«អឺ!ខ្ញុំគិតអស់ហើយ ខ្ញុំមិនដឹងទៅរកឯងណាទេ ឃើញកង់ទ័ពគេបើកមី យកឡាំងមីបើកចានយកអានឹងមកសរសេរ ឡាំងត្រីខនឹងហែកសរសេរបង្រៀន មិនដឹងច្នៃប្រឌិតពីណាទៀត ហួសពីនឹងថាយកស្លឹកខ្នុងមកសរសេរ ធ្វើម៉េចឲ្យរៀនចាំវៃឲ្យស្ទាត់ៗ ដល់ពេលរួចទៅ គាត់ថា«ឯងទៅមើលនោះ ក្រដាសអញទុកនោះ» ខ្ញុំស្មានក្រដាសគាត់ទុកមែនដឹងក្រដាស«ក្រដាសអញទុកគិតអាចន៍នឹង» គាត់យកអាក្រដាសបែកចានបែកឆ្នាំងគេ អាក្រដាសទ្រាប់ឆ្នាំងចាននឹង ដល់ពេលថា«មានតែក្រដាសគតអាចន៍» «អឺ!អានឹងហើយយកមក» ខ្ញុំយកមកគាត់សើច ហាស់ៗ ថាលេងដល់ហើយ នឹកឃើញហើយៗ រួចហើយបានគាត់តេគាត់ឲ្យគេវៃទូរលេខទៅផ្ញើពីថៃមកបាន៤-៥រ៉ាម បាននៅនឹងទៅៗ ដល់ពេលក្រោយពីនឹងមកបានខ្ញុំនេះ តិចទៅនៅកងនេះតិច កងនោះតិច ព្រោះតាម៉ុតគាត់ចាត់ទុកថាខ្ញុំជាកន្លែងទូរលេខរួម អញ្ចឹងកងណាខ្វះទៅនៅកងនោះបានមួយខែពីរខែទៅ នៅកងនោះទៅៗ អញ្ចឹងវាអត់អន្តភាពអី នៅកន្លែងកងពល៩៨០នឹងហើយ ការគ្រប់គ្រងរបស់គាត់នឹងៗ ដល់ពេលក្រោយមកទៀត គាត់ឲ្យខ្ញុំទៅនៅនេះនោះ បង្កើត៧៨៥ៗខ្ញុំទៅនៅទន្លេ ខ្ញុំទៅនៅម៉ាជួរព្រៃកំពីឮយ កំពើកឮយក្បែរម្នាងបឹងរាជុះដាង ទៅខ្សែនោះជិតប៉ុលតូចនោះ ទៅនៅនឹងខ្ញុំទូរលេខមួយចាំយាមគ្រាប់ៗដឹកជញ្ជូនខែវស្សាអីនឹង មកគរនៅនឹង ខែប្រាំងគរ ខែវស្សាយើងបណ្ដែតទូកនៅជុំវិញនឹង ដាក់មីនអត់ឲ្យចូលទេ អត់ឲ្យប្រជាជនចូលទៅ យើងនៅនឹងៗ អញ្ចឹងជំនាន់នឹង បាត់ងាប់ភ័យ អ្នកខ្លះគេថា«ចេះតែហ៊ាននៅដែរ អត់ភ័យទេ ព្រោះដាក់មីនព័ទ្ធជុំវិញ?» ហើយមួយទៀតអ្នកស្រុកអង្ករយើងឲ្យហូបនឹង កាលនោះយើងចាយលុយហើយៗខ្មែរក្រហមនៅនឹង ហើយចូលមិនចូលទេ ហើយខទាហរណ៍ដូចចូលទៅភូមិណាអញ្ចឹងស្អែកឡើងចាំស្ដាប់ប៉ុស្ដិ៍ខាងក្នុងហើយ គេស្រែកថាខ្មែរក្រហមចូលប្លន់អង្ករ ប្លន់អីទៅទិញធម្មតានឹង ហើយគេចេះតែរាយហើយ អានឹងសភាពការណ៍នយោបាយយើងពិបាកធានាហើយកសិករស្គាល់ខ្ញុំច្រើនណាស់ម៉ាចំនៀរនឹងៗ អញ្ចឹងគាត់មកពាក់មង កូនចៅអត់បាយអត់អង្ករ ជួនកាលគាត់ទិញអង្ករមក ឲ្យលុយគាត់ទិញ គាត់ខ្វះអង្ករគេគាត់ទៅ ឲ្យគាត់ទៅអញ្ចឹងវាចេះតែការសាមគ្គីនឹងរស់បានហើយ អញ្ចឹងអត់ធ្វើបាបអីគាត់ មានរឿងអីដែលវាត្រូវព្រួយ អញ្ចឹងយើងមានសេចក្ដីសុខរហូតៗ អញ្ចឹងពេលខាងលើ ខាងក្នុងនេះថាចុះរាគត្បាត ខ្សែបងប្អូនមានដូចគ្នាប្រាប់ហើយតើ ២-៣ថ្ងៃគេចុះហើយប្រឡោះនេះៗៗ អញ្ចឹងយើងរកកន្លែងគេចអីត្រៀមអញ្ចឹង ប្រាប់គាត់ត្រង់នេះៗកុំមកដាក់មីន អញ្ចឹងកសិករណាដែលយើងស្គាល់ជិតស្និត យើងប្រាប់ហើយ កសិករណាយើងមិនស្គាល់យើងដែលហ៊ានប្រាប់ៗ អញ្ចឹងយើងខស្បាហ៍ការរស់នៅទីតាំងនឹងបានស្រួល ដែលបានមានបញ្ហាអី សុខ

សាន្តរហូតទៅ ហើយអានឹងហើយដែលខ្ញុំនិយាយថា ពួកម៉ាដូរភូមិត្បិលក្រសាំង អាខ្លះយកកូនទៅដូរ អាខ្លះលុតជង្គង់ ដែលនែក!ឲ្យកូនមកធ្វើអីធ្វើទៅឲ្យតែបានអង្ករ "ខ្ញុំសុខចិត្តទិញអង្ករចែកជូនប្រជាជន ហើយខ្លះនាំគាត់ហូបប្រពៃណី ។

ដានី : ឆ្នាំណា?

ដេត : អានឹងក្នុងឆ្នាំ៨៤ ៨៥ ចូល៨៥ ។

ដានី : ចូល៨៥?

ដេត : បាទ! ខែវស្សា ៨៥ ។

ដានី : ពូជួយរៀបរាប់កន្លែងនឹងលំអិតតិចមើល យ៉ាងម៉េចកសិករ?

ដេត : គាត់អត់បាយ ហើយអញ្ចឹងគាត់ដើរទៅទាក់មង១ គាត់ដើរទៅចងសន្ទូចដាក់ពស់អី សន្ទូចយកពស់ចាំងលក់ អាស្បែកពស់ចាំងលក់ហើយ ។ អញ្ចឹងពេលគាត់អត់បាយទៅ យើងឲ្យគាត់ទៅ ហើយខ្ញុំប៉ះគ្រួសារមួយ ។

ដានី : នៅណានឹង?

ដេត : នៅម៉ាដូរ បឹងរាជ្ជះដាង ម្តុំដងស្ទឹងសែនខាងក្រោមនេះ ។

ដានី : ម្តុំដងស្ទឹងសែនកំពង់ធំ?

ដេត : បាទ! កំពង់ធំ ។

ដានី : គាត់អត់ធ្វើស្រែធ្វើអីទេ?

ដេត : យើងអត់ដឹង កាលនឹងសួរគាត់ថាអត់មានដីដែរ ដីខ្ពង់គេ ហើយដូនកាលគាត់នៅមាត់ទឹកអញ្ចឹងដីទំកលិច ដូនកាលវាអត់មានដីដែរ កសិករម៉ាសារនឹងអត់ដែរនឹង វាមិនសូវជាមានទេម៉ាចំនៀរនឹងក្រ បងប្អូនម៉ាសារនឹង អញ្ចឹងយើងចេះតែឲ្យ ។ អញ្ចឹងអាភាពនៃការផ្តល់ដំណឹងវាចេះតែបានទាំងអស់នឹងឯង ។

ដានី : កាលនឹងគ្រួសារណាដែលថាគាត់យកកូនស្រីមកឲ្យ?

ដេត : ខ្ញុំភ្លេចឈ្មោះ ចាំឈ្មោះមុនចាំ ។

ដានី : ឈ្មោះអីគេ?

ដេត : ប៉ុនវាភ្លេចហើយឥឡូវ ភ្លេចរកនឹកមិនឃើញ ព្រោះពួកខ្ញុំមាន២-៣នាក់... ហើយអារស់នោះក៏ងាប់ តាចើយក៏ងាប់ អញ្ចឹងពួកខ្ញុំបានឲ្យអង្ករគាត់ ឲ្យលុយគាត់ជូនគាត់ទៅ ។

ដានី : អង្ករបានមកពីណា ពូបានមក?

ដេត : អង្ករទិញៗមក ។

ដានី : ទិញពីខាងណាមក?

ដេត ៖ ទិញយកចេញពីកំពង់ធំផង ចេញពីម្តុំនិយាយរមកសិករដែលនាំគ្នាទៅរកត្រីនៅបឹងរាជុះដាង ដូនកាលពួកការណូត១ដែលគេត្រូវគេឡើងមកលើនេះទៅ យើងនេះទៅកាក់សុំទិញគេ គេមក លើវិញ សល់អង្ករប្រមូលទិញយក ។ ហើយម៉ាទូករបស់ខ្ញុំអត់ចេះអត់ទេ អង្ករ ។

ដានី ៖ អង្ករប៉ុន្មានដែរប្រាប់គាត់?

ដេត ៖ ១០០គីឡូ ឲ្យគាត់

ដានី ៖ បាទ!

ដេត ៖ ឲ្យគាត់ម៉ាបេ១ម៉ឺន ។

ដានី ៖ ម៉ាបេប៉ុន្មាន?

ដេត ៖ ៥០គីឡូ ។

ដានី ៖ ៥០គីឡូ ឲ្យអង្ករគាត់១បេ?

ដេត ៖ បាទ!

ដានី ៖ កាលនឹងម៉េច គាត់មកទាក់ទងពូថាម៉េច?

ដេត ៖ ទាក់ទងថាគាត់មានប្រពន្ធ ។

**កាស្សែតទី៣ ផ្នែក«ក»**

ដេត ៖ អត់ទេ ខ្ញុំឃើញអញ្ចឹង សភាពការណ៍ខ្ញុំតាមដាន ព្រោះខ្ញុំនៅកន្លែងប៉ុស្តិ៍វិទ្យុខ្ញុំដឹង ប៉ុស្តិ៍ដែល នៅកន្លែង ។ ហើយកាលនោះខាងភ្នំពេញ រាយការណ៍ពាក់ព័ន្ធនឹងដាំខ្សាន ពាក់ព័ន្ធនឹងជូរ ប្រាសាទព្រះវិហារនឹង ត្រូវការយន្តហោះមកយកអ្នកជម្ងឺ ត្រូវការខ្វះស្បៀងអី ខ្ញុំបកដឹងទាំង អស់នឹង កាលនោះដឹងម៉ឺង ដូចស្មែងយល់ ហើយមើលបកមួយភ្លែត១ដឹងម៉ឺង ហើយតាម ដានមើល ខ្ញុំប្រាប់ឯងចំមើលម៉ោងប៉ុននេះយន្តហោះមកហើយ ចាំមើលបើមិនឃើញ យន្ត ហោះមកមែន ហើយឲ្យកម្លាំងស៊ើបការណ៍ «យ៉ាងម៉េចកម្លាំងដឹកមក?» «អានេះ អត់មាន ដឹកកម្លាំងទេ ដឹកតែអ្នកជម្ងឺទេ អានោះ កម្លាំងនេះ យន្តហោះនេះដឹកមនុស្សហើយ» ត្រូវ ទម្លាក់ លោកណាមកពីណាដឹងទាំងអស់ម៉ឺង អានោះដឹងហើយ ខាងបញ្ញាការដើងគោកមក កាលណាចុះកន្លែងណាដឹងទាំងអស់ ។ ហើយអញ្ចង់ខ្ញុំត្រូវល្បាច១ឡើងធ្វើរបាយការណ៍ជូនតា ឯកសារណា អាដែលនែក!ឯកឧត្តមណាឈ្មោះអី កងពលណាចេញពីណាទៅត្រួតទ័ពនៅណា ទៅប្រជុំនៅត្រង់ណា ប៉ុនចំនុចខ្លះអត់រាយការណ៍ទេ ខ្ញុំខ្ជិល អត់នេះដែរ ការពិតខ្ញុំខូចដែរនឹង អត់មាត់ដែរនឹង ។ ហើយក្រោយពីនឹងមកទៀត ខ្ញុំឈប់នៅនឹងហើយ គេឲ្យទៅនៅប្រាសាទ ព្រះវិហារ ចេញប្រាសាទ ដល់ប្រាសាទព្រះវិហារនឹង កន្លែងនឹងទុកឲ្យតាសម្បត្តិនេះនៅ ។ អញ្ចឹងខាងនេះខ្ញុំឈប់ដឹងហើយការងារ ខ្ញុំដឹងតែប្រាសាទព្រះវិហារនឹងគេយកទៅបណ្តែត

បោលកន្លែងគេអូនឹង នៅចាំនឹងឯងគ្នាប៉ុន្មាន១០នាក់ គ្នា៥០នាក់គេអូម៉ាគ្រឿងនៅពើយ ដែលប្រាសាទព្រះវិហារនឹង ចេញចូលយកអង្ករថៃ ទិញអង្ករថៃចូល។ ដល់ពេលនៅប្រហែលបានប៉ុន្មាន ព្រឹត្តិការណ៍ថ្ងៃ៥-៦ ខ្ញុំនៅបានប្រហែល២ខែ១វស្សា។ ព្រឹត្តិការណ៍ថ្ងៃ៥-៦ នោះខែ៧-៨កាលនោះ។

ដានី ៖ ថ្ងៃ៥-៦ ខែ៧។

ដេត ៖ បាទ! ខែ៧ ដល់ព្រឹត្តិការណ៍នឹងកើតឡើង ខ្ញុំដេកមើលទូរទស្សន៍ ហើយកាលនោះកម្លាំងខ្មែរក្រហមកាលនោះដូចប្រាប់អញ្ចឹងវានៅល្បៀងគ្នា អត់ទាន់បែកគ្នាទេ។ ហើយប៉ុនកាលវៃប៉ុលពតនឹង ខ្ញុំនិយាយកាលវៃអាពតនឹង ញឹក ប៊ុនឆៃមកតើ។

ដានី ៖ ញឹក ប៊ុនឆៃ?

ដេត ៖ បាទ! ញឹក ប៊ុនឆៃមកចុះយន្តហោះនៅជាំនេះ ចុះជាំ ដាក់គ្រាប់មកប៉ុន្មាន កាលនោះចង់ទាញកម្លាំង គំនិតនេះចង់ទាញកម្លាំងខាងនេះនឹង ប៉ុនយើងដឹង១ថាគេមកចុះបញ្ចូលយ៉ាងណាឲ្យយើងទៅ ប៉ុនយើងទៅគ្មានអ្នកណា បង១អស់លោកនឹង គ្មានអ្នកណាគេនេះដែរ។ ហើយក្រោយមក មានព្រឹត្តិការណ៍ថ្ងៃ៧អី ហើយបានដកខ្ញុំមកអន្លង់វែងវិញ១ បានគាត់ឲ្យខ្ញុំនេះកាន់កាំម៉ាវ៉ាមួយ ប្រគល់កាំម៉ាវ៉ាអីនេះនឹង ដើរថតដើមស្មាច់ ទៅយើងតាមផ្លូវទៅ៦៨នឹងទៅស្មាច់នឹង កាលនោះខ្ញុំចូលដើងជាមួហ៊ុនស៊ីប៊ិចហើយ ចូលដែលញឹក ប៊ុនឆៃក្ដៅពយ១ ហើយម៉ាជួរស្មាច់នឹងខ្ញុំដើរទាំងអស់ មកខាងល្បឿនអីនឹង ប៉ុនគេអត់ស្គាល់ខ្ញុំទេ ទៅផ្ញើការទៅថតកាំម៉ាវ៉ានឹង។

ដានី ៖ ទៅជាមួយពួកញឹក ប៊ុនឆៃ?

ដេត ៖ អត់ទេ ពួកខ្ញុំ កាលនោះវាជាខ្មែរក្រហមទៅជួយដែរ ដកកម្លាំងរាប់រាយដែរនឹង ទៅជួយណាអញ្ចឹងខ្ញុំនៅនឹង១ជិត២ខែ១ចេញចូល ដឹងចង្អាក់ដឹងនេះ។ ដល់ពេលនៅយូរទៅបានដឹងថាអត់ស្រួល កម្លាំងខ្ញុំអត់មានកម្លាំងណាពិតទេ អញ្ចឹងប្រាប់តាមគ្នាយកកម្លាំងនឹងប្រើផង ដឹងអញ្ចឹងអាសមរង្ស៊ី ដឹងណាខាងនរោត្ដម ខាងហ៊ុនស៊ីប៊ិចទេ ច្របូកច្របល់គ្នា។

ដានី ៖ ច្របូកច្របល់ប្រជាជន?

ដេត ៖ មានតែពីរទេ។

ដានី ៖ មានតែពីរទេ?

ដេត ៖ បាទ! មានតែពីរទេកាលនោះ អញ្ចឹងមានតែពរព្រោះកាលនោះគណបក្សប្រជាជនកំពុងតែវៃអញ្ចឹងយើងទៅ អញ្ចឹងមានតែសមរង្ស៊ី និងហ៊ុនស៊ីប៊ិច អញ្ចឹងអាខ្លះចូលហ៊ុនស៊ីប៊ិច អាខ្លះវាចូលទៅខាងនោះ អញ្ចឹងសមរង្ស៊ីអត់កម្លាំងទេ អញ្ចឹងទាញយកកម្លាំងហ៊ុនស៊ីប៊ិចនឹងប្រើ

ហើយទៅចេះតែចូលចុះឡើងៗ ដល់ពេលដល់ហើយឮថាកម្លាំងរាជរដ្ឋាភិបាលចាប់ផ្ដើមបុកវ៉ៃ ហើយនាំគ្នារត់ទៅនោះហើយ នៅកម្លាំងតែម៉ាកងទេ អានឹងស្មាហាប់របស់គេមែន នៅអាភ្នំ អាកន្លែងខាងនោះជិតកាស៊ីណូនឹង កាលនឹងផាប់យាម ផាប់មួយយប់មួយៗៗ ថ្ងៃណាបី ថ្ងៃណាពីរ ផាប់ញឹកជាងគេ រាល់ថ្ងៃ ផាប់ញឹកគ្នា ។ អញ្ចឹងវ៉ៃគ្នា កាលនោះវាលពេកហើយ ប៉ុនឃើញកម្លាំងម៉ាកងនឹងស៊ិតស្មាញមង អត់ចេះរត់ដូចគ្នាជាប់អានឹង បើខុសពីនឹងអត់ទេ គ្មានអ្នកណាពូកែ ។ ដល់ពេលអញ្ចឹងទៅខ្ញុំទៅថតអីអញ្ចឹង ខ្ញុំថតបានរូបភាពច្រើនណាស់កាលនឹងបាត់អស់ ។ ហើយខាងខ្ញុំទៅក្នុងៗនោះ ខ្ញុំសុទ្ធតែថតច្រើនណាស់ ព្រោះគេឲ្យទៅខ្ញុំថត ខ្ញុំថតសកម្មភាពច្រើនណាស់ ។ ដល់ពីនឹងមក នៅប៉ុន្មានខែនឹង ខ្ញុំមក គាត់មកហៅវិញ មកវិញខ្ញុំមល ខ្ញុំដឹងការទាក់ទងៗគ្នា ហើយខ្ញុំដឹងចង្វាក់តាំងពីនឹងមក ប៉ុនឲ្យពួកនឹងទាក់ទង តែខ្ញុំអត់ដែលរាយការណ៍ទេ ខ្ញុំលែងរាយការណ៍ហើយ ។

ដានី : ចង្វាក់ម៉េច អានឹង?

ដេត : ខាងពួកខាងនេះនឹងទាក់ទង ខាងក្នុង ខ្ញុំដឹងមកទាក់ពីណា ទិសស្រែណាយ ទិសបន្ទាយស្រីដល់ពេលរហូតទៅដល់ប៉ុន្មានខែបាន ពួកនោះគេផ្ដាច់ខ្លួន ពួកខាងនោះគេផ្ដាច់ខ្លួនអស់ម៉ាឆុលទៀតទៅ២សារ ។

ដានី : ខាងត្រពាំងប្រាសាទ?

ដេត : ហ៎! ខាង៥១៩ ខាងពួកគគីរ ខាងថ្មពួកណា រួចទៅខ្ញុំនេះក៏តានេះហៅខ្ញុំទៅជួប ឲ្យទៅជួបដែលឌុល សារឿននឹងទៅ ថាឯងទៅជប់គគីរ ទៅនៅជាមួយឌុល សារឿនហើយ ជួយពិគ្រោះការងារគ្នា ខ្ញុំក៏ទៅជួបជាមួយគាត់ នៅធ្វើការជាមួយគាត ។ ដល់ពេលធ្វើការជាមួយគាត់ទៅ គាត់សួរខ្ញុំថានែក! នៅយូរទៅគាត់សួរខ្ញុំថា«ហ៎! ដេតឯងមានដឹងតពួក៩៨០ម៉េចទេ?» ថា«អត់ដឹងអីទេ» ហើយខ្ញុំនឹកឃើញថា ពួកនេះសង្ស័យពួក៩៨០ ហើយកាលនោះ៩៨០នឹងការពិតគួរឲ្យគេសង្ស័យ កាលនោះខ្សែតាពកនឹង គាត់មានប្រព័ន្ធគាត់មួយ មានការទាក់ទងគ្នា មានលួចលាក់តេអូ នៅព្រៃស្អាតនេះ សម្រាប់ចង់ទាញកែពក តាពកភូមិភាគឧត្តរមុន បានប្រុងយកកូនគាត់នៅធ្វើព្រៃស្អាតចុះឡើងៗ ហើយពួកនឹងតាមដានតែតេអូខ្ញុំទេ ព្រោះតេអូខ្ញុំៗមានបញ្ហាអីគេដឹងពីខ្ញុំច្រើនជាង អញ្ចឹងចាំស្ដាប់តែខ្ញុំទេ តែខ្ញុំនិយាយម៉េចគេយកផ្លូវការ ព្រោះខ្ញុំអាចមានបញ្ហាពីតាម៉ុក ឬបញ្ហាពីអ្នកណាមួយផ្លូវការ អញ្ចឹងចេះតែតាមដានខ្ញុំ ។ ប៉ុនខ្ញុំដឹង តេអូមានអញ្ចឹងគេខាងលើក៏គេដឹងហើយជំនាន់នោះ ប៉ុនគ្រាន់យើងរកចាប់ចំនុចអត់បាន ហើយអញ្ចឹងគេចេះតែចោទ៩៨០ៗ ប៉ុន៩៨០ទាក់ទងតែមុខទេ ខ្សែមុខហើយកាលនោះ សភាពការណ៍ដល់ពេលយើងមកពង្រត់រហូត ចាប់ប៉ុលពតដាក់គុកហើយនឹង

ដល់ពេលចូលមកដល់វិញនឹង ក៏នៅខ្ញីញខ្ទេងដែរ អត់ទៀងទាត់ទេ នយោបាយអត់នឹងនរ ទៅខាងណាពិតប្រាកដអីទេ ។ អញ្ចឹងពួកនឹងក៏មានរកវិធី២ លក់រូងលក់អីនឹង គាម៉ុកអីហាម ឃាត់មិននេះនឹង អាពួកនឹងឆ្អើល ហើយអាខ្វះរកស៊ីឲ្យគេកាប់ឈើកាប់អីនឹង បែកការណ៍នឹង ទៅកើតរឿងរ៉ាវនឹងទៅមានរឿងម៉ាសារនឹងដែរ អញ្ចឹងអាពួកនឹងខ្វាចនឹងវាភ្ជាប់បណ្តោយ ជាប់គ្នាបណ្តោយ អានឹងអត់ទាន់ប្រតិកម្មទេ ។ ក្រោយមកទៀត ដែលខ្ញុំទៅនៅនោះ ទៅជុំគេ នោះ ខ្ញុំមកតេអូនោះ កាន់អាវុធអា៦០ ខ្ញុំមើលចុចមើលទៅ១០កប់ក្បាល៦០ ក្បាល៦ អស់ ព្រឺវីលដូចវិទ្យុនឹង ខ្ញុំចាប់បានខ្ញុំថតសម្លេងទុកទៅ ក្រោយមកខ្ញុំបោះចោលអស់មិនបាន ទុក អានឹងនោះចេញពីអគ្គបបញ្ជាដើងគោកមក ចេញមកភូមិភាគ៤នេះ ឲ្យប្រយ័ត្នប្រយែង ឲ្យមើលទិសក្នុងអន្លង់វែង ព្រោះត្រូវការទាក់ទងគ្នាហើយ ។ ហើយខ្ញុំពួកនេះទាក់ទងមែន ហើយ ប៉ុនកាលនោះខ្ញុំដឹងហើយ នៅនេះខ្ញុំដឹងហើយណា ប៉ុនតែខ្ញុំទៅខ្ញុំប្រាប់ប្រពន្ធខ្ញុំដែរតើ «នែក!សភាពការណ៍នយោបាយអត់ល្អទេ អញ្ចឹងបើសិនមានសកម្មភាពរត់ទៅណា ទៅនឹងទៅ មិនបាច់រត់តាមខ្ញុំទេ» ខ្ញុំប្រាប់អពាង ។ ហើយខ្ញុំដែលខ្ញុំរៀបចេញទៅ តែដែលតាម៉ុកឲ្យទៅ នៅចុងបូព៌ា ទៅនៅជាមួយ៥១៩នឹង ក៏ទៅនឹង ហើយដល់ពេលហើយមូលអាតេអូនឹង ចោទ ម៉ង់មានម៉ោងវាខ្ញុំភ្លេចម៉ោងហើយ ដល់ម៉ោងនិយាយៗ អត់មានពិបាកនេះ និយាយព្រុសង ខាង ដឹងម៉េចតេអូនឹងស្រួបគ្នាម៉េចឆ្លល់ដែរ តាមមិញនិយាយទូរស័ព្ទទេ មិនមែនតេអូទេ ប៉ុន តេអូវាស្រួបយកអាចំនុចនឹង ហើយបើអាធំនឹងខ្ញុំតាមដានរហូត អាណាទាក់ទងៗពួកនឹងទាក់ ទងជាមួយអាណា ប៉ុនខ្ញុំអត់ាដែលរាយការណ៍ប្រាប់អាណា ។ ថ្ងៃមួយ អាពួកនឹងអត់ទាន់ដឹង ទេអាពួកនឹង អន្លង់វែងអត់ទាន់មានរំដើបរំជួលទេ នៅអានោះមេៗល្មមៗម៉ាចំនួននោះចូល ទៅទីបញ្ជាការកងពល១៩នៅភ្នំបូកនោះ ក៏ខ្សែញីក ប៊ុនឆៃរាយការណ៍ខ្មោកមកញីកប៊ុនឆៃ ។ ញីក ប៊ុនឆៃ ទូរស័ព្ទទៅ កន្លែងខ្ញុំមានទូរស័ព្ទមួយ ហើយខ្ញុំអង្គុយជាមួយបងឌុល សារឿន ដែរថា«អាដេតលើកមើល ទូរស័ព្ទអីគេ» ខ្ញុំចុចអាសម្លេងព្រុតិច ខ្ញុំលើក«គោរពបង គោរព ព្រះបាទមានអីបង?» «បងឌុល សារឿននៅទេ?» ថា«នៅ» «អឺ!សុំជួបតិច» ជួបគាត់ ម៉ង់ ឌុល សារឿនជួបទៅ ថា«ខ្ញុំឆៃៗ» «បាទ!មានអី» ជួបគ្នានិយាយចុះឡើង គាត់ថា «ឥឡូវខ្សែបណ្តាញនៅទីបញ្ជាខាងត្បូង រាយការណ៍មកថាពួកទិសស្រែណយ ពួកបន្ទាយស្រី នៅក្នុងដែននឹងចូលទៅដឹកស៊ីក្នុងអស់ហើយ ហើយអន្លង់វែងអាចប្រែប្រួល អញ្ចឹងទៅរៀបចំ ផែនការយ៉ាងម៉េច ដើម្បីទប់ដើម្បីឲ្យកម្លាំងនឹងទៅបាន» ហើយខ្ញុំត្រៀមកម្លាំង២ពាន់ ហើយ ខ្ញុំនឹកឃើញទប់ស្ទាច់ឲ្យតែបានមក យកកម្លាំង២ពាន់ទប់អន្លង់វែង ខ្ញុំនឹកឃើញអញ្ចឹង ។ បើ ស្ទាច់ទប់មិនបានផង យកកម្លាំងខ្មែរក្រហមទៅជួយទប់ហើយ នឹកឃើញបាន២ពាន់មកពីណា

ខ្ញុំនឹកឃើញហើយ ។ ដល់អញ្ចឹងទៅ បងសារឿនសួរខ្ញុំ«ម៉េចអាដេត ពួក៩៨០ម៉េចហ៎!» ថា«ទេ!មានអី ប៉ុនក្រែងតាប្រតិកម្មគេចាប់ ដេញចាប់គេ អាពួកនេះរកស៊ីពន្ធ រកស៊ីលួច អាឈើទេដឹង ព្រោះខ្ញុំមិនបានជិតម៉ាខែដែរ ខ្ញុំក្រែងមិនដឹងសភាពការណ៍ម៉េចបង ខ្ញុំមិនដឹងដែរដូចតែគ្នា ហើយមុនៗអត់មានទេ» ខ្ញុំថា«មិនទាន់មានអីទេពួកនឹងនោះ ពួកនឹងយ៉ាងម៉េចក៏គ្មានអាណាក្បត់តាដែរ» ខ្ញុំថាអញ្ចឹង «ប៉ុនខ្លាចតែអាដែលសភាពការណ៍យ៉ាងណាទៀត ហើយម្យ៉ាងទៀត តាក៏គាត់បងៗឥស្សរជននយោបាយនឹង ដែលនៅជាមួយប៉ុលពតមកនៅវិញមក ឬមួយមតិគ្នាក៏វិលខួរទៅ មិនដឹងទៅខាងណា អត់មានទីប្រឹក្សានៅជិតជួយអញ្ចឹងមិនស្រួលចេះតែម៉ាមាត់មួយយកកន្លងចាស់ដូចប៉ុលពតអញ្ចឹង ផាប់ហើយឯង» ខ្ញុំថាអញ្ចឹង ។ គាត់អត់ទាន់មាត់ទេ កំពុងតែគិតៗទៅយើងហូបបាយថ្ងៃត្រង់ ដល់ម៉ោង២មកម៉ាសារទៀត «បងឯងបានរាយការណ៍ឲ្យតាឥឡូវ ម៉េចៗរាយទៅច្បាស់ហើយអត់មាននេះទេ ការងារនឹងច្បាស់ហើយ» អីយ៉ាស់រៀងខិចមែនទែនហើយ ខ្ញុំនឹកឃើញហើយ «ដល់ហើយចាំពិគ្រោះគ្នាសិន ម៉េចៗចាំមើល ខ្ញុំមើលម៉េចបានខ្ញុំឆ្លៀតទៅជួបជាមួយតា» ។ ពួកនេះរៀបផែនការមែន ហើយខ្ញុំក៏តាមដានគេអួ តាមដានទៅឮមែន ឮសភាពសការណ៍អត់ស្រួលមែន ឮផែនការណ៍ ។ ហើយដល់ប្រហែលជាម៉ោង៤ គេមកម៉ាសារទៀតៗ បានបងសារឿងថា«ហ៎! ដេត ខ្ញុំទៅជួបឆែសិន» «បងឯងទៅ» «អញ្ចឹងឯងទទួលខុសត្រូវកន្លែងនេះ» ថា«បាទ!ចាំខ្ញុំមើលអត់អីទេ មានអី» ម៉េចៗអញទៅអន្លង់វែងទៅជួបតាតិច គ្រាន់បងសារឿងចេញផុតខ្ញុំនឹងចាប់គេអួបានគេមកតាសម្បត្តិប្រចាំស្ថានីយ៍៩៥របស់តាម៉ុក នៅផ្ទះតាម៉ុក ខ្ញុំតេខ្មោក ខ្ញុំសួរ«តាសម្បត្តិ» «អឺ!នៅណា» ថា«បាទ!៣៨០» «ម៉េចមានអី» ថា«មានការណ៍តិច» អានោះមានការតិចចាំតិចសិន គ្រាន់ចាំតិចដូរផ្ទះបាត់ហើយ មានផ្ទះមូលណា «ឈប់ចាំសិន» គ្រាន់ចាំមកផ្ទះទៀតហើយខ្ញុំប្រាប់ គ្រាន់តែនិយាយជិតកន្លះម៉ោង អញ្ចឹងតាងពីក្បាលពារហូតដល់ក្បាល៦ ៗចុះវិញចុះឡើងវិល ប៉ុននិយាយអត់និយាយច្រើនទេ និយាយតិចៗទេម៉ារលកនិយាយ២ម៉ាត់ ថា«មានពីណានៅជិតទេ?» «អត់» «បើអត់ សុំឲ្យប្រាក់៥០០» ថាអញ្ចឹងចល័តផ្ទះ១ទៀតហើយ«សភាពការណ៍អត់ល្អ ស្ថានការណ៍ប្រែប្រួល» ម៉ាម៉ាត់ៗអត់និយាយចេះ យើងចាប់ក៏ចាប់អត់ទាន់ដែរ ផ្ទះយើងចង្អួចហើយណា ចងមួយចង្កោមៗចាប់ៗអត់ទាន់ ។ ហើយបើទ្វារសំងាត់ ទ្វារតូច ទ្វារធំ ទ្វារងងឹត ទ្វារភ្លឺ ទ្វារដែក ទ្វារឈើ ទ្វារឫស្សីដើរអាកាស ដើរគោកបកអស់និយាយហើយ និយាយក្នុងការចារកម្មម៉ងនឹង ។ ហើយខ្សែញ៉ឹក ប៉ុនឆែនៅទីបញ្ជាការភ្នំបូក កងពល១១រាយការណ៍ថា កម្លាំងភ្នំគូលែន បន្ទាយស្រីស្រែណយបានចូលទៅសារភាពក្នុងសមាហរណ៍កម្មទាំងគ្រួសារ តែការពិតមានអ្នកណាទាន់ទៅ

មិនទាន់ទៅដងនឹង បានអីនៅឡើយ ឃើញអញ្ចឹងសុំ៥០០ប្រយ័ត្នប្រយែង ត្រូវមើលៗឲ្យអស់ ខ្ញុំបើកចំហរប្រាប់អញ្ចឹងឯង "កុំប្រាប់ពីណាៗ ប្រាប់៥០០បានហើយ"។ ទៅលោកសម្បត្តិនឹងអត់មានប្រាប់ពីណាដែរ សុំប្រាក់៥០០គេ ប្រពន្ធរៀបចំផែនការប៉ិបៗក៏រៀបអត់ទាន់ដែរ ហើយបានពួកនឹងវាចាប់ផ្តើមទាញកម្លាំងមក ដាក់ប្រតិកម្មបណ្តោយ អញ្ចឹងវាខុសថ្ងៃហើយ។ អញ្ចឹងពួកនឹង បើសិនខ្ញុំប្រាប់ពួកនឹងវីរួចហើយ ខ្លួនឯងវាអាចរួច តែប្រពន្ធកូនត្រូវវ៉ៃ ប្រទូសប្រទះគ្នានឹង ប៉ុន្តខ្ញុំធ្វើម៉េចឲ្យស្ថានការណ៍វាអត់មាត់ៗ អញ្ចឹងចិត្តគាសម្បត្តិនឹងដែរនេង កុំប្រាប់គា ប្រាប់តែខ្ញុំបានហើយ។

ដានី : ប្រាក់៥០០ប្រាប់ពីណាគេ?

ដេត : គាថាន់នឹង ស្តានីយគេ៥០០ អាដែលឪរគេឈ្មោះតេអូគេៗឈ្មោះ៥០០។

ដានី : របស់ពីណាគេគ្រប់គ្រង៥០០?

ដេត : ៥០០នឹងគឺស្ថានីយ៍ដូចថាថាន់នឹងគេឈ្មោះតេអូគេនឹង ឈ្មោះ៥០០។

ដានី : អត់ឲ្យប្រាប់គាម៉ុកទេ?

ដេត : អត់ឲ្យប្រាប់ទេ អញ្ចេងវាហាក់បីដូចជាជួយម៉ាកម្រិតនឹង បើសិនខ្ញុំប្រាប់អូ......វ៉ៃគ្នា ព្រោះយើងដល់ដំណាក់កាលនេះ យើងដឹងណាអីណា អញ្ចឹងលក្ខណៈនឹងអាអ្នដឹងទៅ វ៉ៃគ្នាអាយប់នឹងឯង វ៉ៃគ្នាខ្ញុំដឹង គ្រាន់បើតេអូខ្ញុំដឹងវ៉ៃគ្នាបាត់ហើយ ប្រាប់គាដាក់អាវុធ សំណាងៗ ដល់ពេលក្រោយមកទៀត អាយុនៗប្រធានពេទ្យនេះ កាលនោះកូនប្រសារកែពត កាលនោះវានៅជាមួយខ្ញុំនោះឯង ប៉ុន្តកាលនោះវាដើរមកលេង ខ្ញុំនៅតេអូនៅតែឯង មកគេថា"ដេតសុំទៅជួបទៅភូមិ៧៧ នៅនេះសន្តិភាពក្រោម អាផ្លូវយើងមកផ្លូពួកណា" ខ្ញុំថា"ទៅធ្វើអី" "ទៅជួបប្អូនៗឲ្យជួប" "ឯងទៅៗមកវិញល្ងាចអត់" ដល់ពេលខ្ញុំទៅ ឃើញគេរៀបចំអីវ៉ែអីវ៉ាន់ហើយ ខ្ញុំថាគាត់នេះរត់ហើយ គ្រាន់មើលអត្តចរិកដឹងថារត់ហើយ ទៅហើយ ព្រោះប្រពន្ធកូនគេក៏ខ្ញុំដឹងថាខ្មែរ។

ដានី : កែ ពក?

ដេត : កែ ពកៗទៅបាត់ហើយនឹង កែ ពកូលបាត់ហើយ នឹងមួយទៀតអាពួកនឹងចាំយកយូរហើយចាំយកកែពក វាគំរាម តាមពីមុនពួកព្រឹត្តិការណ៍ពួកនេះទៀត ប៉ុន្តវានៅបង្កប់នេះឯងអត់ទាន់ដល់ពេលនេះអញ្ចឹងខ្ញុំថាខ្ញុំដើរៗចេញទៅ ឡប់មកវិញ គាត់វេចបង្វិចៗពេញរៀបសាក់កាដូរ ១ បង្វិចមួយសុទ្ធតែថ្នាំពេទ្យពិសេសៗ ថ្នាំវះកាត់អីម៉ាចោលនឹងលើគាត់នឹង ប្រដាប់ប្រដាវះកាត់អីនឹងថ្លៃដែរ គាត់ម៉េច អញ្ចឹងឃើញគាត់វេចៗ ខ្ញុំទៅដល់ឃើញគាត់ស្តាយអាដែលនែក!បង្វិចគាត់ទៅ អង្រឹងមួយបង្វិចមួយ ស្រាប់ដល់ពេលដល់ខ្ញុំដើរប្រហែលៗពីនឹងទៅផ្លូល់

បាំងម៉ាកែងព្រៃនឹង ខ្ញុំឡប់មកវិញ ចូលអស់ អានេះរត់ហើយ ប៉ុន្តែខ្ញុំនឹកឃើញឲ្យទៅចុះ ខ្ញុំខូច
ណាស់ ដែលរួចខ្លួនទេ ប៉ុន្តែខ្ញុំនឹកឃើញធ្វើម៉េចឲ្យប្រសើរ ការប្រែប្រួលយើងឃើញ វាត្រូវ
តែទៅហើយ ប៉ុន្តែការពិត បើសិនជាពេលនឹងខ្ញុំកុំជួយពេលនឹង ខ្ញុំកុំប្រាប់មុនគេចាប់ ទម្រាំ
បានសមាហរណ៍កម្មទម្រាំបានមិនដឹងងាប់អស់ប៉ុន្មានទៀត អញ្ចឹងខ្ញុំជួយអាការងាររទាក់ទងខាង
អីលើខ្ញុំហើយ ខ្ញុំដឹង ព្រោះទៅកន្លែងណា គេអូខ្ញុំអត់ដាច់ទេ ដូចដែលអាខែតរត់និង...........
អាសង់ត្រាល់នឹង៣-៤ អាធំៗនោះ៣-៤ អញ្ចឹងកន្លងមកខ្ញុំនិយាយជាមួយលោកប្រធាន
នោះចង់និយាយថាអានេះឯងជាការជួយរបស់ខ្ញុំកន្លងមកណា ខ្ញុំជួយ ហើយខ្ញុំអត់ទេៗ
ហើយក្រោយមកទៀត បានអាពួកនឹងផ្តាច់ខ្លួនទៅៗ ខ្ញុំក៏នៅនោះទៅ ប្រពន្ធខ្ញុំអត់ទៅតាមគេ
នេះ ក៏ទៅគេនេះដែរទៅៗ អញ្ចឹងបានដីខ្ញុំគេយកអស់ ដល់ពេលឡប់មកវិញ ខ្ញុំអត់មានខឹង
រដ្ឋាភិបាល ព្រោះខ្ញុំមានខួរក្បាលមួយគិតនៅពេលដែលទៅប្រាសាទព្រះវិហារ ព្រោះខ្ញុំគេឲ្យ
កាំម៉ារ៉ាមួយតូចថត នឹងឯកឧត្តមទៀវ បាញ់ និងឯកឧត្តមមាសសុភា និងគណៈប្រតិភូប៉ុន្មាន
នាក់ទៀតទេ ហើយខាងខ្ញុំនេះមាន តាណន តាមុន តានៅ ទេពកូណាល់ តារ៉ន ខ្ញុំៗអ្នកថត
ដល់ពេលការចរចាគ្នានឹង លើកទី១អត់បានទៅទេ លើកទី២ខ្ញុំដឹងៗ អញ្ចឹងឯកឧត្តមទៀវ
បាញ់ បាននិយាយហើយថា«ថ្ងៃនេះអត់មានអ្នកណានិយាយទៀត ថ្ងៃ១៥-១៦ត្រូវទៅ»
១៥-១៦ខែ១នោះកាលនឹង ត្រូវតែទៅ ហើយបើមិនទៅទេ អានឹងខ្ញុំមិនដឹងទេ តែបើទៅ
ថ្ងៃនឹងមានទុកតួនាទីតំណែង ហើយផ្ទះដីអ្នកណាដីអ្នកនឹងយកវិញ តែបើខុសពីថ្ងៃនឹងអត់ទទួល
ខុសត្រូវទេ ហើយក៏ចូលដំឡូងនឹងហើយ តាទៀវនិយាយរួច ទេពកូណាល់និយាយម្តង ទេព
កូណាល់និយាយរំលឹកពីរឿងវិញ ប្រយ័ត្នខ្លាចដូចព្រឹត្តិការណ៍ចូលភ្នំពេញ ដែលវ៉ៃបាតុកម្មវ៉ៃ
ខៀវសំផនអីអញ្ចឹងណា រំលឹកអាប្រវត្តិចុះឡើងវិញ ឯកឧត្តមមាស សុភាទះតុផុងដើរចេញ
ដើរចេញ ថៃឆ្អើល ស្អានតែឈ្លោះគ្នា ថៃវារត់ចង់ងាប់ ហើយពេលនឹងខ្ញុំអត់ថតទេៗ ហ្នឹង
ហើយពួកមេៗបន្ទោសខ្ញុំដែរ ខ្លាំង ទេពកូណាល់មិនថតទេ «អាចំត្រង់នឹង» «អូ!ខ្ញុំអស់ថ្ម»
ប៉ុន្តែការពិតដល់ពេលគាត់លើកចុងក្រោយមក ខ្ញុំអស់អារម្មណ៍ហើយ ដឹងខំតទៅអីទៀត
យើងវាស្ថានការណ៍មិនអាចនេះ អស់គេជួយពីណាមានពីណាមកជួយទៀត កើតរឿងជាប៉ះ
ទង្គិចគ្នាៗ ហើយកាលនឹងបងទេពកូណាល់ប្រុងទាញកម្លាំងឲ្យទៅលិចទៀត មិនចង់ឲ្យចូលមក
នេះទេ ឲ្យទៅលិចទាំងអស់គ្នា អញ្ចឹងរឿងប្រទះប្រទិសគ្នាច្រើនៗ អញ្ចឹងការជួយរបស់ខ្ញុំ គឺ
ការពិតជួយអស់លោកដែលគេប្រុងសម្លាប់ចោល ហើយគាត់និយាយហេតុផលប្រាប់ អញ្ចឹង
បានគាត់ចេះតែឲ្យមកសួរខ្ញុំៗ អញ្ចឹងខ្ញុំនិយាយកន្លងមកនេះ គឺជាប្រវត្តិត្រួសៗទេ រកឲ្យល្អិត
ល្អន់ម៉ាថ្ងៃអត់អស់ទេៗ

ដានី : អញ្ចឹងពូខ្ញុំចង់គិត ប្រហែលជាទាក់ទងដូចថាកាលពីជំនាន់៣ឆ្នាំ ពី៧៥ដល់៧៩ ពូកាលជំនាន់នឹងធ្លាប់មានទំនាក់ទំនងអីល្អជាមួយប្រជាជនដែលជាមិនមែនជាអ្នកនៅក្នុងអង្គភាពជាមួយពូៗមានធ្លាប់រាប់អានជាមួយគាត់កាលជំនាន់៣ឆ្នាំ?

ដេត : ការពិតបើយើងគិតពី៧៥ មក៧៩ ការពិតខ្ញុំរស់នៅក្នុងចង្កោមអង្គភាព អញ្ចឹងដែលយើងជួបប្រជាជនមកខាងក្រៅអត់មានពេលជួប អត់ទេ ជំនាន់នោះឲ្យជិតស្និតជាមួយបងប្អូនណាគឺអត់ម៉ង យើងគិតពីធ្វើការងារ ហើយយើងអត់មានពេលអីនេះ ហើយជួនណាទៅអង្គភាពអញ្ចឹងអត់មានបានដើរទៅណាអីវែងឆ្ងាយទេ អញ្ចឹងយើងធ្វើការតាមក្រិត្យក្រមរបស់យើងជាកម្មករ ហើយអត់មានមេ ក្នុងនេះមានមេគេដែរ ប៉ុនមេតូចត្រូវតែលឺៗ ត្រូវតែសែងៗពី៧៥មក ដូចខ្ញុំប្រាប់អញ្ចឹងវាអត់បានអីទេ ។ នៅចន្លោះពេលដែលខ្ញុំបាននេះ នឹងនៅតែមកប៉ោយប៉ែតនឹងយ៉េងអាចទៅចួបជាមួយកសិករមើលស្ថានភាពនឹង នឹក!ឃើញថាយើងនៅប៉ោយប៉ែតស៊ីឆ្ងាញ់ដេកស្រួល អញ្ចឹងទិញសម្ភារៈអីចេះចល ប៉ុនមកដល់ខាងក្នុងអត់មានឃើញអីសោះ ហើយដែលយើងនៅកំពង់សោមបាយស៊ីគ្រប់គ្រាន់ ហើយប្រកាសដូចថាអងរកសិករយើងធ្វើបាន១ហិចតាប៉ុន្មានតោនអញ្ចឹងមិនបាច់យកមកពីចិនទៀតទេ ដល់ពេលដកមកភ្នំពេញ ស៊ីបបរទៀតហើយមិនដឹងយើងនឹកឃើញអារម្មណ៍នេះហើយ ។ ហើយយើងទិញក្រណាត់កៅស៊ូនឹង ធ្លាក់ទៅណា ។ ប៉ុនឲ្យទំនាក់ទំនងជាមួយប្រជាពលរដ្ឋណាវាអត់ទេ អាថ្ងៃមួយគេឆ្លងកាត់នោះ គេប្រាប់ខ្ញុំដែរ ឲ្យខ្ញុំឈប់ទៅជួរលោបៀ្យរៗប្រយ័ត្នប្រជាជនទៅកាប់ ខ្ញុំចេះតែឆ្ងល់កន្លែងនឹងគេដេញកាប់ស្អី គេហៅចាស់ៗមក២-៣នាក់ស្គមៗស្លេស្លាំងដើរមកថា “អឹងឯងនៅសហករណ៍ណាម៉េចអញ្ចឹង?” “អត់អីហូប” ហៅមកហុចដៃ ឲ្យអង្ករគាត់ ឲ្យនំនេះទៅយើងមកពីថៃ ពេលដំបូង ។

ដានី : ពេលណា?

ដេត : អានឹងចុង៧៦ហើយ ។

ដានី : ម៉េចបានទៅជួប?

ដេត : ចុង៧៦ ចូលជានេះហើយ ខែប្រាំង កាលនោះខ្ញុំធ្វើដំណើរពីប៉ោយប៉ែនមកភ្នំពេញ អានឹងគេហៅឡើងមកធ្វើការ អានឹងគេហៅមកភ្នំពេញវិញ ។

ដានី : ពេលនឹងឈប់នៅកន្លែងណា?

ដេត : ហួសពីព្រាំ ចូលក្នុងដីយើងដែរ ខ្ញុំដឹងថាចូលដីរលោបៀ្យរ ហើយវាលស្រែអត់មានភូមិទេកាលនឹង ហើយគាត់ដើរតាមថ្នល់ ហើយខ្ញុំ ។

ដានី : គាត់ដើរធ្វើអីគាត់?

ដេត ៖ គាត់ដើររើសខ្យង រើសក្តាម ដើរដឹកក្តាមខ្យង គាត់ថាអត់បាយ នឹកឃើញអញ្ចឹង ។

ដានី ៖ ប៉ុន្មាននាក់?

ដេត ៖ ៥នាក់ អញ្ចឹងយើងតូចចិត្តដែរ ។

ដានី ៖ ៥នាក់នឹងសុទ្ធតែជាកសិករ?

ដេត ៖ សុទ្ធតែជាកសិករ ប៉ុន្តែ ។

ដានី ៖ មើលទៅអ្នកភូមិនៅនឹង ហើយក៏ប្រជាជនជម្លៀសមក?

ដេត ៖ មិនដឹងទេ បើវាស្គមពេក១អញ្ចឹងខ្ញុំមានអារម្មណ៍មួយថាអត់ស្រួលទេ កន្លែងខ្លះមានបាយស៊ី កន្លែងខ្លះអត់បាយស៊ីវាម៉េច អញ្ចឹងខ្ញុំកំពុងគិត ។

ដានី ៖ អញ្ចឹងដល់ពេលពូជួបពួកគាត់ អានឹងជួបតាមផ្លូវទេ?

ដេត ៖ ជួបតាមផ្លូវទេ អត់មានអ្នកណាដិតទេ ។

ដានី ៖ ដល់ពេលជួបអញ្ចឹងយ៉ាងម៉េច?

ដេត ៖ ដល់ពេលជួបទៅយើងឲ្យអីគាត់ហូបទៅ ។

ដានី ៖ កាលនឹងឲ្យអីគេ?

ដេត ៖ ខ្ញុំឲ្យនំប៉័ង ផ្លែមៀន ក្នុងអង្ករ កាលនោះខ្ញុំស្រគួរអង្ករប្រហែល១០គីឡូ អញ្ចឹងដាក់ឲ្យគាត់ទៅ ។

ដានី ៖ ឲ្យប៉ុន្មាន ឲ្យគាត់?

ដេត ៖ ឲ្យទាំងអស់ ។

ដានី ៖ ឲ្យទាំង១០គីឡូ?

ដេត ៖ បាទ! ១០គីឡូ យកទាំងអស់ យកទៅណាយកទៅ ។

ដានី ៖ គាត់អត់?

ដេត ៖ អូ! មិនដឹងទៅដាំត្រង់ណាទៀត គាត់ថាម៉េចធ្វើម៉េចដោះស្រាយម៉េចចេញ ។

ដានី ៖ ចុះនំប៉័ងគាត់ហូប?

ដេត ៖ គាត់ហូបនៅកន្លែងនឹង ។

ដានី ៖ ហូបនៅកន្លែងបណ្តោយ?

ដេត ៖ បាទ! ហូបនៅកន្លែងបណ្តោយ ប៉ុនអត់ហ៊ានឈរយូរទេ ដល់ហូបរួមខ្ញុំថាគាត់ថា“អត់ហ៊ាននៅទេ ខ្លាច” ។

ដានី ៖ ខ្លាចអីគេ?

ដេត ៖ ខ្លាចគេឃើញ ។

ដានី ៖ ខ្លាចពីណាគេ?

ដេត ៖ ដឹងគាត់ខ្លាចគេឃើញមិនដឹងបានសួរគាត់អីទៀត ខ្ញុំមិនបានដេញដោលខ្ញុំយល់បើអញ្ចឹងខាង ។

ដានី ៖ ចុះគាត់មាននិយាយអីជាមួយពូទៀត?

ដេត ៖ អត់មានទេ គាត់ថាវេទនាណាស់ ហើយហូបអត់គ្រប់គ្រាន់បបរ ធ្វើការអត់គ្រប់ ដែលខ្ញុំឈឺពេក ដែលបានដើរមករកអីអញ្ចឹង ។

ដានី ៖ កាលនោះអត់មានសួរឈ្មោះគាត់ទេ?

ដេត ៖ អត់បានសួររលីង មិនដឹងជាអ្នកយើងត្រូវថ្មី ។

**ផ្នែក«១»**

ដានី ៖ ចាស់ៗពីរនាក់?

ដេត ៖ ចាស់ពីរនាក់ ហើយចាស់នឹងយើងមើលមិនចាស់ប៉ុន្មាន ស្គមអត់បាយប្រុស១ស្រី១ ប៉ុន្តែក្មេងនឹងមិនមែនកូនចៅគាត់ទេ បាទ!ខ្ញុំមើលខ្ញុំអត់សួរនាំច្រើនទេ ខ្ញុំខ្លាចដែរ ព្រោះខ្ញុំមានរឿងនៅប៉ោយប៉ែតគេថាយើងខ្សែសេ.អ៊ី.អាផង មិនស្គាល់ផង ខ្លាចគេជួបតាមផ្លូវថាឯងចេះចុះអីទៀតនឹងណា យើងដល់ឃើញរូបភាពអញ្ចឹងបានយើងគិតប៉ុននឹងហើយ យើងមិនបានជួយអីគាត់ទេ ហើយក៏មិនបានណែនាំពីអីដែរ ។

ដានី ៖ កូនក្មេងនឹងស្រីៗ?

ដេត ៖ ក្មេងស្រីទាំងអស់ ។

ដានី ៖ ក្មេងស្រីទាំងអស់?

ដេត ៖ បាទ!

ដានី ៖ ហើយពូឲ្យនំប័ុងៗប៉ុន្មានទៅមនុស្សម្នាក់?

ដេត ៖ នំប័ុងថ្ងៃនឹងបានម្នាក់២ ។

ដានី ៖ បាននំប័ុងម្នាក់២?

ដេត ៖ បាទ! នំប័ុងម្នាក់២ ។

ដានី ៖ តែពួកគាត់ហូបនៅកន្លែងនឹងទាំងអស់?

ដេត ៖ ហូបនៅកន្លែងនឹង អន្គុយ ប៉ុនខ្ញុំអត់ហ៊ានសួរអីច្រើនដែរ ។

ដានី ៖ តែនំប័ុង ហើយមានអីទៀត?

ដេត ៖ នំប័ុង មៀនផ្លែមៀន ។

ដានី ៖ ចុះមៀន នំប័ុងពូបានពីណាមក?

ដេត ៖ អានោះខ្ញុំ ថ្ងៃនឹងខ្ញុំទៅលេង ខ្ញុំទៅប្រកថៃនឹង អញ្ចឹងអាថៃនឹងវាទិញផ្ញើ ។

ដានី ៖ ទិញធ្វើ?

ដេត ៖ បាទ! តែល្ងាចឡើងកន្លែងខ្ញុំយកទៅណា ពួកចៅកែៗថៃនឹង វាទាក់ទងទិញអីវ៉ែអីវ៉ាន់យើងនឹង អញ្ចឹងល្ងាចឡើងវាទិញហើយ មៀន១គីឡូ អាខ្លះ២គីឡូ អាខ្លះសៅម៉ៅ អាខ្លះមង្ឃុតអាខ្លះទំពាំង អាខ្លះនេះនឹង អាថ្ងៃខ្ញុំរៀបមកនឹង អាខ្លះទិញជានាឡិកា ទិញខ្សែដៃ ខ្សែកឲ្យទៀតណា ពួកថៃនឹង ពួកចៅកែនឹង "អត់យកៗទេ ថារបស់ស៊ីយក ថារបស់នឹងអត់យកទេ" យកទៅដឹងថាងាប់ហើយ" ហើយគេអត់ដឹងថាយើងក្នុងការងាររដ្ឋរបៀបណាអស់ដឹងទេ ដឹងថាយើងចៅកែ ជាចៅកែរងមួយសម្រាប់ធ្វើការងារ ហើយគេអត់ដឹងថាក្នុងស្រុកយើងនឹងវចនាសម្ព័ន្ធរបៀបម៉េចគេមិនដឹងជងនឹង របៀបលាក់ការណ៍ដែរនឹង ។

ដានី ៖ ដល់ពេលអង្ករនឹងឲ្យគាត់ៗយកទៅ គាត់ចែកគ្នាទាយ ឬក៏គាត់យកទៅទាំងដុំ?

ដេត ៖ គាត់កាន់ម្នាក់វេចទៅ តែដឹងចែកគ្នាមិនចែកគ្នាមិនដឹងទេ អ៊ំប្រុស បាទ!គាត់វេចយកទៅបានចែកគ្នាយ៉ាងណាអត់ដឹងទេ ព្រោះនឹកឃើញចែកគ្នាទៅ ។

ដានី ៖ ចុះពូនៅនឹង ក្រែងយើងដូចថាយើងផ្លាស់មកវិញមានគ្នាច្រើន អញ្ចឹងពូឲ្យអត់ខ្លាចអ្នកផ្សេងគេ?

ដេត ៖ អត់មានទេ កាលនឹងនោះ មានតែតែកុងឡានមួយ ។

ដានី ៖ មានតែតៃកុងមួយ ហើយនឹងលោកពូ?

ដេត ៖ បាទ! ពួកនារសាតៃកុងបើក ។

ដានី ៖ គ្នា២នាក់?

ដេត ៖ បាទ! តៃកុងនឹងវានៅជាមួយខ្ញុំយូរដែរ ស្គាល់ចិត្តគ្នា ហើយវាថា"អូ!ឲ្យគ្នាទៅទុកធេងអី ម៉ាយើងទៅនោះនេះ" ក៏អត់មានបញ្ហាទៅ ។

ដានី ៖ ក្នុងឆ្នាំ ចុងឆ្នាំ៧៦អានឹង?

ដេត ៖ បាទ! ចុងឆ្នាំ៧៦ ។

ដានី ៖ រលាប្អៀវ តែក្រោយមកពូមិនដែលជួប មិនដែលដឹងពីពួកគាត់ទៀតទេ?

ដេត ៖ បាទ! អត់ដឹង ព្រោះយើងឆ្ងងកាត់ គេឲ្យយើងឆ្លងកាត់ ។

ដានី ៖ ចុះក្រោយៗពី៧៩មក ក្រៅពីពូមានប្រសាសន៍ប្រាប់ខ្ញុំថាធ្លាប់ឲ្យអង្ករ ហើយថានៅគុំនៅផ្លូវភ្នំ ខាងជើងស្ទឹងសែននឹង មកមានអ្នកណាជួប ធ្លាប់ដូចធ្លាប់ជួយដូចថាប្រជាជនលក្ខណៈប្រជាជនគាត់ភៀសខ្លួនមក ពូជួយជូនទៅកន្លែងណាដែលមានសុវត្ថិភាព ឬក៏គាត់ឲ្យបាយឲ្យទឹកគាត់ទៀត មានដែរអត់ដូចថាប្រជាជនផ្សេង រត់អី?

ដេត ៖ នែក!ការពិតបើយើងនិយាយជំទាន់នឹង នយាយរួម ជារួមចង់និយាយថាអ្នកដែលជួបតាមផ្លូវវាច្រើន អញ្ចឹងយើងតែងតែផ្តល់អង្ករ ផ្តល់ថវិកាឲ្យគាត់រហូត កាលនោះលុយពិតមែនតែវាមិនមានទេ គ្រាន់ថាការចាយវាដូចថាម៉ាខែនៅម៉ាខែ ដូចខ្ញុំក្នុងម៉ាខែវាត្រូវបានដែរ៥-៦-៧ ពាន់បាតអីណា បានប៉ុននឹងគេផ្គត់ផ្គង់ឲ្យ អញ្ចឹងយើងទៅដោះឲ្យគាត់នឹង ។ ហើយឧទាហរណ៍ថានៅក្រោមៗអី ចាស់ៗគាត់តែអត់លុយអី យើងចេះតែឲ្យទៅ១០០បាត ២០០បាត ៥០០បាតឲ្យៗច្រើនណាស់ ប៉ុនគ្រាន់ថាឲ្យយើងចេញថាគាត់ស្គាល់រាប់អានឬឲ្យច្បាស់លាស់នោះវាគ្មានភាពច្បាស់លាស់ទេ ។

ដានី ៖ ប៉ុនដល់ពេលពូធ្លាប់ឲ្យអង្ករ ឲ្យលុយអីនឹង ច្រើននៅពេលណា នៅកន្លែងណាខ្លះបើតាមពូចាំ?

ដេត ៖ នៅម៉ាជួរប៉ុលឡក៏មាន ។

ដានី ៖ នៅណា?

ដេត ៖ នៅម៉ាជួរប៉ុលឡស្មោង ។

ដានី ៖ ប៉ុលឡស្មោង?

ដេត ៖ បាទ!

ដានី ៖ កាលនឹងពូក្រែងនៅក្នុងព្រៃតើ?

ដេត ៖ ក្នុងព្រៃប៉ុនខ្ញុំដើរម៉ាជួរនឹង វាលក្រោមនឹងគឺផ្អើលសោះម៉ង ហើយបើយើងមកបល័ក្ខនេះត្បូងយើងវិញគាត់រាប់អានខ្ញុំដែរ ខ្ញុំឲ្យលុយគាត់ទិញជ្រូក ទិញអីដែរនឹង ហើយក្បែរវត្តបល័ក្ខអាយើង ។

ដានី ៖ ក្បែរវត្តបល័ក្ខ អត់ស្គាល់ឈ្មោះគាត់ទេ?

ដេត ៖ ឈ្មោះយាយម៉ានៗ ។

ដានី ៖ យាយម៉ាននៅក្បែរវត្តបល័ក្ខ?

ដេត ៖ បាទ! នៅវត្តបល័ក្ខនឹង ។

ដានី ៖ គាត់ធ្លាប់ឲ្យអីគេ?

ដេត ៖ ឲ្យលុយគាត់ចាយនឹង ហើយគាត់រាប់អានចុះឡើង ប៉ុនគ្រាន់ថាដែលយើងមានការផ្លាស់ប្តូរជួយកសិករគេចេញពីនេះពីនោះអី ការពិតវាអត់ប៉ះដងអញ្ចឹងៗ ទាស់តែយើងទៅឃើញការវេទនារបស់គាត់អីយើងចេះតែហុចទៅ ហើយមួយទៀតដូចចាស់ៗដែលអីទូក លក់អីវ៉ៃអីវ៉ាន់តាមស៊ីងជាមួយ តាមខែទឹកឡើងចេះ កសិករពាក់មង ពាក់អីនឹង អញ្ចឹងឧទាហរណ៍ថាឃើញគាត់លក់ទៅវាវេទនាពេក វាដូចនំបញ្ចុកអានេះនឹង លតម៉ៅទៅមិនបាច់លក់ទេ យកមកយកលុយទៅ ប្រញាប់ទៅផ្ទះវិញទៅ រកស៊ីអីទៀត មានធ្វើរបៀបនឹងច្រើន ។

ដានី ៖ ប៉ុនកាលជំនាន់នឹង ក្រុមរបស់ពូចាយលុយបាត?

ដេត ៖ ចាយលុយបាត ។

ដានី ៖ ប៉ុន្តែនៅខាងក្នុងនឹងគេយកលុយបាត តែគេម៉េចចាយកើត?

ដេត ៖ អត់ទេ ដូរ អញ្ចឹងកាលនោះយើងនេះ ។

ដានី ៖ ព្រោះជំនាន់៨០ដាងក្រែងខាងនោះគេអត់ចាយលុយ?

ដេត ៖ អត់ចាយ ត្រូវដូរ ។

ដានី ៖ ត្រូវដូរ?

ដេត ៖ បាទ!ខាងនោះមាន ឧទាហរណ៍ថាលុយបាតអញ្ចឹងទៅ ហើយអ្នកដែលយើងស្គាល់ទៅលុយត្រឹមល្មមៗគេមានអាអ្នករត់រកស៊ីប៉ោយប៉ែតទៅ គេលួចដូរគ្នាទៅ ។

ដានី ៖ បើតាមពូចាំ គិតថាពូធ្លាប់ជួយគេ ឲ្យចំណីឲ្យអាហារឲ្យអង្ករឲ្យលុយកាក់អ៊ីនឹង បើតាមពូចាំប្រហែលប៉ុន្មាននាក់ដែរ?

ដេត ៖ ការពិតឲ្យចាំឈ្មោះ ឲ្យចាំសំនួរម៉ង មិនងាយចាំទេ ព្រោះក្នុងម៉ាឆ្នាំៗអស់ច្រើនដែរនឹង បើយើងគិតទៅ ព្រោះជួនកាលម៉ាខែប៉ះ២-៣នាក់ទៅៗ អញ្ចឹងយើងថារកកំណត់ចាំអត់ឃើញទេ តែកាលនោះចង់និយាយថាយើងឲ្យទិសដៅមួយគ្រាន់ថាជួបគាត់ទៅឲ្យគាត់ទៅ ថ្ងៃក្រោយយើងមានអាសន្នអីមួយមានបញ្ហាអី គាត់ឃើញយើង គាត់អាចជួយយើងវិញ ។

ដានី ៖ អញ្ចឹងមូលហេតុដែលពូជួយនឹងក្រែងលរថាយើងជួយគាត់ទៅ ក្រែងលរយើងជួបអាសន្នអីគាត់ជួយគាត់ដឹងគុណ គាត់ជួយយើងវិញ?

ដេត ៖ បាទ! ការពិតគឺចាយអញ្ចឹង ។

ដានី ៖ មូលហេតុដែលជួយនឹងគឺអញ្ចឹង?

ដេត ៖ បាទ!ជួយគឺអញ្ចឹង ហើយដូចកន្លងមកយើងធ្លាប់ជួយអញ្ចឹងទៅ ក្មេងៗមកជួយយើង.......កម្រអូសណាស់ក្មេងៗឃ្វាលគោនឹង បាទ!ជួនកាលហៅវាមក អ្នកណាមានលុយទេ អត់អីពូអត់មានទេ អញ្ចឹងហៅវាមកតំរង់ដូរឲ្យ១ពាន់ ៥រយម្នាក់អញ្ចឹងទៅ ។

ដានី ៖ ១ពាន់រៀល?

ដេត ៖ បាទ! ១ពាន់រៀល ក្មេងៗឃ្វាលគោ អញ្ចឹងយើងឲ្យវាឲ្យរៀលខ្មែរ អាណាមាឌធំតិចឲ្យវាឲ្យតាមម្នាក់៥០០ស្មើ អញ្ចឹងថ្ងៃក្រោយវាល្អនឹងយើងដែរ បើមានករណីអីវាប្រាប់យើង ។

ដានី ៖ ដូចយើងកាលនឹង ចាយលុយបាតផង លុយខ្មែរផង?

ដេត ៖ លុយបាត តែការពិតលុយបាតយើងអត់សូវនេះទេ យើងដូរហើយ ប៉ុនកាលនោះយើងមានមនុស្សណា ។

ដានី ៖ កាលនឹងច្រើនដែលពូជួយឲ្យលុយឲ្យកាក់អីអង្ករអីនឹងឆ្នាំណា?

ដេត ៖ នែក! អានៅនេះចូលយើងនៅជីក្រែងនេះ ចូលឆ្នាំនេះនឹង៩៤ ៩៥ ៩៦ ។

ដានី ៖ ជិតសមាហរណ៍កម្មហើយ?

ដេត ៖ បាទ!ជិតហើយ៩៥ ៩៦នៅជីក្រែង ហើយទៅនឹងការពិតពីមុនអ្នកស្រុកជាមួយខ្ញុំស្រឡាញ់គ្នាណាស់ ប៉ុនខ្ញុំខូចឈ្មោះតិច ខូចត្រង់ថានៅពេលដែល០៥ ០៦យកកម្លាំងទៅ សួរជីក្រែងពីណាក៏ស្គាល់ខ្ញុំដែរ ម៉ាខ្វាវឲ្យតែសួរឈ្មោះដេតអ្នកណាក៏ស្គាល់ដែរ ម៉ាឃុំខ្វាវស្គាល់ទាំងអស់ ព្រោះខ្ញុំប្រជុំភូមិគៀងគរ ហើយខ្ញុំអូសទាញយកកូនចៅគេមកប្រើៗ យកមកកាលដែលឆ្នាំទី២កម្លាំងរាជរដ្ឋាភិបាលវ៉ៃ បានកម្លាំងពួកនឹងតើមកជួយវ៉ៃខ្ញុំ មកជួយ ហើយខ្ញុំប្រជុំថាគិតទៅខ្ញុំនៅតែប៉ុន្មាន៦ខែ ៧ខែ ខ្ញុំយកបានកម្លាំង៩៥០ ។

ដានី ៖ ប្រជាជននឹង?

ដេត ៖ បាទ! ឲ្យកូនមកនៅជាមួយ ៥៥០នាក់ អញ្ចឹងខ្ញុំបេះតែកុហកគេ ទៅភរអ្នកស្រុកម៉េចនិយាយម៉េចឲ្យទំនងអ្នកស្រុកឲ្យៗកូនមក ប៉ុនអ្នកស្រុកខឹង នៅពេលដែលគាត់បេះតែគេជម្លៀសៗគាត់ចេញមក ហើយដាក់មីន ដាក់ចំរូងភូមិភាគ ។

ដានី ៖ ពីណា កាលនឹងក្រុមរបស់ពូនឹង?

ដេត ៖ ក្រុមរបស់ខ្ញុំនឹងឯង ។

ដានី ៖ អ្នកជម្លៀសប្រជាជននឹង?

ដេត ៖ បាទ! ប៉ុន្តែខ្ញុំកាលនោះគេ ខ្ញុំអត់ដឹង គេមកប្រជុំទៅ រួចទៅគេឲ្យខ្ញុំចេញ គេឲ្យពូថងៗនឹងម្ចាស់ស្រុកកន្លែងនឹង ប៉ុនគាត់ស្លាប់បាត់ហើយ អញ្ចឹងល្ងាចនឹងគេហៅខ្ញុំប្រជុំថា«ឥឡូវដេតឯងត្រូវទទួលអាត្រាក់» កាលនោះមានផ្លូវមួយទៅត្រពាំងប្រាសាទ បរអាត្រាក់ទៅលើកយកគ្រាប់ណា «ទៅយកៗចាំទទួលគ្រាប់ ហើយរៀបចំទុកដាក់អីវ៉ៃអីវ៉ាន់គ្រាន់រំសេវអង្ករអី ទុកដាក់នឹង នោះអង្ករផង អំបិលផង គ្រាប់រំសេវ» ដល់ពេលនឹងរៀបទុកដាក់ចាំធ្វើរោងជិត៣ថ្ងៃបានហើយ គ្នាប៉ុន្មាន៧-៨នាក់ ហើយកម្លាំងនៅនេះ នៅភូមិ ។ អាពេលដល់រៀបអីរួចបាន២ថ្ងៃអាពួកក្មេងទៅប្រាប់ៗថា«បង គេជម្លៀសប្រជាជនអស់» «ជម្លៀសមែន?» «ជម្លៀស» «អញមិនបាច់ចូលភូមិនឹងទៀតទេ» ។

ដានី ៖ គេជម្លៀសប្រជាជនធ្វើម៉េច គេយកកន្លែងនឹងធ្វើអីបានគេជម្លៀសប្រជាជន?

ដេត ៖ អឺ! យើងមិនយល់ គេចង់និយាយថាដើម្បីកែប្រែតំបន់គេ តំបន់ស ហើយវ៉ៃកន្លែងណាចាប់ជំរុំកន្លែងនឹងថ យើងមិនឲ្យប្រជាជនទាក់ទងមកខាងក្នុង អញ្ចឹងខ្ញុំថា«ធ្វើអញ្ចឹងងាប់ហើយ» ។

ដានី ៖ ០៥អ្នកបញ្ជាឲ្យជម្លៀស?

ជេត ៖ គានឹងបញ្ហា០៥ ជាមួយ០៦ អញ្ចឹងដល់ពេលគេជម្លៀសអញ្ចឹងអ្នកស្រុកខឹង យើងម្ចាស់ទឹកម្ចាស់ដីនៅកន្លែងនឹង សមរភូមិយើងគ្រប់គ្រង ដល់ពេលគេជម្លៀសគេឲ្យយើងទៅនោះ គេអត់ប្រាប់យើងផងនឹង ។

ដានី ៖ អញ្ចឹងក្រោយពីបែក៧៩ ពេលចូលព្រៃមកពូធ្វើសកម្មភាពខាង ជួរខាងជីក្រែង?

ជេត ៖ បាទ! ការពារដែល ចាត់ទុកខ្មែរក្រហមក្រោចប្បាប់ម៉ង ខ្ញុំភាគច្រើន ខ្ញុំនៅជីក្រែង ។

ដានី ៖ ចុះកាលពីមុន?

ជេត ៖ ពីមុន ។

ដានី ៖ ជំនាន់៨០ ឆ្នាំ៨០?

ជេត ៖ អឺ!៨០ ។

ដានី ៖ បាទ! ជំនាន់៨០ ៗ?

ជេត ៖ ៨០ ៨១ ៨២ខ្ញុំនៅលើភ្នំ ដល់ពេលចូល៨២ ចុង៨២ចូល៨៣ អានឹងខ្ញុំទៅនៅម៉ាជួរក្រោមព្រៃប្រស់នឹងឯង ។

ដានី ៖ ព្រៃប្រស់ខាងកំពង់ធំនឹង?

ជេត ៖ បាទ! ដល់ពេលជីក្រែង សៀមរាប ។

ដានី ៖ ស្ទឹងសែន?

ជេត ៖ ជងស្ទឹងសែន ម៉ាជួររហាព្រួល បាទ!ខ្ញុំនៅម៉ាជួរនឹង ក្រោយពីនឹងមកចូលដល់ឆ្នាំ៨៤ ៨២ ៨៣ ៨៤ ខ្ញុំនែក!ឡើងមកលើភ្នំ ដល់ពេលចូលពាក់កណ្តាល៨៤បានខ្ញុំទៅនៅនឹង ។

ដានី ៖ នៅណា?

ជេត ៖ នៅកពីងពួយ កន្លែងខ្ញុំមិញនឹង ៨៤ ៨៥ហើយនឹង ។

ដានី ៖ កន្លែងព្រៃប្រស់ ជងស្ទឹងសែន តាំងជីក្រែង?

ជេត ៖ បាទ! ៨៤ ៨៥ នៅនឹង ដល់ពេលម៉ាចំហៀងទៀតមក បានខ្ញុំឡើងមកខាងនេះ ដល់ពេល ៨៦ ខែ៨-៩ ៨៦បានគេឲ្យខ្ញុំទៅនៅក្រោមតាំងគោក ។

ដានី ៖ ខាងតាំងគោក?

ជេត ៖ បាទ!

ដានី ៖ តែនៅក្នុងព្រៃ?

ជេត ៖ នៅកណ្តាលវាលក្រោមនឹង វាលក្រោម វាស្មោង ។

ដានី ៖ អត់មានទាហានអី ខាងរដ្ឋាភិបាល?

ជេត ៖ វ៉ៃ នៅវ៉ៃគ្នាចុះឡើងៗ គេយកដាក់ ភូមិល្វាចឡើងភូមិប៉ុន្មានក្រោមនឹង ខ្ញុំចូល ដើរអន្ទុយ

ដឹកគ្រោតជូរ ដើរលេងនឹងទៅ យប់ឡើង១១ ១២បានមកដេកវិញមក ។

ដានី ៖ ពូខស្បាហ៍ឲ្យលុយ ឲ្យអង្ករអីខាងម៉ាចំនៀរខាងនឹង?

ដេត ៖ បាទ! ម៉ាចំនៀរខាងនឹងឯង ។

ដានី ៖ ពូដូចថាធ្លាប់កាលនឹង មូលហេតុដែលឲ្យដូចថាដើម្បី បើយើងធ្វើល្អជាមួយគេទៅ គេធ្វើល្អជាមួយយើងវិញ គេជួយដូចថាយើងជួយឲ្យលុយឲ្យកាក់នឹងដើម្បីឲ្យគេធ្វើល្អជាមួយយើងវិញ?

ដេត ៖ បាទ!

ដានី ៖ ចុះកាលដែលគេជួយពូអញ្ចឹង កាលនឹងពូមានដូចថាមានអារម្មណ៍យ៉ាងម៉េចដែរ ពេលដែលខ្ញុំសួរទាក់ទងដែលថាពូធ្លាប់បានជួយគេ បានធ្លាប់ឲ្យបាយ ឲ្យអង្ករ ឲ្យលុយឲ្យកាក់អញ្ចឹង?

ដេត ៖ ទស្សនៈខ្ញុំ?

ដានី ៖ បាទ! ឥឡូវពូនិយាយទៅ ខ្ញុំសួរនាំអញ្ចឹងពូមានអារម្មណ៍ម៉េចដែរ?

ដេត ៖ បាទ!ខ្ញុំអត់មានបញ្ហាអីទេ ព្រោះខ្ញុំគិតថាអានេះជាការអាដែលចង់ដឹងពីការពិតខ្ញុំថាតើក្នុងជីវិតរបស់ខ្ញុំវាត្រូវមានផលលំបាកយ៉ាងម៉េច ត្រូវអាដែលវាមានបញ្ហាអីខ្លះ តែខ្ញុំក៏និយាយតាមការពិត ហើយខ្ញុំកន្លងមកពិតមែនតែជានៅក្នុងតែឈ្មោះខុសាមខ្មែរក្រហម អ្នកឃោឃៅ អ្នកផ្ដាច់ការ តែខ្ញុំចំពោះខ្លួនខ្ញុំៗមិនដែលបានរំអាណាម៉ាផុងទេ តែបើបាញ់គ្នាខ្ញុំបាញ់ អានឹងក្នុងសភាពការណ៍សមរភូមិបានវាមាន តែបើក្នុងលក្ខណៈដែលខ្លួនខ្ញុំមួយទៅធ្វើបាបកសិករណាទៅធ្វើបាបប្រជាជនណា ខ្ញុំមិនដែរទេ ។ ហើយបើមិនជឿទេ សួរតាមដំណាក់កាលឃុំរបស់ខ្ញុំទៅ ហើយយើងអាចដឹងថាតើខ្ញុំឃោរឃៅមិនឃោឃៅម៉េចអាចដឹង ។

ដានី ៖ ចុះពេលដែលពូធ្លាប់ជួយគេអញ្ចឹងពូមានអារម្មណ៍ម៉េចដែរ ពេលដែលពូបានជួយគេហើយ?

ដេត ៖ ការពិតយើងគិតថាយើងមានអារម្មណ៍សប្បាយចិត្ត ព្រោះធម្មតាយើងដើរចំនុចខ្លះ ដែលយើងស្រែកឃ្លាន ហាវណាស់ ដើរកាត់ភូមិធ្វើដំណើរកាត់ភូមិ អញ្ចឹងពេលដែលយើងហាមាត់សុំពុកម៉ែតាមភូមិនឹង ម៉ែសុំអង្ករមក គិតថាយើងដាច់ហើយ អញ្ចឹងគាត់ឲ្យ អញ្ចឹងយើងមានការសប្បាយចិត្តហើយ ។ អញ្ចឹងយើងឃើញគាត់ យើងឲ្យគេៗក៏សប្បាយចិត្តដូចយើងដែរ ។

ដានី ៖ ចុះពូខ្ញុំចង់សួរពម៉ាសំនួរទៀត ដូចថាជំនាន់ពូចូលព្រៃតស៊ូអញ្ចឹង ពូមានដែលធ្លាប់ជួបដូចថាប្រជាជនដែលភៀសខ្លួនទៅជំរុំអី ពូមានដែលធ្លាប់ជួបពួកគាត់អត់?

ដេត ៖ ការពិតយើងនៅម្តុំត្រង់នេះអត់សូវមានទេ ។

ដានី ៖ អត់សូវមានទេ?

ដេត ៖ បាទ! ដូចនៅក្នុងនោះមាន ។

ដានី ៖ ខាងណា?

ដេត ៖ ម៉ាជួរពីនព្ទួយយើងនេះ អកខ្លះរត់មក ឧទាហរណ៍ថារត់មកថា“ទៅណា” “ហេ៎!មកសុំនៅជាមួយ”។

ដានី ៖ អូ! អញ្ចឹង?

ដេត ៖ បាទ!មាន ហើយអ្នកខ្លះនារីៗអីនឹង ខ្លះមិនដឹងជាទីងម៉ែឪ ឥឡូវមកដល់នឹង អ្នកខ្លះមានប្រពន្ធអី!មានប្ដីមានកូនអីរាប់នាក់ អាខ្លះការកូនការអីខ្លះ។ នែក!យើងថា“ហេតុអីបានជាមក” ជួនកាលអ្នកខ្លះថាមានការចោទប្រកាន់ ឲ្យធម្មតាភូមិនឹងមិនយើងចេញចូល ជួនកាលអ្នកធំមកធម្មតាយើងទៅមិនបានដើរលេងស្គាល់គ្រប់ផ្ទះណា ឧទាហរណ៍ថាភូមិរលួសមួយរលួសខាងក្រោម យើងចូលទៅអន្លុយលេងនឹង អញ្ចឹងអាអ្នកគេមើលពីចំងាយ អញ្ចឹងអាមានពាក្យចោទប្រកាន់អញ្ចឹង គាត់ទីងគាត់ភ័យ ជួនកាលយើងនៅនឹងគាត់មកបណ្ដោយ។ អញ្ចឹងយើងជួយគាត់យកគាត់មកដាក់ជុំរុំម៉ង អានឹងមានលក្ខណៈអញ្ចឹង។

ដានី ៖ ប៉ុន្តែដូចជាលក្ខណៈភៀសខ្លួន ចង់ភៀសទៅក្រៅប្រទេស?

ដេត ៖ អត់ៗមាន មូលហេតុអត់មាន។

ដានី ៖ អញ្ចឹងមានមុំណាខាងណា?

ដេត ៖ ការពិតមានច្រកប៉ោយប៉ែតនោះទេ។

ដានី ៖ ខាងប៉ោយប៉ែតនោះវិញ?

ដេត ៖ បាទ! ឯខាងនេះហេតុអីបានគ្មាន ព្រោះខាងនោះអត់មានប្រជាជនចេញចូល អត់ទេ ស្ងាត់ឈឹងត្រង់នេះ។

ដានី ៖ កាលជំនាន់នឹងពួកខ្មែរក្រហមដែលធ្វើសកម្មភាពខាងប៉ោយប៉ែនអីនឹង ពួកនឹងច្រើនរស់នៅណាវិញទៅ?

ដេត ៖ ពួកនឹងៗច្រើននៅខាងម៉ាឡៃៗ។

ដានី ៖ ខាងម៉ាឡៃ?

ដេត ៖ ខាងម៉ាឡៃពួកនឹងច្រើន ឯពីត្រឹមនេះមកច្រើនម៉ាជួរនេះអត់សូវមាន។

ដានី ៖ អត់មានខាងជុំរុំខាងនេះអត់មានទេ?

ដេត ៖ អត់មានទេ បាទ! ព្រោះយើងចាប់ពីមុំបីព្រំដែនឡាវមកៗដល់នេះអត់មានជុំរុំទេ មានជុំរុំ អូរត្រាវមួយ អញ្ចឹងជុំរុំអូរត្រាវនៅជ្រៅ ហើយអត់មានអាណាចេញចូលទេ អញ្ចឹងមានតែចេញពីខ្មែរក្រហមទៅៗនៅនឹង ហើយបង្កើតជុំរុំនឹងទៅអានេះតាមសភាពព្រំដែនៗ ហើយនោះគេរកស៊ីចេញចូល អញ្ចឹងគេត្រូវការទាក់ទងដាំស្វាយៗខាងថ្មពួក ខាងបឹងត្រកួនអានឹងគេចេញចូលច្រើនណាស់។ បើខាងនេះឡើងភ្នំ មានអ្នកណាគេមក អត់សូវមានទេ។

ដានី ៖ ចុះពូអ្នកដែលធ្លាប់ពូធ្លាប់ធ្វើសកម្មភាពម៉ាជួរខាងនឹង ធ្លាប់ជួយ ធ្លាប់ឲ្យអង្ករឲ្យអីនឹង ក្រោយមកក្រោយៗមកដុតពេលចប់សង្គ្រាម ពេលសមាហរណ៍កម្មហើយ ពូដែលជួបពួកគាត់ ឬក៏ទៅអីមានទំនាក់ទំនងជាមួយគាត់ម៉េចទៀតដែរអត់?

ដេត ៖ អត់ សូន្យម៉ង ។

ដានី ៖ អត់ទេ?

ដេត ៖ បាទ! ថ្ងៃមុនមានក្មេងៗនៅខាវគេមកសួររកអីចាស់ៗនឹកអី សុំឲ្យទៅលេងអី ថាអូ!គ្មានពេលអីការងារច្រើន ហើយម្យ៉ាងខ្ញុំនឹកតែយើងក្រយល់ អញ្ចឹងកាលនោះយើងមានតួនាទីអីទៅជួនកាលជួបចាស់អញ្ចឹងទៅទិញស្រាម៉ាកាន មាន២-៣កាប់ហូបទៅឲ្យគាត់ហូបទៅណា មកដល់ឥឡូវពេលយើងអត់មានអីអញ្ចឹងវាខ្មាស់គាត់ទៅម៉េច ដល់ពេលវាអត់មានពេលផង ។

ដានី ៖ កាលជំនាន់ពូធ្វើសកម្មភាពនឹង ពូតួនាទីអីដែរ?

ដេត ៖ ខ្ញុំកាលនោះ ខ្ញុំខាងនោះវរសេនាធំ ។

ដានី ៖ ប្រធានវរសេនាធំ?

ដេត ៖ សមាជិកទេ ។

ដានី ៖ សមាជិកវរសេនាធំ?

ដេត ៖ សមាជិកវរសេនាធំ ខ្ញុំឡើងតួនាទីវរសេនាធំឆ្នាំ៨៧ តួនាទីសមាជិកវរសេនាធំ ។

ដានី ៖ កងពល?

ដេត ៖ កងពល៩៨០ក៏នៅ កងពល៧៨៥ក៏នៅ ។

ដានី ៖ ពេលដែល ហ្នឹងទាំងពីធ្វើសមាជិកវរសេនាធំទាំងពីរ?

ដេត ៖ បាទ! ដូចគ្នា មុនដំបូងយុទ្ធជននៅ៩៨០ ក្រោយមកបានខ្ញុំចេញទៅដែលកាន់កងវរនៅ៧៨៥ បានរួចទៅបានឡើងសមាជិកវរសេនាធំនៅនឹងទៅ ហើយក្រោយមកទៀតមកបានគេទៅក្រោយមករយៈ ហើយបានឡប់ទៅវិញបានទៅកាន់ចាសមាជិកវរសេនាធំទៅ៩៨០នឹងនៅម៉ាជួរខ្វាវនឹង ។

ដានី ៖ ពីណាគេប្រធានកងពល?

ដេត ៖ កាលនឹងមានច្រើនដំណាក់ ប៉ុន្តែកាលគ្រប់គ្រងឌុង ឈុននី ។

ដានី ៖ បាទ! ឌុង ឈននី?

ដេត ៖ បាទ!ឌុង ឈុននី អភិបាលរងពល់ថ្ងៃនេះ គាត់គ្រប់គ្រងចុងក្រោយ មុនមកតាមុតៗ បន្ទាប់ពីតាមុតមកធ្លាក់មកលើតាប៉ាវៗ តាពឹម ដល់ពេលតាពឹមដកចេញមកបានធ្លាក់លើតានីវាមានដំណាក់កាលវា ។

ដានី ៖ បើអញ្ចឹងខ្ញុំដូចជាអស់សំនួរអីត្រូវសួរពូទៀតហើយ អញ្ចឹងចុងក្រោយខ្ញុំចង់ស្គាល់ឈ្មោះពូៗឈ្មោះអីដែរ?

ដេត ៖ ខ្ញុំឈ្មោះម៉ក់ ដេត ។

ដានី ៖ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

ដេត ៖ ខ្ញុំរាល់ថ្ងៃអាយុ៥៣ហើយ តែនៅក្នុងនេះខ្ញុំដាក់ប្រវត្តិរូបនៅឆ្នាំ១៩៧៥ ។

ដានី ៖ ពូសព្វថ្ងៃរស់នៅក្នុងភូមិ?

ដេត ៖ អូរចិញ្ចៀន ។

ដានី ៖ អូរចិញ្ចៀន ឃុំអីដែរ?

ដេត ៖ ឃុំអន្លង់វែង ។

ដានី ៖ ឃុំអន្លង់វែង ស្រុកអន្លង់វែង ។ គ្រួសារពូឈ្មោះអីដែរ ប្រពន្ធពូ?

ដេត ៖ អឺ! ទូច ឡុង ។

ដានី ៖ សព្វថ្ងៃគាត់អាយុប៉ុន្មានដែរ?

ដេត ៖ អឺ! ៤៨ ។

ដានី ៖ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ដេត ៖ ២ ។

ដានី ៖ ប្រុសទាំង២ឬក៏យ៉ាងម៉េច?

ដេត ៖ ស្រី១ ប្រុស១ ។

ដានី ៖ ស្រី១ ប្រុស១ ។ សព្វថ្ងៃពូតួនាទីពូ?

ដេត ៖ ប្រធានការិយាល័យកសិកម្មស្រុក ។

ដានី ៖ ប្រធានការិយាល័យកសិកម្មស្រុកអន្លង់វែង ។ ស្រុកកំណើតពូនៅណាដែរ?

ដេត ៖ នៅភូមិព្រិច ឃុំទ្រា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ដានី ៖ នៅភូមិព្រិច ឃុំទ្រា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ឪពុកពូឈ្មោះអីដែរ?

ដេត ៖ ឈ្មោះម៉ក់ ឡាញ់ ។

ដានី ៖ ម៉ក់ ឡាញ់ សព្វថ្ងៃគាត់នៅ?

ដេត ៖ គាត់នៅចាស់ជរាហ៎យ ។

ដានី ៖ គាត់នៅស្រុកកំណើត?

ដេត ៖ បាទ! នៅស្រុកកំណើតនឹង ។

ដានី ៖ ចុះម្ដាយ?

ផេត ៖ ម្ដាយស្លាប់បាត់ហើយ ។

ដានី ៖ គាត់ឈ្មោះអី?

ផេត ៖ ឈ្មោះ ប៉ាង ហ៊ាន ។

ដានី ៖ ប៉ាង ហ៊ាន គាត់ស្លាប់តាំងពីជំនាន់ណា?

ផេត ៖ អឺ! គាត់ស្លាប់នៅឆ្នាំ៩៨ ព្រោះខ្ញុំអត់ដឹងផង ខ្ញុំសមាហរណ៍កម្ម ខ្ញុំទៅលេង គាត់ស្លាប់បាត់ហើយ ។

ដានី ៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ផេត ៖ មាន៧នាក់ ហើយបងទី១នោះស្លាប់ប៉ុលពតវៃចោល ទាំងពូជម៉ងទាំងបងទាំងនេះកាលជំនាន់យកវៃចោលទាំងអស់ ទាំងក្មួយខ្ញុំ ទាំងប្ដីប្រពន្ធ ហើយទាំងកូនប៉ុន្មាននាក់មិនបានសួរផងកាលនឹងរត់ពីភ្នំពេញមកនៅនឹងផ្ទះនឹង ហើយដល់បងខ្ញុំគាត់នៅស្រុក នៅភូមិព្រិចនឹង ។

ដានី ៖ នៅឯខាងស្រុកកំណើត?

ផេត ៖ បាទ! ស្រុកកំណើតហើយដល់មកខ្ញុំនៅនេះ ខ្ញុំទី៣ បាទ!ទី៤បាត់ដែរ បាត់ជំនាន់៧៩ ។ ហើយមួយទៀតនៅស្រយ៉ូវ ។

ដានី ៖ នៅស្រយ៉ូវកំពង់ធំ?

ផេត ៖ កំពង់ធំ ហើយមួយទៀតនៅស្វាយ ។

ដានី ៖ នៅស្វាយ?

ផេត ៖ ហើយស្រី២នាក់នៅនឹងផ្ទះ១ទៀតស្លាប់ដែរ ដែលគ្រោះថ្នាក់របបពាឆ្នាំនឹងអស់២ ។

ដានី ៖ ស្រីតែ២ទេក្នុងចំណោម៧នាក់នឹង?

ផេត ៖ បាទ!

ដានី ៖ អញ្ចឹងពូពត៌មានដែលខ្ញុំបានសាកសួរពូនឹង ពូអាចអនុញ្ញាតិឲ្យពួកខ្ញុំយកទៅប្រើប្រាស់ដូចជាយើងសរសេរជាអត្ថបទចុះក្នុងទស្សនាវដ្ដី ឬក៏យកទៅធ្វើសិក្សាស្រាវជ្រាវផ្សេងៗពូអនុញ្ញាតិឲ្យពួកខ្ញុំយកទៅប្រើប្រាស់ដែរ?

ផេត ៖ ការពិតបើសិនជាមើលទៅ បើសិនជាលក្ខណៈណាដែលគេអានឹងប្រើក៏ប្រើទៅចុះអត់បញ្ហាទេព្រោះខ្ញុំនិយាយនឹងជាការពិតមិនមែនជារឿងអីដែរនេះទេ ហើយបើសិនណាចុះក៏ចុះ បើសិនណាតាមការគិតរបស់លោកណា ថាយ៉ាងណា ។ ហើយខ្ញុំក៏អត់បាននិយាយអីឲ្យល្អិតល្អន់ដែរបើខ្ញុំនិយាយឲ្យល្អិតល្អន់វែងឆ្ងាយនូវរឿងរបស់ខ្ញុំនេះ អូ!ច្រើនណាស់ ហើយខ្ញុំក៏អង្គុយគិតទៅក្នុងសម័យពាឆ្នាំ ចេញពីអង្គភាពមួយទៅអង្គភាពមួយសុទ្ធសម្រាប់គេច ។ ហើយដល់ពេលមកកុំបាន៧៩ ខ្ញុំក៏គ្មានបញ្ហា ព្រោះប្រឡោះគ្នាថាចុចយកហើយ អញ្ចឹងគេយកដាក់កន្លែង

លុតកន្លែងគេប្រកួតកំទេចហើយនឹង អញ្ចឹងជារឿងមួយ ។

ដានី : បាទ! អញ្ចឹងខ្ញុំអរគុណពូច្រើនដែលចំណាយពេលសំណេះសំណាលជាមួយខ្ញុំនេះ វាច្រើនម៉ោងដែលជា២ម៉ោងជាងហើយណា អញ្ចឹងខ្ញុំអរគុណច្រើនពូណា ។

ដេត : បាទ!

«ចប់»